**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# ផលប៉ះពាល់នៃការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៨ ខែមិនា ឆ្នាំ២០១៩ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **លោក ខង្យ ព្រហ្មនា**

ណែនាំដោយសាស្ត្រាចារ្យ
**បណ្ឌិត មូ ច័ន្ទគុលិកា**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១២

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ វង្ស ព្រហ្មនា ជានិស្សិតបរិញ្ញាបត្រឆ្នាំទី៤ ឆ្នាំសិក្សា២០១៨-២០១៩ ជំនាន់ទី១១ ផ្នែករដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាបឋម ខ្ញុំបាទសូមសំដែងនូវភាពកត្តញ្ញូតាធម៌ដ៏មានតម្លៃចំពោះអ្នកមានគុណទាំងទ្វេ ពោលគឺ **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់រូបខ្ញុំបាទ ព្រមទាំងសុខចិត្តលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត និងខិតខំពុះពារគ្រប់ឧបសគ្គក្នុងការចិញ្ចឹមបីបាច់ ថែរក្សា អប់រំ ប្រៀនប្រដៅ និងផ្តល់ឱកាសសម្រាប់រូបខ្ញុំបាទបានសិក្សារៀនសូត្ររហូតឈានដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យនៅក្នុងឆ្នាំនេះ។

ក្នុងឱកាសនេះដែរ ខ្ញុំបាទសូមរលឹកនឹកគុណដែលពុំអាចកាត់ថ្លៃបាន ចំពោះដួងវិញ្ញាណក្ខន្ធ **លោកយាយ** ដែលទើបទទួលមរណភាពក្នុងរយៈពេលថ្មីៗនេះ ពីព្រោះលោកយាយ ជាស្ត្រីម្នាក់តែងតែនៅក្បែរ ថែរក្សា និងផ្គត់ផ្គង់ចំពោះខ្ញុំបាទ រហូតដល់ធំដឹងក្តី។ ដូចនេះ ខ្ញុំបាទសូមអោយដួងវិញ្ញាណក្ខន្ធរបស់លោកយាយ ទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។ ក្រៅពីនេះ ខ្ញុំបាទដែលជាក្មួយប្រុស សូមសំដែងដឹងគុណផងដែរចំពោះ **អ៊ុំស្រី** ដែលតែងតែផ្តល់កម្លាំងចិត្ត អប់រំ ប្រៀនប្រដៅ និងធ្វើការផ្គត់ផ្គង់ចំពោះខ្ញុំបាទ តាមដែលអាចធ្វើទៅបាន។

សូមអរគុណដ៏ជ្រាលជ្រៅដល់ **លោកស្រីសាស្ត្រាចារ្យបណ្ឌិត មូ ច័ន្ទគុលិកា** ដែលសាស្ត្រាចារ្យម្នាក់ប្រកបដោយគតិបណ្ឌិតចំពោះនិស្សិត ព្រមទាំងជាអ្នកបានផ្តល់អនុសាសន៍សំខាន់ៗ និងមានតម្លៃសម្រាប់សារណាបញ្ចប់ការសិក្សារបស់ខ្ញុំបាទ រហូតឈានដល់ការសម្រេចបានដោយភាពជោគជ័យ។

សូមថ្លែងអំណរអគុណ **លោក លោកស្រី សាស្ត្រាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់ដែលបានខិតខំទាំងកម្លាំងកាយ និងកម្លាងចិត្តក្នុងការបណ្តុះបណ្តាលដល់រូបខ្ញុំបាទ។

ជាចុងបញ្ចប់ ខ្ញុំបាទសូមសំដែងដឹងគុណអស់ពីដួងចិត្ត និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកតាមជួយថែរក្សា **លោកអ្នកមានគុណទាំងទ្វេ អ៊ុំស្រី** និង**លោកស្រីសាស្ត្រាចារ្យបណ្ឌិត មូ ច័ន្ទគុលិកា** និងសូមឲ្យជួបប្រទះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

## អារម្ភកថា

ខ្ញុំបាទពិតជាមានសេចក្ដីសោមនស្សរីករាយយ៉ាងខ្លាំង ក្រោយពេលដឹងថា សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រ បានផ្ដល់ឱកាសឲ្យរូបខ្ញុំបាទរៀបចំ និងសរសេរសារណាបញ្ចប់ការសិក្សា ក៏ដូចជាបង្ហាញនូវសមត្ថភាព និងការយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ « **ផលប៉ះពាល់នៃការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា** (ករណីសិក្សាស្ដីពីផលប៉ះពាល់នៃការសាងសង់ និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធលើប្រសិទ្ធិភាពសេវាសាធារណៈ) »។ កម្មវត្ថុជាចម្បងដែលខ្ញុំបាទបានសម្រេចចិត្តជ្រើសរើសយកប្រធានបទនេះ ពីព្រោះថាការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ជាចំណុចរសើបមួយ ពោលគឺទទួលបានការលើកទឹកចិត្តជាខ្លាំងពីសំណាក់រាជរដ្ឋាភិបាល រហូតឈានដល់ការដាក់ផែនការជាអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណ ជាពិសេសក្នុងរយៈពេលជិតពីរទសវត្សរ៍ចុងក្រោយនេះ។ នៅក្នុងនោះ ខ្ញុំបាទបានសម្លឹងឃើញថា មានបញ្ហាចោទឡើងមួយចំនួន ពាក់ព័ន្ធនឹងការអនុវត្តឯកជនភាវូបនីយកម្មនេះ រួមមានជាអាទិ៍ ការរៀបចំ និងការគ្រប់គ្រងទៅលើការយន្តការសេវាសាធារណៈ តាមរយៈការអនុវត្តឯកជនភាវូបនីយកម្ម កត្តាសំខាន់ៗដែលរារាំងដល់ដំណើរការនៃការអនុវត្តឯកជនភាវូបនីយកម្មឲ្យទទួលបានភាពជោគជ័យជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ពិសេសជាងនេះទៅទៀត ទំនាក់ទំនងរវាងភាគីរដ្ឋ និងភាគីឯកជន នៅក្នុងនាពេលបច្ចុប្បន្នបានបង្កើតឲ្យមានតម្លាភាព និងគណនេយ្យភាពជាងមុន ដែលជាហេតុធ្វើអោយបរិយាកាសក្នុងការអនុវត្តឯកជនភាវូបនីយកម្មទទួលជោគជ័យខ្ពស់។ ទំនាក់រវាងភាគីទាំងពីរកើតមានឡើងនៅក្នុងការអនុវត្តឯកជនភាវូបនីយកម្មតាមរយៈទម្រង់ ឬយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលនឹងសបញ្ជាក់ឲ្យឃើញអំពីដំណើរការនៃការអនុវត្ត និងផលប៉ះពាល់របស់វា ជាពិសេសនៅក្នុងប្រទេសកម្ពុជាចំពោះករណីសិក្សាមួយដែលបានចុះសិក្សាស្រាវជ្រាវនៅក្រសួងសាធារណការ និងដឹកជញ្ជូន។

ខ្ញុំបាទសុំអភ័យទោសទុកជាមុននូវរាល់កំហុសឆ្គងទាំងឡាយណា ដែលកើតមានឡើងដោយអចេតនានៅក្នុងការអាត្ថាធិប្បាយរួមបញ្ចូលទាំងអត្ថន័យ ពាក្យពេចន៍ និងអក្ខរាវិរុទ្ធជាដើម។ ខ្ញុំបាទរងចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាទាំងឡាយ និងយល់ព្រមធ្វើការកែសម្រួលចំពោះអត្ថបទមួយនេះឲ្យល្អប្រសើរជាងនេះពីសំណាក់លោកសាស្ត្រាចារ្យ និងសិស្ស និស្សិតទាំងអស់ ដើម្បីទុកជាឯកសារគ្រឹះមួយក្នុងការសិក្សារៀនសូត្រទៅជំនាន់ក្រោយៗទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............ ១

១.១-លំនាំបញ្ហា ............ ១

១.២-ចំណោទបញ្ហាក្នុងការស្រាវជ្រាវ ............ ២

១.៣-គោលបំណងនៃការស្រាវជ្រាវ ............ ៣

១.៤-ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ............ ៣

១.៥-សារៈសំខាន់នៃការស្រាវជ្រាវ ............ ៤

១.៦-វិធីសាស្រ្តនៃការស្រាវជ្រាវ ............ ៤

១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ ៥

**ជំពូកទី១**

**បច្ចុប្បន្នភាពនៃការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា**

១.១-និយមន័យ ............ ៧

១.១.១-និយមន័យតាមន័យអង្គការ ............ ៨

១.១.២-និយមន័យតាមន័យខ្លឹមសារ ............ ៨

១.១.៣-និយមន័យតាមន័យគតិយុត្ត ............ ៨

១.១.៤-និយមន័យតាមមុខងារ ............ ៨

១.១.៥-និយមន័យតាមគោលនយោបាយរបស់រដ្ឋាភិបាល ............ ៩

១.២-ការបង្កើត និងការរៀបចំសេវាសាធារណៈ ............ ៩

១.៣-គោលការណ៍គ្រឹះនៃសេវាសាធារណៈ ............ ១០

១.៣.១-គោលការណ៍និរន្តភាពនៃសេវាសាធារណៈ ............ ១១

១.៣.២-គោលការណ៍កែតម្រូវនៃសេវាសាធារណៈ ............ ១២

១.៣.៣-គោលការណ៍សមភាពនៃសេវាសាធាណៈ ............ ១២

១.៤-ប្រភេទនៃសេវាសាធារណៈនៅកម្ពុជា ............ ១៣

១.៤.១-សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល ............ ១៣

១.៤.១.១-និយមន័យ ............ ១៣

១.៤.១.២-លក្ខណសម្បត្តិ.......... ១៤
១.៤.១.៣-របបគតិយុត្ត និងការគ្រប់គ្រង .......... ១៤
១.៤.១.៤-ចង្កោមសេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល .......... ១៤
១.៤.២-សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម.......... ១៦
១.៤.២.១-និយមន័យ .......... ១៦
១.៤.២.២-លក្ខណសម្បត្តិ.......... ១៦
១.៤.២.៣-របបគតិយុត្ត និងការគ្រប់គ្រង.......... ១៧
១.៤.២.៤-ចង្កោមសេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម.......... ១៧
១.៥-គោលដៅនៃសេវាសាធារណៈ.......... ២១
១.៦-យន្តការនៃការអនុវត្តក្នុងការផ្តល់សេវាសាធារណៈ .......... ២២
១.៦.១-ការកែលំអកិច្ចដំណើរការការងារនៃការផ្តល់សេវាសាធារណៈ.......... ២២
១.៦.២-ច្រកចេញចូលតែមួយ .......... ២៣
១.៦.៣-វិសហមជ្ឈការសេវាសាធារណៈ.......... ២៤
១.៦.៤-វិមជ្ឈការសេវាសាធារណៈ .......... ២៤
១.៦.៥-គ្រឹះស្ថានសាធារណៈរដ្ឋបាល .......... ២៥
១.៦.៦-សហគ្រាសសាធារណៈ .......... ២៦
១.៦.៧-កិច្ចសន្យា .......... ៣០
១.៦.៨-ភ្នាក់ងារប្រតិបត្តិការពិសេស .......... ៣១
១.៦.៩-ឯកជនភាវូបនីយកម្ម.......... ៣២

## ជំពូកទី២

## ឯកជនភាវូបនីយកម្មនៃសេវាសាធារណៈ

២.១-ការគ្រប់គ្រងរដ្ឋបាលបែបថ្មី.......... ៣៥
២.១.១-និយមន័យ .......... ៣៥
២.១.២-សញ្ញាណនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី .......... ៣៥
២.១.៣-ប្រវត្តិនៃការបង្កើតឲ្យមានការគ្រប់គ្រងរដ្ឋបាលបែបថ្មីនៅប្រទេសអភិវឌ្ឍន៍ .......... ៣៦

២.១.៤-ផលវិបាកនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី ..... ៣៨
២.២-ឯកជនភាវូបនីយកម្ម..... ៣៩
២.២.១-និយមន័យ ..... ៤០
២.២.២-កម្មវត្ថុនៃឯកជនភាវូបនីយកម្ម ..... ៤១
២.២.៣-ទម្រង់នៃឯកជនភាវូបនីយកម្ម ..... ៤២
២.២.៣.១-ភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៤៤
២.២.៣.១.១-និយមន័យ ..... ៤៤
២.២.៣.១.២-លក្ខណៈនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៤៤
២.២.៣.១.៣-ដំណើរការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៤៧
២.២.៣.១.៤-គុណសម្បត្តិ និងគុណវិបត្តិនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន .. ៥០
២.២.៤-ឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ..... ៥២
២.២.៤.១-ប្រសិទ្ធភាពនៃច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធ ..... ៥៣
២.២.៤.២-ភាពច្បាស់លាស់នៃគោលនយោបាយ ..... ៥៣
២.២.៤.៣-តុល្យភាពរវាងសេដ្ឋកិច្ចជាតិ និងឯកជន ..... ៥៤
២.២.៤.៤-សន្តិភាព និងស្ថេរភាពនយោបាយនៃប្រទេសជាតិ ..... ៥៤

## ជំពូកទី៣

## ឯកជនភាវូបនីយកម្ម និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា

៣.១-សាវតាសង្ខេបនៃការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា..... ៥៥
៣.២-គោលបំណងនៃភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជននៅកម្ពុជា ..... ៥៦
៣.៣-ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ..... ៥៧
៣.៤-គណៈកម្មការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា ..... ៥៩
៣.៥-ទ្រព្យសម្បត្តិរដ្ឋដែលជាកម្មវត្ថុនៃឯកជនភាវូបនីយកម្មនៅកម្ពុជា..... ៦៣

## ជំពូកទី៤

## ករណីសិក្សានៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន លើវិស័យ ហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា

៤.១-ពត៌មានទូទៅនៃគម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ..... ៦៥

៤.២-នីតិវិធីនៃការរៀបចំគម្រោង........................................................................ ៦៧
៤.២.១-ការចុះអនុស្សរណៈការយោគយល់........................................................ ៦៧
៤.២.២-ការធ្វើអត្តសញ្ញាណកម្មគម្រោង ........................................................ ៦៨
៤.២.៣-ការរៀបចំគម្រោង........................................................................ ៦៨
៤.៣-នីតិវិធីលទ្ធកម្មនៃគម្រោង........................................................................ ៦៩
៤.៣.១-ដំណាក់កាលនៃកិច្ចលទ្ធកម្ម ........................................................ ៦៩
៤.៣.២-ដំណាក់កាលនៃកិច្ចសន្យា........................................................ ៧០
៤.៤-ការអនុវត្តគម្រោង ........................................................................ ៧០

## ជំពូកទី៥

## ការរកឃើញ និងការពិភាក្សា

៥.១-ការរកឃើញពាក់ព័ន្ធគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ........................ ៧២
៥.១.១-នីតិវិធីនៃការរៀបចំគម្រោង ........................................................ ៧២
៥.១.២-នីតិវិធីលទ្ធកម្ម........................................................................ ៧៣
៥.១.៣-ការអនុវត្តគម្រោង........................................................................ ៧៣
៥.២-ការពិភាក្សាអំពីផលប៉ះពាល់នៃគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ.......... ៧៣
៥.២.១-ផលប៉ះពាល់ជាវិជ្ជមាន ........................................................ ៧៤
៥.២.២-ផលប៉ះពាល់ជាអវិជ្ជមាន ........................................................ ៧៤
**សេចក្តីសន្និដ្ឋាន**........................................................................ ៧៦
**អនុសាសន៍**........................................................................ ៧៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.១-លំនាំបញ្ហា

តបតាមការវិវត្តនៃចរន្តបរិបទពិភពលោក ប្រទេសទាំងអស់ទាមទារជាសំខាន់ណាស់នូវការធ្វើកំណែទម្រង់ទៅលើគោលនយោបាយ ឬប្រព័ន្ធនៃការគ្រប់គ្រងប្រទេសរៀងៗខ្លួន ដើម្បីឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់ប្រទេសជាតិ និងក្តីរំពឹងទុករបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល និងអាចមានអត្ថិភាព និងឆ្លើយតបនឹងតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម។ នៅក្នុងនោះ ការធ្វើឯកជនភាវូបនីយកម្ម ជាការកំណែទម្រង់មួយដ៏សំខាន់ផងដែរ ក្នុងគោលបំណងអោយសេដ្ឋកិច្ចជាតិមានការអភិវឌ្ឍថែមទៀត តាមរយៈការជម្រុញ និងការលើកទឹកចិត្តដល់វិស័យឯកជនក្នុងការវិនិយោគនៅក្នុងប្រទេស ព្រមទាំងចូលរួមកាត់បន្ថយនូវតួនាទីអនុវត្តដោយផ្ទាល់របស់រដ្ឋក្នុងកិច្ចការសហគ្រាសនានា។ ជាក់ស្តែង ការកសាងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស ជាចលករមួយដែលជម្រុញដល់ការអភិវឌ្ឍមិនត្រឹមតែសេដ្ឋកិច្ចជាតិនោះទេ វាក៏បានជួយលើកកម្ពស់ជីវភាពប្រជាពលរដ្ឋទូទៅផងដែរ តាមរយៈការទទួលបាននូវសេវាសាធារណៈមួយដែលមានភាពឆ្លើយតប គុណភាព និងតម្លាភាព។ ដូច្នេះ ការអនុវត្តឯកជនភាវូបនីយកម្មទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនេះ ជាផ្នែកមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍរបស់ប្រទេសជាតិ។

យ៉ាងណាមិញ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីទទួលរងនូវការបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុងដោយសារភ្លើងសង្គ្រាម គម្រោងនៃការសាងសង ឬការស្តារនូវការខូចខាតក៏ត្រូវបានរៀបចំឡើងវិញនៅក្រោមគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាល តាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណពីមួយដំណាក់កាលទៅមួយដំណាក់កាល។ នៅក្នុងនោះ ការស្តារនូវបណ្តាញផ្លូវជាតិ និងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាច្រើនខ្សែ ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ១៩៩០ រហូតមកដល់ដើមឆ្នាំ២០០០ក្រោមជំនួយហិរញ្ញប្បទានពីប្រទេសជប៉ុន សហរដ្ឋអាមេរិក អូស្ត្រាលី ធនាគារអភិវឌ្ឍអាស៊ី (ADB) ធនាគារពិភពលោក (World Bank) និងដៃគូអភិវឌ្ឍន៍ ជាច្រើនទៀត។ ការអភិវឌ្ឍក្រោមជំនួយហិរញ្ញប្បទាននេះ ធ្វើឡើងក្រោមរូបភាពផ្សេងៗគ្នា ដែលក្នុងនោះការអនុវត្តឯកជនភាវូបនីយកម្មក៏ជាផែនការអាទិភាពមួយផងដែរនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ ជាលទ្ធផល ការអភិវឌ្ឍនេះបានប្រែមុខមាត់គួរឲ្យគត់សម្គាល់សម្រាប់ប្រទេសកម្ពុជា ពោលគឺប្រែក្លាយពី

ប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធអន់ថយ ទៅជាប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធទំនើប ងាយស្រួល និងមាននិរន្តរភាព។ លើសពីនេះ វាក៏ជាផ្នែកមួយនៃការធ្វើសមាហរណកម្មសេដ្ឋកិច្ច ទាំងក្នុងតំបន់ និងក្រៅតំបន់ផងដែរ តាមរយៈការបង្កើន ពន្លឿន និងការពង្រីកការដឹកជញ្ជូនឲ្យសម ស្របទៅនឹងបរិបទនៃសាកលភាវូបនីយកម្ម។

## ១.២-ចំណោទបញ្ហាក្នុងការស្រាវជ្រាវ

ផ្តើមចេញពីការអនុវត្តជាលើកដំបូងនៅក្នុងប្រទេសឈីលី (Chile) និងចក្រភពអង់គ្លេស (The United Kingdom) នៅក្នុងចន្លោះទសវត្សឆ្នាំ១៩៧០ និងក្រោយមកទៀតបានរីករាលដាល ទៅដល់ប្រទេសនៃទ្វីបផ្សេងៗទៀតដែលមានដូចជា ប្រទេសនូវែលសេឡង់ (New Zealand) និង បារាំង (France) ក្នុងឆ្នាំ១៩៨៤ សិង្ហបុរី (Singapore) និងម៉ាឡេស៊ី (Malaysia) នៅក្នុងឆ្នាំ១៩៨៥ អាមេរិកឡាទីន (Latin America) និងប្រទេសនៅអឺរ៉ុបផ្សេងៗទៀតក្នុងទសវត្សឆ្នាំ១៩៩០ ឯកជន ភាវូបនីយកម្ម គឺគ្រាន់តែជាលទ្ធផលដែលស្តែងចេញពីដំណើរការនៃការធ្វើវិមជ្ឈការ ដែលពេលខ្លះ គេអាចនិយាយបានថាជាវិមជ្ឈការសេដ្ឋកិច្ចប៉ុណ្ណោះ ប៉ុន្តែដោយសារការវិវត្តនៃចរន្តបរិបទពិភព លោក ដំណើរការនេះបានផ្លាស់ប្តូរពីការគ្រប់គ្រងដោយរដ្ឋ និងភាពជាម្ចាស់កម្មសិទ្ធិ ទៅឲ្យវិស័យ ឯកជនស្ទើរតែទាំងស្រុង។

ចំពោះប្រទេសកម្ពុជា ការអនុវត្តឯកជនភាវូបនីយកម្មចាប់ផ្តើមអនុវត្តដំបូងនៅក្នុងឆ្នាំ១៩៨៥ ក្រោមរូបភាពនៃការអភិវឌ្ឍទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងការអភិវឌ្ឍតាមឧបករណ៍ឯក ជនភាវូបនីយកម្មនេះ បានធ្វើអោយតួនាទីរបស់រដ្ឋទៅក្នុងការវិនិយោគដោយផ្ទាល់ត្រូវបានកាត់ បន្ថយ ចំណែកឯសេវាសាធារណៈមានការទទួលខុសត្រូវ និងមានប្រសិទ្ធភាពជាងមុន។ ប៉ុន្តែ បើទោះបីជាលទ្ធផលនៅក្នុងការអនុវត្តឯកជនភាវូបនីយកម្មមានភាពល្អប្រសើរ និងអាចទទួល យកបានសម្រាប់ប្រទេសកម្ពុជាក៏ពិតមែន នៅក្នុងនោះគឺនៅមានឧបសគ្គ និងមានផលប៉ះពាល់ មួយចំនួនផងដែរ។ ដូចនេះ ដើម្បីឆ្លុះបញ្ចាំងអោយឃើញពីការផ្តល់សេវាសាធារណៈ តាមរយៈការ អនុវត្តឯកជនភាវូបនីយកម្មជាពិសេសនៅក្នុងប្រទេសកម្ពុជា និងប្រទេសកំពុងអភិវឌ្ឍន៍ សារណា បញ្ចប់ការសិក្សានេះនឹងធ្វើការបកស្រាយ ដោយគ្រប់ដណ្តប់ទៅលើសំណួរមួយចំនួនដូចខាង ក្រោម៖

១-តើការរៀបចំសេវាសាធារណៈក្រោមទម្រង់នៃការគ្រប់គ្រងរដ្ឋបាលសាធារណៈបែបថ្មីនៅប្រទេសកម្ពុជាប្រព្រឹត្តទៅយ៉ាងដូចម្តេច?

២-តើមានកត្តាសំខាន់ៗអ្វីខ្លះដែលធ្វើឲ្យការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍទទួលបានជោគជ័យ?

៣-តើការអនុវត្តឯកជនភាវូបនីយកម្មក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជាដំណើរការបានទៅយ៉ាងដូចម្តេច?

៤-តើមានផលប៉ះពាល់អ្វីខ្លះដែលកើតចេញពីការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជននៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា?

## ១.៣-គោលបំណងនៃការស្រាវជ្រាវ

ការជ្រើសរើសប្រធានបទ ផលប៉ះពាល់នៃការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា មកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈនេះ ក្នុងគោលបំណងធ្វើការស្វែងយល់ និងរំលេចឲ្យឃើញអំពីការអភិវឌ្ឍន៍របស់ប្រទេសមួយចំនួនតាមរយៈការអនុវត្តឯកជនភាវូបនីយកម្ម ជាពិសេសនោះគឺប្រទេសកម្ពុជាដែលបានផ្តល់ផែនការជាអាទិភាពទៅលើការអនុវត្តឯកជនភាវូបនីយកម្ម ចំពោះចង្កោមសេវាសាធារណៈពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ក្រៅពីនេះ សារណាបញ្ចប់ការសិក្សានេះ នឹងធ្វើការបកស្រាយឲ្យឃើញផងដែរនូវចំណុចវិជ្ជមាន និងអវិជ្ជមានបន្ទាប់ពីការអនុវត្តឯកជនភាវូបនីយកម្មជាពិសេសចង់រំលេចឲ្យឃើញកាន់តែច្បាស់នូវចំណុចជាអវិជ្ជមាន ដើម្បីជាកម្មវត្ថុនៃការស្វែងរកដំណោះស្រាយទុកជាប្រយោជន៍សម្រាប់ការអនុវត្តនាពេលក្រោយៗទៀត។

## ១.៤-ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃសារណាបញ្ចប់ការសិក្សានេះ គ្របដណ្តប់ស្ទើរតែទាំងស្រុងទៅលើការអនុវត្តឯកជនភាវូបនីយកម្ម និងការគ្រប់គ្រងរដ្ឋបាលបែបថ្មី ជាពិសេសនោះការអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅកម្ពុជា។ ក្នុងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានករណីសិក្សាជាក់ស្តែងមួយដែលត្រូវបានលើកឡើង ដោយផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

## ១.៥-សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងក្លាយជាកម្មវត្ថុនៃការចងក្រងដើម្បីទុកជាមូលដ្ឋានគ្រឹះសម្រាប់សាធារណៈជនទូទៅ ជាពិសេសអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ធ្វើការស្វែងយល់ និងស្រាវជ្រាវបន្តអំពីបច្ចុប្បន្នភាពនៃសេវាសាធារណៈ តាមរយៈការជ្រើសរើសឯកជនភាវូបនីយកម្មធ្វើជាឧបករណ៍ក្នុងការផ្តល់សេវាសាធារណៈ។ ក្រៅពីនេះ ការសិក្សាស្រាវជ្រាវនេះក៏បានរួមចំណែកផងដែរ ដើម្បីពង្រឹងការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ដោយហេតុតែនៅក្នុងការសិក្សាស្រាវនេះបានរំលេចឲ្យឃើញអំពីការអនុវត្ត ក៏ដូចជាបទពិសោធន៍ពីបណ្តាប្រទេសអភិវឌ្ឍន៍មួយចំនួនផងដែរ។ ចំណែកឯអនុសាសន៍ក្នុងរបាយការណ៍ស្រាវជ្រាវនេះ អាចជាមូលដ្ឋានសម្រាប់អ្នករៀបចំគោលនយោបាយសាធារណៈ និងអ្នកធ្វើកំណែទម្រង់សាធារណៈ ក្នុងការធ្វើឱ្យប្រសើរដល់ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈនៅកម្ពុជា។

## ១.៦-វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី ផលប៉ះពាល់នៃការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជានេះ ប្រើវិធីសាស្ត្រស្រាវជ្រាវគុណវិស័យ បែបជាការវិភាគឯកសារ និងករណីសិក្សា។ វិធីសាស្ត្រស្រាវជ្រាវគុណវិស័យ ជាការសិក្សាស៊ីជម្រៅលើស្ថានភាពពិត ឬធម្មជាតិនៃកម្មវត្ថុនៃការសិក្សា។ ក្នុងនោះ អ្នកស្រាវជ្រាវសួរសំណួរស្រាវជ្រាវដែលមានលក្ខណៈទូលាយ ដើម្បីស្វែងយល់ បកស្រាយ និងយល់ពីបរិបទសង្គម។ មានតថភាពសង្គមជាច្រើនជុំវិញបញ្ហាដែលអ្នកចង់សិក្សា និងអ្នកចង់ស្វែងយល់ពីការបង្កើតតថភាពសង្គមទាំងនោះ។ វិធីសាស្ត្រនេះទាក់ទងនឹងការកំណត់ទស្សនៈយល់ឃើញរបស់មនុស្ស។

ឯកសារដែលយកមកវិភាគ មានឯកសារច្បាប់ លិខិតបទដ្ឋានគតិយុត្ត គោលនយោបាយរបស់រដ្ឋាភិបាល គោលនយោបាយរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងសុន្ទរកថារបស់ថ្នាក់ដឹកនាំប្រទេស របាយការណ៍ស្រាវជ្រាវរបស់អង្គការអន្តរជាតិ និងអត្ថបទស្រាវជ្រាវជាភាសាខ្មែរ និងអង់គ្លេស ដែលពាក់ព័ន្ធនឹងការធ្វើឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍ និងក្នុងប្រទេសកម្ពុជា និងរបាយការណ៍របស់រដ្ឋាភិបាលកម្ពុជាដើម។

ការប្រើករណីសិក្សាក្នុងការស្រាវជ្រាវ ផ្តល់នូវការយល់ដឹងយ៉ាងស៊ីជម្រៅអំពីការអនុវត្តជាក់ស្តែងនៅក្នុងបរិបទ ឬករណីនីមួយៗ។ ក្នុងដំណើរការនៃករណីសិក្សានេះ អ្នកស្រាវជ្រាវបានចុះទៅប្រមូលទិន្នន័យចម្បងពីក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈការសម្ភាសជាមួយមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលក្នុងនោះផ្តោតជាសំខាន់ទៅលើ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ដើម្បីជាមូលដ្ឋាននៃការយល់ដឹង វិភាគ និងវាយតម្លៃលើការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈតាមទម្រង់ឯកជនភាវូបនីយកម្ម និងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា។ ជាងនេះទៅទៀត អ្នកស្រាវជ្រាវក៏បានសិក្សា និងវិភាគលើឯកសារគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ។ ដោយសារពេលវេលាស្រាវជ្រាវមានកំណត់ អ្នកស្រាវ ជ្រាវមិនអាចជួបសម្ភាសជាមួយប្រជាពលរដ្ឋ (អតិថិជន) ដែលទទួលបានសេវា "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" បានទេ។ ប៉ុន្តែអ្នកស្រាវជ្រាវអាចឆ្លុះបញ្ចាំងពីបទពិសោធរបស់ខ្លួនដែលធ្លាប់បានទទួលសេវានេះ។ ប៉ុន្តែ ដោយសារបញ្ហាការធ្វើឯកជនភាវូបនីយកម្មលើសេវាសាធារណៈ ជាបញ្ហារសើបមួយ (ទស្សនៈភាគច្រើនរបស់សាធារណជន ថាមានពាក់ព័ន្ធនឹងបញ្ហាពុករលួយ និងនយោបាយ) មន្ត្រីដែលអ្នកស្រាវជ្រាវបានជួប មិនបានផ្តល់ព័ត៌មានស៊ីជម្រៅលើការអនុវត្តគម្រោងជាក់ស្តែងទេ។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះនៅតែផ្អែកលើការសិក្សាឯកសារជាចម្បង។

## ១.៧-រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះ ត្រូវបានរៀបរៀងឡើងដោយបែងចែកទៅជាប្រាំជំពូក រួមមានជំពូកទី១៖ បច្ចុប្បន្នភាពនៃការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា ជំពូកទី២៖ ឯកជនភាវូបនីយកម្មនៃសេវាសាធារណៈ ជំពូកទី៣៖ ឯកជនភាវូបនីយកម្ម និងភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា ជំពូកទី៤៖ ករណីសិក្សានៃយន្តភាពជាដៃគូរវាងរដ្ឋ និងឯកជនទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា និងជំពូកទី៥៖ ការរកឃើញ និងការពិភាក្សា។

# ជំពូកទី១

# បច្ចុប្បន្នភាពនៃការរៀបចំ និង
# ការគ្រប់គ្រងសេវាសាធារណៈ
# នៅកម្ពុជា

# ជំពូកទី១

# បច្ចុប្បន្នភាពនៃការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា

ការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន មានលក្ខណៈខុសគ្នាពីការផ្តល់សេវាសាធារណៈនៅក្នុងសម័យបុរាណ។ នៅក្នុងសម័យបុរាណ សេវាសាធារណៈត្រូវបានចាត់ទុកថាជាកាតព្វកិច្ចមួយ ដោយដាក់បន្ទុកទៅលើព្រះមហាក្សត្រខ្មែរ ដូចជាការសាងសង់មន្ទីរពេទ្យ ការសាងសង់ប្រាង្គប្រាសាទ ទីសក្ការៈ ផ្សេងៗ។ ចំពោះផ្នែកសេវាធនធានទឹក គឺព្រះមហាក្សត្រខ្មែរមានករណីកិច្ចក្នុងការដោះស្រាយ ដើម្បីស្រោចស្រពដីស្រែចំការរបស់ប្រជារាស្ត្រ។ នៅក្នុងសម័យកាលនោះ ការធានារ៉ាបរងផ្នែកធនធានទឹកដើម្បីស្រោចស្រព ជាសញ្ញាណដំបូងនៃការរៀបចំ និងបង្កើតសេវាសាធារណៈ ដែលមានព្រះមហាក្សត្រ ជាតួអង្គមួយដែលមានព្រះរាជភារកិច្ចយ៉ាងសកម្ម ក្រៅពីតំណាងឲ្យរដ្ឋ។ ក្នុងន័យនេះ តាមការសង្កេតរបស់អ្នកប្រវត្តិសាស្ត្រ ព្រះមហាក្សត្រខ្មែរតែងគិតគូអំពីប្រព័ន្ធទឹក ដោយការបង្កើត ឬស្ថាបនាបារាយទប់ទឹកជានិច្ច មុននឹងចាប់ផ្តើមស្ថាបនាអ្វីៗផ្សេងទៀត។ នៅក្នុងនោះ កំណែន និងពន្ធ ត្រូវបានបង្កើតឡើងផងដែរ តាមរយៈការដកហូតពន្ធជារៀងរាល់ឆ្នាំ ក្នុងគោលបំណងឆ្លើយតបទៅតាមសេចក្តីត្រូវការនៃសេវាសាធារណៈ។[1]

ប៉ុន្តែ ការផ្តល់សេវាសាធារណៈក្រោមយន្តការបែបនេះត្រូវបានផ្លាស់ប្តូរ បើទោះបីជាព្រះមហាក្សត្រទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់ប្រជារាស្ត្ររបស់ទ្រង់ក៏ដោយ ដើម្បីឆ្លើយតបតាមសកលភាវូបនីយកម្ម និងដោយសារការផ្លាស់ប្តូររបបនយោបាយ សេដ្ឋកិច្ច និងសង្គម។ ជាសកល ការផ្លាស់ប្តូរនេះកើតមានឡើងដោយសារការវិវត្តនៃបរិបទពិភពលោក ទៅរករដ្ឋបាលសាធារណៈ និងសេវាសាធារណៈដែលគិតអំពីការលើកកម្ពស់សុខមាលភាពរបស់ប្រជាជន និងទម្រង់នៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី (New Public Management-NPM) ត្រូវបានដាក់ឲ្យអនុវត្តក្នុងទសវត្សរ៍ឆ្នាំ១៩៧០ ដោយជំនួសអោយការគ្រប់គ្រងរដ្ឋបាលតាមបែបបុរាណ។ សម្រាប់ប្រទេសកម្ពុជា ប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលបែបបុរាណត្រូវបានកែទម្រង់ជាបន្តបន្ទាប់ និងបានចាប់ផ្តើមបើកទំព័រសក រាជថ្មី នៃការចាប់ផ្តើមអនុវត្តប្រព័ន្ធនៃការគ្រប់គ្រង់រដ្ឋបាលបែបថ្មី ក្រោយពេលដែលសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃត្រូវបានបញ្ចប់ តាមរយៈការបង្កើតនូវកិច្ចព្រមព្រៀងសន្តិភាពក្រុងបារីសនៅ

[1] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ១។

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងឈានដល់ការបោះឆ្នោតជាសកលក្នុងឆ្នាំ១៩៩៣។ ការកែទម្រង់រដ្ឋបាលសាធារណៈដ៏ស៊ីជម្រៅ ក្រោមរូបភាពជាការគ្រប់គ្រងរដ្ឋបាលបែបថ្មី ដោយផ្តោតសំខាន់ទៅលើសេវាសាធារណៈ ត្រូវបានចាប់ផ្តើមពីឆ្នាំ២០០៤ និងមានការវិវឌ្ឍន៍រហូតមកដល់ពេលបច្ចុប្បន្ន[2]។ ដូចនេះ ដើម្បីយល់ឲ្យកាន់តែច្បាស់អំពីបច្ចុប្បន្នភាពនៃសេវាសាធារណៈនៅកម្ពុជា សារណាបញ្ចប់ការសិក្សានេះនឹងលើកយកនូវចំណុចសំខាន់ៗមួយចំនួនដូចជា (១.១)-និយមន័យនៃសេវាសាធារណៈ (១.២)-ការបង្កើត និងការរៀបចំសេវាសាធារណៈ (១.៣)-គោលការណ៍គ្រឹះនៃសេវាសាធារណៈ (១.៤)-ប្រភេទនៃសេវាសាធារណៈ (១.៥)-គោលដៅនៃសេវាសាធារណៈ និង (១.៦)-យន្តការនៃការអនុវត្តក្នុងការផ្តល់សេវាសាធារណៈ។

## ១.១-និយមន័យ

ពាក្យថា សេវាសាធារណៈ គឺជាកន្សោមពាក្យរវាង "សេវា" និង "សាធារណៈ"។ នៅក្នុងនោះ ពាក្យថា "សេវា" គ្មានចែងនៅក្នុងវចនានុក្រមខ្មែរ ភាគទី២ របស់សម្តេចព្រះមហាសុមេធាធិបតី ជោតញ្ញាណោ សង្ឃនាយក គណៈមហានិកាយ ជួន ណាត ឡើយ។ មានន័យថា ពាក្យនេះ ជាការបកប្រែ និងបង្កើតឡើងដើម្បីតម្រូវទៅនឹងពាក្យ ឬភាសាបរទេសប៉ុណ្ណោះ។ វាគ្មានឫសគល់នៃពាក្យ និងគ្មានប្រភពច្បាស់លាស់នៃពាក្យទេ។ ប៉ុន្តែ ពាក្យនេះមានឥទ្ធិពលខាបសណ្តំជនជាតិខ្មែរឲ្យវង្វេង និងប្រើប្រាស់ជាប្រចាំ។[3] ចំណែកឯពាក្យ "សេវាសាធារណៈ" គឺមានកំណត់នៅក្នុងវចនានុក្រមខ្មែរ ដោយឲ្យនិយមន័យថា ដែលទូទៅ ដែលទុកជាកណ្តាល ដែលប្រើបានទាំងអស់គ្នា និងដែលមិនចំពោះមួយៗ។[4]

ជារួមមក សម្រាប់ប្រទេសកម្ពុជា ពាក្យថា "សេវាសាធារណៈ" មិនត្រូវបានកំណត់នៅក្នុងវចនានុក្រមណាមួយឡើយ ក្រៅពីការយកនិយមន័យជាទូទៅ[5] និងនិយមន័យដែលកំណត់នៅក្នុង

[2] និស្សិត យ៉ន សារ៉េត និង ក. យឹម វណ្ណឌីម៉ង់ (២០១៥), សារណាបញ្ចប់ការសិក្សា៖ *ការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ*។

[3] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ១។

[4] និស្សិត យ៉ន សារ៉េត និង ក. យឹម វណ្ណឌីម៉ង់ (២០១៥), សារណាបញ្ចប់ការសិក្សា៖ *ការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ*។

[5] និយមន័យជាទូទៅមានដូចជា និយមន័យតាមអង្គការ (ស្ថាប័ន) និយមន័យតាមខ្លឹមសារ និយមន័យតាមគតិយុត្ត និង និយមន័យតាមមុខងារ។

គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈមកប្រើប្រាស់។ និយមន័យទាំងអស់នោះត្រូវបានកំណត់ដូចខាងក្រោម៖

**១.១.១-និយមន័យតាមន័យអង្គភាព**

សេវាសាធារណៈ គឺជាមន្ត្រីរាជការបុគ្គលិក និងមធ្យោបាយនានាដែលនីតិបុគ្គលសាធារណៈដាក់មកបម្រើការងារមួយរបស់ខ្លួន។[6]

**១.១.២-និយមន័យតាមន័យខ្លឹមសារ**

សេវាសាធារណៈ គឺជាសកម្មភាពដែលបម្រើអោយផលប្រយោជន៍ទូទៅ ដែលរាជការជាអ្នកទទួលបន្ទុក។[7]

**១.១.៣-និយមន័យតាមន័យគតិយុត្ត**

សេវាសាធារណៈ គឺជាសកម្មភាពរបស់រាជការ ដែលនៅក្នុងរបបគតិយុត្តមួយខុសពីនីតិរួមពោលគឺនីតិរដ្ឋបាលតែម្តង។ បើតាមលោកសាស្ត្រាចារ្យច្បាប់ Jean Rivero វិញបានឲ្យនិយមន័យថា សេវាសាធារណៈជារូបភាពមួយនៃអំពើរបស់រាជការដែលនៅក្នុងនោះ នីតិបុគ្គលសាធារណៈទទួលភារកិច្ចបំពេញតម្រូវការនៃប្រយោជន៍ទូទៅ។[8]

**១.១.៤-និយមន័យតាមមុខងារ**

សេវាសាធារណៈ គឺជាសកម្មភាពនៃសេវាមួយ កាលណាសកម្មភាពនោះត្រូវបានធានា និងទទួលបន្ទុកដោយបុគ្គលសាធារណៈ ក្នុងគោលបំណងបម្រើប្រយោជន៍សាធារណៈ ឬប្រយោជន៍ទូទៅ ឬប្រើប្រយោជន៍របស់ប្រជាពលរដ្ឋ ហើយស្ថិតនៅក្រោមនីតិសាធារណៈ ឬនីតិឯកជន ឬនីតិចម្រុះ។[9]

---

[6] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ ២០៦។

[7] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២០៦។

[8] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២០៦។

[9] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២០៦។

### ១.១.៥-និយមន័យតាមគោលនយោបាយរបស់រដ្ឋាភិបាល

សេវាសាធារណៈ សំដៅដល់រាល់សកម្មភាពទាំងឡាយណា ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច ក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។ ចំពោះពាក្យថា "ស្ថាប័នមានសមត្ថកិច្ច" សំដៅដល់រដ្ឋ ភ្នាក់ងាររដ្ឋ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ចំណែកឯពាក្យ "ស្ថាប័នទទួលសមត្ថកិច្ច" សំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋ ហើយដែលស្ថិតនៅក្រោមការគ្រប់គ្រង ត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។[10]

ដូចនេះ សរុបជារួមមកវិញ ពាក្យថា សេវាសាធារណៈ គឺសំដៅដល់សកម្មភាពទាំងឡាយណាដែលផ្តើមចេញពីការរៀបចំដោយនីតិបុគ្គលសាធារណៈ ឬនីតិឯកជន ឬនីតិចម្រុះ ក្នុងគោលបំណងបម្រើផលប្រយោជន៍ទូទៅប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធិផល ដោយមានមន្ត្រីរាជការជាតួអង្គមួយដ៏សំខាន់ ដែលដើរតួជាអ្នកផ្តល់សេវាដែលមានភក្តីភាព មានសីលធម៌វិជ្ជាជីវៈ និងផ្តោតលើ សេវាប្រសើរជាងការគ្រប់គ្រង មានន័យថា ត្រូវប្រែក្លាយពីអ្នកគ្រប់គ្រង ទៅជាអ្នកផ្តល់សេវាគួរជាទីគោរព និងមានភាពត្រឹមត្រូវក្នុងការបម្រើ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ឬអ្នកទទួលសេវាសាធារណៈ។

## ១.២-ការបង្កើត និងការរៀបចំសេវាសាធារណៈ

នៅក្នុងរដ្ឋប្រជាធិបតេយ្យ រាស្ត្រប្រជាមានសិទ្ធិទទួលបាននូវដំណើរការប្រព្រឹត្តទៅនៃសេវាសាធារណៈ និងសិទ្ធិទទួលឲ្យមានសេវាសាធារណៈ ហើយសិទ្ធិនេះត្រូវបានចែងដោយរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទបញ្ញា។[11] ដូចនេះ រាល់ការបង្កើតសេវាសាធារណៈ ដែលមានស្ថាប័នទទួលសមត្ថកិច្ចអាស្រ័យទៅតាមចង្កោមនីមួយៗ ត្រូវអនុវត្តដោយស្ថិតនៅក្រោមច្បាប់ និងបទបញ្ញាដែលពាក់ព័ន្ធ។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា សេវាសាធារណៈ ជាផែនការអាទិភាពមួយនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពអភិបាលកិច្ច ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។ នៅក្នុងនោះ អាជ្ញាធររដ្ឋត្រូវមានសមត្ថកិច្ចក្នុងការបង្កើត និងរៀបចំ

[10] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ:*, ទំព័រ៦។

[11] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៧។

សេវាសាធារណៈ ដើម្បីឆ្លើយតបទៅតាមសេចក្តីត្រូវការរបស់ប្រជារាស្ត្រ។ ឧទាហរណ៍៖ ដើម្បីផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ និងដើម្បីចូលរួមសម្រេចឲ្យបាននូវគោលបំណងរួមក្នុងការបង្កើត ការជម្រុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើត គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ឡើង។[12] គណៈកម្មាធិការជាតិនេះមានសមត្ថកិច្ចក្នុងការគិតគូទៅលើបញ្ហាអាទិភាពមួយចំនួនដូចខាងក្រោម៖

- កសិកម្ម
- អប់រំ
- ព្រៃឈើ ធនធានធម្មជាតិ និងបរិស្ថាន
- សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជន រួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជនជាតិដើមភាគតិច
- ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច
- ការផលិត និងការចែកចាយអគ្គិសនី
- ការគ្រប់គ្រងទឹក
- ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយ សម្ភារៈចាំបាច់ ដើម្បីគាំទ្រ និងចាត់ចែងការទទួលខុសត្រូវទាំងនេះ និង
- តម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាក់លាក់ សម្រាប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដោយគិតទាំងវិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរដំណែលវប្បធម៌ផងដែរ។

## ១.៣-គោលការណ៍គ្រឹះនៃសេវាសាធារណៈ

ដើម្បីផ្តល់សេវាសាធារណៈដល់ប្រជាពលរដ្ឋអោយកាន់តែប្រសើរ ស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច ត្រូវគោរពទៅតាមគោលការណ៍គ្រឹះចំនួនបីយ៉ាងសំខាន់ៗ[13] រួមមាន

[12] មាត្រា២១៣, *ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*, ២០០៨។

[13] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៨។

គោលការណ៍និរន្តភាពនៃសេវាសាធារណៈ គោលការណ៍កែតម្រូវនៃសេវាសាធារណៈ និងគោលការណ៍សមភាពនៃសេវាសាធារណៈ។

**១.៣.១-គោលការណ៍និរន្តភាពនៃសេវាសាធារណៈ**

សេវាសាធារណៈ ត្រូវជាប់លាប់មិនអាចឈប់ ឬដាច់បានឡើយ។ គោលការណ៍នេះ ជាផលវិបាកនៃនិរន្តរភាពរបស់រដ្ឋ ព្រោះរដ្ឋមានអត្ថិភាពជារៀងរហូត ទោះបីមានការផ្លាស់ប្តូររដ្ឋាភិបាលក៏ដោយ។ ដូច្នេះ សេវាសាធារណៈក៏ត្រូវបានគេរក្សាជានិរន្តរ៍ផងដែរដែរ។ គោលការណ៍និរន្តរភាពនៃសេវាសាធារណៈនេះ ត្រូវបានសិក្សាក្រោមរូបភាពពីរគឺៈ[14]

**១-បុព្វសិទ្ធិដែលត្រូវបានប្រគល់ទៅឲ្យរាជការ៖** ក្នុងន័យនេះចង់បញ្ជាក់ថា រាជការមានបុព្វសិទ្ធិគ្រប់គ្រាន់ក្នុងការកំណត់ពីសិទ្ធិផ្សេងៗ ជាប្រយោជន៍ដើម្បីធានាសេវាសាធារណៈ។[15] ឧទាហរណ៍ ៖ បុព្វសិទ្ធិនោះអាចជា សិទ្ធិធ្វើកូដកម្ម ពោលគឺច្បាប់បានផ្តល់សិទ្ធិដល់មន្ត្រីគ្រប់ជាន់ថ្នាក់ ឬអាជ្ញាធរសាធារណៈអាចធ្វើកូដកម្មដោយសន្តិវិធី[16] ក្នុងករណីដែលមើលឃើញថាសេវាសាធារណៈ ដែលរៀបចំដោយរាជរដ្ឋាភិបាល ជាពិសេសអាជ្ញាធរថ្នាក់ជាតិ មិនបម្រើដល់ផលប្រយោជន៍សាធារណៈ។

**២-កាតព្វកិច្ចដែលធ្លាក់ទៅលើអំណាចសាធារណៈ៖** ក្នុងន័យនេះចង់បញ្ជាក់ថា រាជការមានបុព្វសិទ្ធិបង្ខំឲ្យសម្បទាននិក បម្រើសេវាសាធារណៈឲ្យបានល្អ តាមរយៈកិច្ចសន្យារដ្ឋបាល[17] បើពុំនោះទេ រាជការនឹងដាក់ទណ្ឌកម្ម (ផាក ផ្អាក ឬលុបចោល) ហើយក្នុងករណីនេះ រាជការជំនួសសម្បទានិក ដែលករណីនេះចៅក្រមជាអ្នកមានសមត្ថកិច្ច។ ក្នុងករណីប្រធានសក្តិដែលសម្បទានិក បានជួបប្រទះដូចជា សេដ្ឋកិច្ចគ្មានលំនឹង ដែលជាហេតុធ្វើឲ្យសម្បទានិកពុំមានលទ្ធភាពក្នុងការបន្តនៅកិច្ចសន្យារបស់ខ្លួនបាន រាជការមានកាតព្វកិច្ចនៅក្នុងការផ្តល់

[14] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៨។

[15] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៨។

[16] មាត្រា៣៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

[17] ***កិច្ចសន្យារដ្ឋបាល*** គឺជាកិច្ចសន្យាទាំងឡាយណា ដែលមានគូភាគីយ៉ាងហោចណាស់មួយជាអាជ្ញាធរសាធារណៈ ហើយដែលមានបុព្វសិទ្ធិសាធារណៈក្នុងការសើរើកែប្រែលើកិច្ចសន្យានេះ។

នូវមធ្យោបាយផ្នែកហិរញ្ញវត្ថុដល់សម្បទានិក តាមរយៈការអនុវត្តន៍នូវទ្រឹស្តីនៃ ការផតព្រៀង ទុក។[18]

**១.៣.២-គោលការណ៍កែតម្រូវនៃសេវាសាធារណៈ**

គោលការណ៍នេះ មានន័យថា សេវាសាធារណៈត្រូវមានការកែតម្រូវដែលផ្តល់លទ្ធភាពឲ្យរាជការទាមទារបានពីសម្បទានិក ដែលជួនកាលធ្វើឲ្យកាន់តែប្រសើរឡើងនូវគុណភាពការងារ និងបរិមាណរបស់វា។ ដើម្បីបំពេញបំណងនៃផលប្រយោជន៍ទូទៅនៅក្នុងករណីដែលមានការទាមទារនៃផលប្រយោជន៍ទូទៅនេះ នាំឲ្យមានការផ្លាស់ប្តូរសេវាសាធារណៈ។ នៅក្នុងករណីអានុភាពនៃកិច្ចសន្យាសម្បទាន មិនមែនជាឧបសគ្គដល់គោលការណ៍កែតម្រូវនៃសេវាសាធារណៈរបស់សម្ប-ទានិកនោះទេ។ ក្នុងន័យនេះចង់បញ្ជាក់ថា សម្បទានិក ក៏មានសិទ្ធិអំណាចគ្រប់គ្រាន់នៅក្នុងការកែប្រែជាឯកតោភាគីនៃកិច្ចសន្យាសម្បទានក្នុងផលប្រយោជន៍ទូទៅ។[19]

សម្រាប់ប្រទេសកម្ពុជា មានករណីសិក្សាជាច្រើនពាក់ព័ន្ធនឹងកិច្ចសន្យាសម្បទាន ដែលរដ្ឋបានលើកទឹកចិត្តឲ្យមានការចូលរួមពីវិស័យឯកជនឲ្យកាន់តែប្រសើរឡើង នៅក្នុងការផ្តល់សេវាសាធារណៈទៅតាមចង្កោមនៃសេវាសាធារណៈផ្សេងៗគ្នា ក្នុងគោលបំណងកែប្រែនូវសេវាសាធារណៈអោយកាន់តែមានប្រសិទ្ធភាព និងប្រសិទ្ធផល។ នៅក្នុងនោះ ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាផែនការអាទិភាពមួយក្នុងគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជា ក្នុងការលើកទឹកចិត្តទៅដល់ក្រុមហ៊ុនឯកជន ដើម្បីវិនិយោគទៅលើគម្រោងដែលរដ្ឋបានបង្កើតឡើង។ ការអនុវត្តក្រោមរូបភាពបែបនេះ ជាផ្នែកមួយនៃយន្តការផ្តល់សេវាសាធារណៈក្រោមទម្រង់ឯកជនភាវូបនីយកម្មដែលនឹងត្រូវសិក្សាស៊ីជម្រៅបន្ថែមទៀតនៅក្នុង ជំពូកទី២ ជំពូកទី៣ និងជំពូកទី៤ នៃសារណាបញ្ចប់ការសិក្សានេះ។

**១.៣.៣-គោលការណ៍សមភាពនៃសេវាសាធារណៈ**

គោលការណ៍សមភាពនៃសេវាសាធារណៈនេះ មានន័យថា អ្នកប្រើប្រាស់ដែលស្ថិតនៅក្នុងស្ថានភាពតែមួយដូចគ្នាទាំងអង្គច្បាប់ និងអង្គហេតុ។ គោលការណ៍សមភាពសេវាសាធារណៈនេះ

[18] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៨-២១៩។

[19] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៩។

ត្រូវទទួលបាននូវអាកប្បកិរិយាដូចគ្នា។[20] សមភាពនៃអ្នកប្រើប្រាស់សេវាសាធារណៈ ដោយគ្មានការរើសមុខអតិថិជន។ តម្លៃសេវាកម្រិតណា សេវាដែលអ្នកប្រើប្រាស់ត្រូវទៅតាមកម្រិតនោះដូចៗគ្នាទាំងអស់។ អ្នកមកដល់មុន ត្រូវទទួលមុន អ្នកមកដល់ក្រោយ នឹងត្រូវទទួលក្រោយដូចៗគ្នាស្មើៗគ្នាដោយគ្មានការរើសអើង។[21]

ជារួមមក គោលការណ៍សមភាពនៃសេវាសាធារណៈ ត្រូវតែធានាធ្វើយ៉ាងណាឲ្យនីតិបុគ្គលដែលច្បាប់បានអនុញ្ញាត ត្រូវបម្រើប្រយោជន៍រួម ដោយជៀសវាងនូវការរើសអើងដោយប្រការណាមួយដូចជា ជាតិសាសន៍ ពណ៌សម្បុរ សាសនា មាន ក្រ ទាប ខ្ពស់ជាដើម។

## ១.៤-ប្រភេទនៃសេវាសាធារណៈនៅកម្ពុជា

យោងតាមគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ដែលអនុម័តដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦ សេវាសាធារណៈនៅកម្ពុជាត្រូវបានចងក្រងទៅជាប្រាំពីរចង្កោមធំៗ និងបានបញ្ជាក់ពីការទទួលខុសត្រូវទៅតាមក្រសួងស្ថាប័នដែលមានសមត្ថកិច្ចផ្សេងៗគ្នា។ ប៉ុន្តែ ដើម្បីឲ្យកាន់តែច្បាស់បន្ថែមទៀត ចង្កោមសេវាសាធារណៈនេះ ត្រូវបានប្រមូលផ្តុំជាពីរប្រភេទធំៗទៅតាមវិស័យផ្សេងៗគ្នា ពោលគឺអាស្រ័យទៅតាមការវិវឌ្ឍនៃសេដ្ឋកិច្ចទីផ្សារ បច្ចេកវិទ្យាទំនើប និងតម្រូវការជាក់ស្តែងដទៃទៀតដែលកើតមានឡើងពីការវិវត្តនៃសង្គមជាតិ[22]។ សេវាសាធារណៈដែលប្រមូលផ្តុំជាពីរប្រភេទធំៗនោះរួមមាន សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល និងសេវាសាធារណៈមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម។

### ១.៤.១-សេវាសាធាណៈដែលមានលក្ខណៈរដ្ឋបាល

#### ១.៤.១.១-និយមន័យ

សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល គឺជាសកម្មភាពទាំងឡាយណា ដែលគ្រប់គ្រងដោយនីតិបុគ្គលសាធារណៈដើម្បីបម្រើផលប្រយោជន៍ទូទៅ។[23] ត្រង់ន័យនេះ ចង់បញ្ជាក់ថារដ្ឋ ឬ

[20] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២១៩។

[21] សាយ បូរី (២០១២), *នីតិរដ្ឋបាលទូទៅ*, ទំព័រ៤០៣។

[22] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ៦៥។

[23] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២១។

ភ្នាក់ងាររបស់រដ្ឋ ជាអ្នករៀបចំ និងប្រតិបត្តិទៅលើការផ្តល់សេវាសាធារណៈដោយផ្ទាល់ ពាក់ព័ន្ធនឹងប្រភេទនៃចង្កោមបីដែលនឹងត្រូវបកស្រាយនូវចំណុចខាងក្រោម។

**១.៤.១.២-លក្ខណៈសម្បត្តិ**

សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល ត្រូវបានគ្រប់គ្រងដោយរដ្ឋផ្តាច់មុខ។ សេវាសាធារណៈរដ្ឋបាលនេះ គឺជាសកម្មភាពដែលបម្រើដោយផ្ទាល់ និងមិនចំពោះ ហើយដែលសម្រាប់សង្គមជាតិទាំងមូល។ គេឃើញថា សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាលនេះ មាននៅគ្រប់ទីកន្លែងនៃរដ្ឋដូចជានៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិជាដើម។[24]

**១.៤.១.៣-របបគតិយុត្ត និងការគ្រប់គ្រង**

- **របបគតិយុត្ត៖** សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល ជាគោលការណ៍ដែលស្ថិតនៅក្រោមរបបគតិយុត្តនៃនីតិសាធារណៈ ជាពិសេសនីតិរដ្ឋបាលជាមួយនឹងផលវិបាកទាំងឡាយ ដែលទាក់ទងទៅនឹងសេវាខាងវិវាទ។[25] សេវាខាងវិវាទនេះផ្តោតជាសំខាន់ទៅលើវិវាទរដ្ឋបាល[26] ដែលត្រូវបានដោះស្រាយដោយអំណាចយុត្តាធិការរួមមានតុលាការកំពូល សាលាជម្រះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់[27]។
- **ការគ្រប់គ្រង៖** សេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល គឺគ្រប់គ្រងដោយមន្ត្រីរាជការសុទ្ធសាធ ដែលទទួលបានប្រាក់បៀវត្សរ៍ពីរដ្ឋ។[28]

**១.៤.១.៤-ចង្កោមសេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល**

[24] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២១។

[25] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២២។

[26] *វិវាទរដ្ឋបាល* គឺជាវិវាទដែលកើតឡើងរវាងអាជ្ញាធរសាធារណៈ និងប្រជាពលរដ្ឋ ឬរវាងនីតិបុគ្គលសាធារណៈ និងនីតិបុគ្គលសាធារណៈ ឬរវាងនីតិបុគ្គលឯកជន និងនីតិបុគ្គលសាធារណៈ។

[27] មាត្រា១២៨ថ្មី (មាត្រា១០៩ ចាស់) នៃវាក្យខណ្ឌ៣ និង៤ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តក្នុងឆ្នាំ១៩៩៣។

[28] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២២។

នៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រភេទនៃសេវាសាធារណៈត្រូវបានរដ្ឋចងក្រងទៅជាប្រាំពីរចង្កោមធំៗ ដែលក្នុងនោះចង្កោមសេវាទីមួយ ទីពីរ និងទីបី ត្រូវបានចាត់ចូលទៅក្នុងប្រភេទសេវាសាធារណៈដែលមានលក្ខណៈរដ្ឋ។ ចង្កោមសេវាទាំងបីនោះ ត្រូវបានបកស្រាយដូចខាងក្រោម៖[29]

**១-ចង្កោមសេវាពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋ៖** គឺជាសេវាទទួលខុសត្រូវផ្តាច់មុខរបស់រដ្ឋដែលផ្តល់ដោយអង្គភាពរដ្ឋ ឬនីតិបុគ្គលនៃនីតិសាធារណៈ ដែលរដ្ឋបានប្រគល់សិទ្ធិអំណាចដើម្បីអនុវត្ត។ ចង្កោមសេវា ពាក់ព័ន្ធនឹងអធិបតេយ្យភាពរដ្ឋមានដូចជា លិខិតអនុញ្ញាត ឬ អាជ្ញាប័ណ្ណ លិខិតអគ្រានុកូលដ្ឋាន លិខិតចុះបញ្ជីយានយន្ត អាកាសយាន និងនាវាវិញ្ញាប័ណ្ណប័ត្រទទួលស្គាល់ប័ណ្ណកម្មសិទ្ធិ អត្តសញ្ញាណប័ណ្ណសំគាល់ខ្លួនប្រជាពលរដ្ឋខ្មែរ សៀវ ភៅគ្រួសារ និងការធ្វើនីត្យានុកូលកម្មជាដើម។

**២-ចង្កោមសេវាពាក់ព័ន្ធនឹងផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម៖** គឺជាការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច កងនគរបាលជាតិ កងរាជអាវុធហត្ថ និងកងយោធពលខេមរភូមិន្ទគ្រប់លំដាប់ថ្នាក់ទូទាំងប្រទេស។ ចង្កោមសេវានេះ ជាសេវាដ៏ចាំបាច់បំផុត និងមិនអាចខ្វះបានដើម្បីធានាបរិយាកាសល្អដល់ការអភិវឌ្ឍសង្គមជាតិ ការកាត់បន្ថយភាពក្រីក្រ ភាពសុខសាន្តរបស់ប្រជាពលរដ្ឋ និងជាទំនុកចិត្តដល់វិនិយោគិនធុរជន ក្នុងការប្រកបរបរអាជីវកម្ម និងជំនួញជួញដូររបស់ពួកគេ។

**៣-ចង្កោមសេវាពាក់ព័ន្ធនឹងយុត្តិធម៌ និងអាជ្ញាកណ្តាល៖** ចង្កោមនេះកើតមានអរិយភាពឡើង ដែលជាទូទៅគឺរវាងប្រជាពលរដ្ឋ និងប្រជាពលរដ្ឋ ឬប្រជាពលរដ្ឋ និងរាជការ ឬរាជការ និងផ្នែកឯកជន ដោយគិតចាប់តាំងពីសេវាអាជ្ញាកណ្តាលដោះស្រាយវិវាទក្រៅផ្លូវតុលាការ ក្នុងគោលបំណងកាត់បន្ថយការកកស្ទះសំណុំរឿងមួយចំនួននៅតុលាការ ដែលមិនសូវមាន សារៈសំខាន់ និងមិនធ្ងន់ធ្ងរជាដើម។ ភាពជឿទុកចិត្តរបស់ប្រជាពលរដ្ឋ អ្នកប្រើប្រាស់ និងអ្នកពាក់ព័ន្ធទាំងអស់ អាស្រ័យទៅលើការអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធិភាព គុណភាព ភាពសុចរិត យុត្តិធម៌ តម្លាភាពនៅក្នុងបរិបទនៃនីតិរដ្ឋ។ ការវិវត្តនៃចង្កោមសេវានេះ បានឆ្លុះបញ្ចាំងគ្រប់ទិដ្ឋភាពសង្គមជាតិ។ ដូចនេះ រាល់សកម្មភាពកែលំអប្រព័ន្ធ

[29] កៅ មុយចង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ៦៦។

ការងារទាំងអស់ ត្រូវរៀបចំឡើងជាជំហានៗ និងដោយប្រុងប្រយ័ត្នក្នុងទិសដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាកម្មយុត្តិធម៌។

### ១.៤.២-សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម

#### ១.៤.២.១-និយមន័យ

សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម គឺជាសកម្មភាពទាំងឡាយដែលគ្រប់គ្រងដោយនីតិបុគ្គលឯកជនដើម្បីផលប្រយោជន៍ទូទៅ។[30] ក្នុងន័យនេះ ចង់សំដៅដល់ការផ្តល់សេវាសាធារណៈដោយនីតិបុគ្គលឯកជន តាមរយៈការទទួលបានសិទ្ធិពីនីតិបុគ្គលសាធារណៈក្រោមយន្តការនៃការធ្វើកិច្ចសន្យារដ្ឋបាលជាដើម។

#### ១.៤.២.២-លក្ខណសម្បត្តិ

ដើម្បីឲ្យដឹងថាជា សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម លុះត្រាតែសេវានោះចាំបាច់ត្រូវប្រកបសកម្មភាពសេដ្ឋកិច្ច ហើយដែលស្ថិតនៅក្នុងការប្រកួតប្រជែងជាមួយសហគ្រាសឯកជន។ សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម មានលក្ខណៈវិនិច្ឆ័យបីយ៉ាងគឺៈ[31]

- សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម គឺមានសកម្មភាពដូចឯកជន បម្រើផលប្រយោជន៍ទូទៅ ទាញយកផលចំណេញ ហើយចូលរួមក្នុងផ្នែកកសិកម្ម សម្ភារៈប្រើប្រាស់ និងការបំពេញតម្រូវការធ្វើឡើងនៅក្នុងគោលបំណងចូលរួមសកម្មភាពបម្រើផលប្រយោជន៍ទូទៅ។ ប៉ុន្តែ ជាគោលការណ៍ច្បាប់បានកំណត់ថា មិនឲ្យមានការបង្កើត ឬការធ្វើអាជីវកម្មតែក្នុងគោលបំណងហិរញ្ញវត្ថុសុទ្ធសាធនោះទេ។
- ហិរញ្ញកិច្ចរបស់សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម គឺបានមកពីការបង់ថ្លៃឈ្នួលរបស់អ្នកប្រើប្រាស់សេវាជាមួយនឹងការងារដែលបានផ្តល់ឲ្យ។
- សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម គឺជាសកម្មភាពមួយដែលបម្រើប្រយោជន៍ទូទៅ ហើយគេរៀបចំ និងប្រព្រឹត្តទៅតាមរបៀប ប្រព័ន្ធនៃការជ្រើសរើស និងការត្រួតពិនិត្យបុគ្គលិក (លក្ខន្តិកៈនៃនីតិឯកជន) ការចេញសេចក្តីសម្រេច

[30] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២៣។

[31] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២៣។

មិនមានលក្ខណៈជាបទបញ្ញាទូទៅ និងមិនមានសិទ្ធិប្រើប្រាស់កម្លាំងប្រដាប់អាវុធនោះទេ។

ឧទាហរណ៍៖ មិនបង់ថ្លៃទឹក នាំឲ្យរដ្ឋាករទឹកផ្តាច់ប្រព័ន្ធទឹក។

### ១.៤.២.៣-របបគតិយុត្ត និងការគ្រប់គ្រង

- **របបគតិយុត្ត៖** សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម ជាគោលការណ៍ស្ថិតនៅក្រោមរបបគតិយុត្តនៃនីតិឯកជន ជាមួយនឹងផលវិបាកទាំងឡាយដែលទាក់ទងទៅនឹងសេវានេះខាងវិវាទ។ ដូច្នេះ ការដោះស្រាយវិវាទដែលកើតឡើង សមត្ថកិច្ចគឺតុលាការយុត្តិធម៌។[32]
- **ការគ្រប់គ្រង៖** សេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម គឺគ្រប់គ្រងដោយបុគ្គលិករបស់ឯកជន ដែលមិនទទួលបានបៀវត្សរ៍ពីរដ្ឋទេ។[33]

### ១.៤.២.៤-ចង្កោមសេវាសាធារណៈដែលមានលក្ខណៈពាណិជ្ជកម្ម និងឧស្សាហកម្ម

ក្រៅពីចង្កោមសេវាទាំងបីខាងលើ ដែលត្រូវបានចងក្រង និងចាត់បញ្ចូលទៅក្នុងប្រភេទសេវាសាធារណៈដែលមានលក្ខណៈរដ្ឋបាល គឺនៅមានចង្កោមសេវាចំនួនបួនផ្សេងទៀត ដែលរដ្ឋបានពិចារណាថាអាចនឹងប្រគល់ទៅឲ្យវិស័យឯកជន ក្នុងគោលបំណងធានាឲ្យបានថាសេវាសាធារណៈត្រូវតែបម្រើប្រជាពលរដ្ឋឲ្យកាន់តែប្រសើរឡើង។ ចង្កោមនៃសេវាទាំងបួននោះមានដូចជា៖[34]

**១-ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងការថែទាំហេដ្ឋារចនាសម្ព័ន្ធ។**

**ក. ការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម**

នៅក្នុងយន្តការនៃការផ្តល់សេវាសាធារណៈតាមចង្កោមនេះ រាជរដ្ឋាភិបាលចាត់ទុកវិស័យឯកជន ជាក្បាលម៉ាស៊ីនយ៉ាងសំខាន់នៃកំណើនសេដ្ឋកិច្ច សម្រាប់ការអភិវឌ្ឍទៅកិច្ចការពាណិជ្ជកម្ម។ នៅក្នុងនោះ រាជរដ្ឋាភិបាលក៏ជាអ្នករៀបចំយុទ្ធសាស្ត្រ ដើម្បីធ្វើឲ្យបរិស្ថានធុរកិច្ចឲ្យកាន់តែ

[32] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២៥។

[33] ហៀង សាង (២០១១), *នីតិរដ្ឋបាលទូទៅ*, ទំព័រ២២៥។

[34] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ៦៨។

ប្រសើរសម្រាប់វិស័យឯកជន និងជាអ្នកគ្រប់គ្រងការអភិវឌ្ឍ។ ដូចនេះ ដើម្បីទាក់ទាញការវិនិយោគរបស់វិស័យឯកជន ផែនការអាទិភាពជាចម្បង សម្រាប់រដ្ឋ ដែលនឹងត្រូវធ្វើឲ្យប្រសើរឡើងមានដូចជាៈ

- ពង្រឹងអភិបាលកិច្ចល្អទាំងក្នុងវិស័យសាធារណៈ និងវិស័យឯកជន
- បន្ថយរាល់បែបបទស្មុគស្មាញ និងវែងអន្លាយនៅតាមក្រសួង ឬស្ថាប័នពាក់ព័ន្ធដល់ការនាំចេញ និងនាំចូលទំនិញរបស់ក្រុមហ៊ុន
- បំបាត់ចោលនូវភារកិច្ចជាន់គ្នារបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដើម្បីជម្រុញដំណើរការត្រួតពិនិត្យតែមួយកន្លែងឲ្យមានប្រសិទ្ធភាព
- ពង្រឹងការអនុវត្តយន្តការ "ច្រកចេញចូលតែមួយ" នៅតាមបណ្តាច្រកអន្តរជាតិ និង
- លើកឡើងនូវវិធានការចាំបាច់ បម្រើឲ្យការអនុវត្តច្បាប់ បទប្បញ្ញត្តិនានាចំពោះរាល់បាតុភាពអសកម្មដែលប៉ះពាល់ដល់ការងារធុរកិច្ចជាដើម។

**ខ. សហគ្រាសធុនតូច និងមធ្យម**

ចំពោះសហគ្រាសធុនតូច និងមធ្យម រាជរដ្ឋាភិបាលបាននឹងបន្តជម្រុញការអភិវឌ្ឍតាមរយៈការដាក់ចេញនូវគោលនយោបាយដូចខាងក្រោមៈ

- លើកទឹកចិត្តដល់ការរីកលូតលាស់សហគ្រាសធុនតូច និងមធ្យម ជាពិសេស តាមរយៈការផ្តល់ឥណទានរយៈពេលមធ្យម និងរយៈពេលវែង
- ទប់ស្កាត់ការរត់គេចពន្ធគ្រប់ប្រភេទ
- កាត់បន្ថយបែបបទការចុះបញ្ជី និងការរៀបចំដំណើរការក្រុមហ៊ុន
- សម្រួលដល់ការនាំចេញនាំចូលតាមរយៈការកាត់បន្ថយបែបបទស្មុគស្មាញ មានដូចជាថ្លៃសេវាកម្ម ក្នុងការអនុញ្ញាតដំណើរការផលិតកម្មវិស័យឧស្សាហកម្មធុនតូច និងមធ្យមតាមច្រកចេញចូលតែមួយ
- ផ្តល់ការគាំពារដល់ឧស្សាហកម្មមួយចំនួនក្នុងរយៈពេលមួយសមស្រប និង
- ជម្រុញសម្ព័ន្ធភាពសហគ្រាសធុនតូច និងមធ្យមជាមួយនឹងឧស្សាហកម្មធុនធំជាដើម។

នៅក្នុងនោះផងដែរ ដើម្បីសម្រេចបានការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមដោយជោគជ័យ រាជរដ្ឋាភិបាលត្រូវៈ

- ជម្រុញការលើកទឹកចិត្តចំពោះឧស្សាហកម្មផលិតទំនិញ បម្រើទីផ្សារក្នុងស្រុក ឬឧស្សាហកម្មផលិតទំនិញ ជំនួសការនាំចេញ ដើម្បីឆ្លើយតបទៅនឹងសំណូមពរជាយុទ្ធសាស្ត្រនៃការបង្កើតមូលដ្ឋានផលិតកម្មទំនិញក្នុងប្រទេសឲ្យបានច្រើន ជាពិសេសនៅយុគសម័យនៃតំបន់ភាវូបនីយកម្ម និងសកលភាវូបនីយកម្ម
- កំណត់គោលនយោបាយលើកទឹកចិត្ត និងគាំទ្រសហគ្រាសធុនតូច និងមធ្យម
- រៀបចំយុទ្ធសាស្ត្រ បង្កើនសមត្ថភាពប្រកួតប្រជែង សម្រាប់សហគ្រាសធុនតូច និងមធ្យម
- រៀបចំផែនការសកម្មភាព ជម្រុញ និងគាំទ្រសហគ្រាសធុនតូច និងមធ្យម ព្រមទាំងតាមដាន និងត្រួតពិនិត្យការអនុវត្ត
- ជម្រុញការរៀបចំបទបញ្ញត្តិនានា ស្តីពីការគ្រប់គ្រងសហគ្រាសធុនតូច និងមធ្យម និង
- អនុវត្តតួនាទីផ្សេងទៀតដែលពាក់ព័ន្ធដល់ការជម្រុញ និងគាំទ្រសហគ្រាសធុនតូច និងមធ្យម។

**គ. បរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជន ក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ**

ពាក់ព័ន្ធនឹងការងារនេះ រាជរដ្ឋាភិបាលមានគោលដៅលើកឡើងនូវវិធានការចាំបាច់បម្រើឲ្យការពង្រឹង និងកែលំអបរិស្ថានវិនិយោគ និងធុរកិច្ច និងលើកគោលនយោបាយលើកទឹកចិត្ត ព្រាង ឬនិងពិនិត្យសេចក្តីព្រាងរាល់លិខិតបទដ្ឋានសម្រាប់ណែនាំ និងជម្រុញការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងរៀបចំបញ្ជីគម្រោងហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទដែលទាមទារការចូលរួមពីសំណាក់ផ្នែកឯកជន។

ចង្កោមសេវាពាក់ព័ន្ធនឹងការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូច និងមធ្យម និងបរិស្ថានវិនិយោគ និងការចូលរួមផ្នែកឯកជនក្នុងការកសាង និងថែទាំហេដ្ឋារចនាសម្ព័ន្ធ ត្រូវចាប់ផ្តើមដំណើរការការធ្វើកំណែទម្រង់ឲ្យបានឆាប់រហ័សទៅតាមស្ថានភាពជាក់ស្តែង និងធនធានដែលមាននូវរចនាសម្ព័ន្ធ និងផ្នែកពាក់ព័ន្ធទាំងឡាយណា ដែលមិនទាន់អាចឆ្លើយតបបានទៅនឹងតម្រូវការជាចាំបាច់នៃការសម្រួលដល់ការធ្វើអាជីវកម្ម ការវិនិយោគទុន និងការអភិវឌ្ឍផ្នែកឯកជន។

**២-ចង្កោមសេវាសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី**

ចង្កោមសេវានេះរួមមាន សេវាអប់រំ (លើកកម្ពស់គុណភាពសេវាអប់រំសម្រាប់ទាំងអស់គ្នា សម្ភារៈសិក្សាគ្រប់គ្រាន់ និងសិទ្ធិទទួលបានសេវាអប់រំនៅគ្រប់កម្រិតសិក្សា) សេវាសុខភាពអនាម័យ (បង្កលក្ខណៈងាយស្រួល គុណភាព ប្រសិទ្ធិភាព ដើម្បីផ្គត់ផ្គង់សេវាសុខាភិបាលមូលដ្ឋានប្រកបដោយសមធម៌ និងនិរន្តរភាពជូនប្រជាពលរដ្ឋគ្រប់រូប ជាពិសេសជនក្រីក្រ និងក្រុមជនងាយរងគ្រោះ) សេវាសម្រាប់ការកំសាន្ត សេវាសង្គមកិច្ច សេវាគាំពារកុមារកំព្រា កុមារងាយរងគ្រោះ ជនពិការ សេវាលើកស្ទួយ និងការចូលរួមរបស់ស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាដើម និងសេវាដទៃទៀតដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ។

**៣-ចង្កោមសេវាពាក់ព័ន្ធនឹងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

ការផ្ដល់សេវានៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាអាទិភាពចម្បងរបស់រាជរដ្ឋាភិបាលដើម្បីជម្រុញ និងបង្កើនល្បឿនកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ត្រូវផ្តោតជាសំខាន់លើការបន្តការសាងសងប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តគ្រប់ប្រភេទ រួមមានផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងអាកាសយានដ្ឋានដែលអាចតភ្ជាប់ក្រុង ជនបទ និងគ្រប់ទីកន្លែងទូទាំងប្រទេស កសាងមន្ទីរពេទ្យ សាលារៀន អណ្តូងទឹក ប្រព័ន្ធទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ អគ្គិសនី ថាមពល បច្ចេកវិទ្យាពត៌មាន ប្រៃសណីយ៍ និងទូរគមនាគមន៍។ល។ ពាក់ព័ន្ធនឹងចង្កោមសេវានេះ រាជរដ្ឋាភិបាលមានគោលនយោបាយលើកទឹកចិត្តឲ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់របស់ជាតិ ជាពិសេសផ្នែកឯកជនក្នុងការកសាង និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តដែលជាកត្តាចាំបាច់មួយក្នុងការអភិវឌ្ឍប្រទេសជាតិ។

**៤-ចង្កោមសេវាពាក់ព័ន្ធនឹងការប្រមូលចំណូល ការចំណាយ និងការបើកផ្តល់**

ចង្កោមសេវានេះ ពាក់ព័ន្ធនឹងការកែលំអការគ្រប់គ្រងចំណូល ចំណាយ និងការបើកផ្តល់នីតិវិធីនៃការបង់ពន្ធ ការប្រមូលចំណូល និងការបើកផ្តល់ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងមិនបង្កការលំបាកដល់អ្នកបង់ពន្ធជាដើម។

## ១.៥-គោលដៅនៃសេវាសាធារណៈ

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងការផ្តល់សេវាសាធារណៈ គឺដើម្បី "បម្រើប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរឡើង"។[35] ដូចនេះ ការកែលំអការផ្តល់សេវាសាធារណៈ ដូចមានចែងក្នុងគោលនយោបាយនេះ និងកម្មវិធីយុទ្ធសាស្ត្រដទៃទៀតរបស់រដ្ឋាភិបាល ត្រូវរៀបចំឡើងឲ្យស្របទៅនឹងគោលដៅ និងចក្ខុវិស័យនៃការរៀបចំកែលំអការគ្រប់គ្រង កិច្ចដំណើរការបែបបទ នីតិវិធីនៃការផ្តល់សេវាសាធារណៈ និងឥរិយាបថ អត្តចរិត ការយល់ដឹងរបស់មន្ត្រីរាជការ និងភ្នាក់ងាររដ្ឋដែលបម្រើការងារនៅក្នុងផ្នែកនេះ ព្រមទាំងផ្តោតការយកចិត្តទុកដាក់ចំពោះការទទួលយកសេវាសាធារណៈគ្រប់ប្រភេទរបស់រដ្ឋទៅប្រើប្រាស់ពីសំណាក់ប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់។

គោលដៅជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលមានដូចខាងក្រោម៖[36]

**១-ធានាភាពងាយស្រួលក្នុងការទទួលយកសេវាទៅប្រើប្រាស់** ផ្តល់សេវាពត៌មានគ្រប់គ្រាន់ច្បាស់លាស់ និងងាយយល់ កាត់បន្ថយការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញសំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវាក្នុងការស្វែងរកសេវាដោយខ្លួនឯង និងចំណាយបន្ថែមទៅលើអ្នករត់ការក្រៅផ្លូវការ។

**២-ផ្តោតទៅលើតម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា** កន្លងមក មន្ត្រីរាជការក្នុងឥរិយាបថជាអ្នកគ្រប់គ្រង បានកំណត់ជាស្រេចនូវប្រភេទសេវាដែលត្រូវផ្តល់ជូនអ្នកប្រើប្រាស់ទោះជាសេវាមួចំនួនអ្នកប្រើប្រាស់មិនត្រូវការក៏ដោយ។ ប៉ុន្តែ ក្នុងឥរិយាបថជាអ្នកផ្តល់សេវា គឺត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់ទីផ្សារ និងរបស់អ្នកប្រើប្រាស់វិញ។

**៣-ផ្តល់សេវាឲ្យចំទីកន្លែងនៃតម្រូវការរបស់អ្នកប្រើប្រាស់សេវា** រដ្ឋបាលសាធារណៈ ត្រូវផ្តល់សេវាដល់កន្លែងដែលអ្នកប្រើប្រាស់ត្រូវការ លើកលែងតែក្នុងករណីពិសេសមួយចំនួន ដែលមិនអាចផ្គត់ផ្គង់បាន ឧទាហរណ៍ សេវារះកាត់បេះដូងដែលបច្ចុប្បន្ននេះមានតែមួយកន្លែងគត់នៅរាជធានីភ្នំពេញ។ ក្នុងន័យនេះ រដ្ឋបាលសាធារណៈ ត្រូវតែបង្វិតឲ្យនៅជិតប្រជាពលរដ្ឋ ដើម្បី

[35] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ២១។

[36] ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ២១។

សម្រួលការទទួលយកសេវាទៅប្រើប្រាស់។ ឧទាហរណ៍ៈ បើអ្នកប្រើប្រាស់ត្រូវការប្រភេទសេវាណាមួយនៅតំបន់ណាមួយ យើងត្រូវកំណត់ឲ្យមានសេវាប្រភេទនោះ នៅតំបន់នោះតែម្តង មិនត្រូវឲ្យអ្នកប្រើប្រាស់រកសេវានោះនៅភ្នំពេញទេ។

**៤-ត្រូវមានតម្លាភាព និងការទទួលខុសត្រូវក្នុងការផ្តល់សេវា** អ្នកផ្តល់សេវា ត្រូវផ្តល់ពត៌មានឲ្យបានទូលំទូលាយ ជាជំហរដោយគ្មានការរើសអើង និងយកចិត្តទុកដាក់ផ្តល់សេវាឲ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាពជូនអ្នកប្រើប្រាស់ដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនឹងនោះ អ្នកផ្តល់សេវាក៏ត្រូវទុកលទ្ធភាពឲ្យអ្នកប្រើប្រាស់តាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្តល់សេវា និងអាចធ្វើការទិទៀន តវ៉ា ឬទាមទារឲ្យមានការកែលំអការខ្វះខាតផ្សេងៗតាមតម្រូវការសំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ។

**៥-គុណភាព និងប្រសិទ្ធភាពនៃសេវា** អ្នកផ្តល់សេវា មានន័យថាអ្វីដែលបានកំណត់ជូនអ្នកប្រើប្រាស់ត្រូវតែធ្វើឲ្យបានទៅតាមការកំណត់នោះ ទាំងតម្លៃ ទាំងពេលវេលា និងគុណភាព។ គុណភាពនៃសេវា ត្រូវបានកំណត់ផ្អែកទៅលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវា នៅពេលដែលសេវាត្រូវផ្តល់ជូននោះឆ្លើយតបនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។

## ១.៦-យន្តការនៃការអនុវត្តក្នុងការផ្តល់សេវាសាធារណៈ

សម្រាប់ការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា រាជរដ្ឋាភិបាលបានកំណត់យកយន្តការនៃការផ្តល់សេវាតាមវិធីសាស្ត្រផ្សេងៗ ក្នុងគោលបំណងជួយសម្រួលការងារទៅដល់ដំណើរការកែលំអ និងការបង្កើតស្តង់ដារនៃការផ្តល់សេវារបស់ក្រសួងនីមួយៗ។ យន្តការនៃការផ្តល់សេវានេះ អាចនឹងត្រូវបានកែប្រែ ប្រសិនបើកាលៈទេសៈ និងទិដ្ឋភាពជាក់ស្តែងនៃរដ្ឋបាលសាធារណៈនៅកម្ពុជាមានការប្រែប្រួលដោយប្រការណាមួយ។ យន្តការនៃការផ្តល់សេវាសាធារណៈនៅកម្ពុជាត្រូវបានដំណើរការតាមជម្រើសដូចខាងក្រោមៈ[37]

### ១.៦.១-ការកែលំអកិច្ចដំណើរការការងារនៃការផ្តល់សេវាសាធារណៈ

វាជាយន្តការមូលដ្ឋានមួយ ដែលត្រូវបង្កើតឡើងដើម្បីកែលំអការផ្តល់សេវាសាធារណៈដែលកំពុងដំណើរការនៅតាមក្រសួងស្ថាប័ន និងភ្នាក់ងាររបស់រដ្ឋទាំងអស់ តាមរយៈការលុបចោលនូវ

[37] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៣៣។

ភាពជាន់គ្នា ឬភាពមិនច្បាស់លាស់នៃភារកិច្ច និងនីតិវិធីដែលមិនចាំបាច់។ ការងារនេះត្រូវផ្ដោតទៅលើនីតិវិធី អភិក្រម ពេលវេលា តម្លៃនៃការចំណាយ ប្រសិទ្ធភាព ជំនឿទុកចិត្ត និងគុណភាពនៃសេវាសាធារណៈដែលអ្នកប្រើប្រាស់បានទទួល។[38]

វិធីសាស្ត្រដើម្បីឈានទៅសម្រេចគោលដៅនេះ ត្រូវបានរៀបចំ និងអនុវត្តដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងក្រសួងស្ថាប័នមួយចំនួន។ ការងារនេះ ត្រូវបញ្ចូលរួមទាំងការរៀបចំនូវការបណ្ដុះបណ្ដាលមន្ត្រីរាជការដែលមានមុខងារ និងភារកិច្ចទទួលអនុវត្តនូវវិធីសាស្ត្រ ឬយន្តការដែលរៀបចំឡើងនេះ។

### ១.៦.២-ច្រកចេញចូលតែមួយ

ច្រកចេញចូលតែមួយ ជាយន្តការនៃការផ្ដល់សេវាសាធារណៈមួយ ដែលបង្កភាពងាយស្រួលដល់អ្នកប្រើប្រាស់តាមនីតិវិធីសាមញ្ញ មានតម្លាភាព ប្រសិទ្ធភាព និងយកចិត្តទុកដាក់ចំពោះការផ្ដល់យោបល់ និងការចាប់អារម្មណ៍របស់អ្នកប្រើប្រាស់សេវា។ យន្តការនេះប្រមូលផ្ដុំជាចង្កោមនូវសេវាសាធារណៈមួយចំនួន ឲ្យមកនៅកន្លែងតែមួយ ទាំងកន្លែងស្នើសុំ និងកន្លែងទទួល ដោយកំណត់ពេលវេលាប្រគល់សេវា និងកំណត់តម្លៃច្បាស់លាស់។ ការផ្ដល់សេវាសាធារណៈតាមយន្តការការិយាល័យច្រកចេញចូលតែមួយ ត្រូវរៀបចំឡើងដោយកំណត់តួនាទី ភារកិច្ច និងដែនសមត្ថកិច្ចឲ្យបានច្បាស់លាស់។ ក្រៅពីនេះ ក៏មានរៀបចំផងដែរនូវការរៀបចំ និងការប្រព្រឹត្តទៅក្របខ័ណ្ឌ គោលការណ៍ នីតិវិធី និងរចនាសម្ព័ន្ធនៃការផ្ដល់សេវាតាមយន្តការការិយាល័យច្រកចេញចូលតែមួយ ដែលត្រូវធ្វើឡើងតាមការសម្រេចរបស់រាជរដ្ឋាភិបាល។

សម្រាប់ប្រទេសកម្ពុជា ការផ្ដល់សេវាសាធារណៈតាមច្រកចេញចូលតែមួយនេះ បានដាក់ឲ្យអនុវត្តជាដំបូងបង្អស់ តាមរយៈគម្រោងសាកល្បងនៅស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបងដោយចាប់ផ្ដើមអនុវត្តចាប់ពីឆ្នាំ២០០៤ យោងតាមសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ៤៧សសរ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ ស្ដីពីរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងស្រុកសៀមរាបនៃខេត្តសៀមរាប និងស្រុកបាត់ដំបងនៃខេត្តបាត់ដំបង។ នៅក្នុងនោះគោល បំណងសំខាន់នៃការអនុវត្តគម្រោងនេះ គឺការសាកល្បងអនុវត្តកំណែទម្រង់រដ្ឋបាលនៅ

[38] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្ដីពីការផ្ដល់សេវាសាធារណៈ*, ទំព័រ៣៤។

ស្រុកទីប្រជុំជនក្នុងការបង្កើតជាមណ្ឌលអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចឲ្យមានតុល្យភាព និងចូលរួមកាត់បន្ថយភាពក្រីក្រ។[39]

**១.៦.៣-វិសហមជ្ឈការសេវាសាធារណៈ**

វិសហមជ្ឈការសេវាសាធារណៈ គឺជាយន្តការមួយនៃការផ្តល់សេវាសាធារណៈក្នុងកម្រិតនៃអំណាចគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិតាមប្រព័ន្ធរដ្ឋបាលឯកភាព ដូចដែលមានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។ ក្នុងន័យខាងលើនេះចង់បញ្ជាក់ថា រដ្ឋបាលកណ្តាលចែករំលែកអំណាច និងការទទួលខុសត្រូវមួយចំណែកទៅឲ្យរដ្ឋបាលមូលដ្ឋាន តាមរយៈការធ្វើប្រតិភូកម្ម ឬការប្រគល់អំណាច ដោយមានកម្រិតព្រំដែនសមត្ថកិច្ច[40] ក្នុងគោលបំណងជួយជម្រុញកិច្ចសម្របសម្រួលរាល់សកម្មភាពរដ្ឋបាលសាធារណៈ នៅរដ្ឋបាលមូលដ្ឋាន សំដៅជម្រុញកិច្ចអភិវឌ្ឍន៍ និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបតាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

**១.៦.៤-វិមជ្ឈការសេវាសាធារណៈ**

វិមជ្ឈការសេវាសាធារណៈ គឺជាយន្តការក្នុងការផ្តល់សេវាសាធារណៈមួយ ដែលអនុវត្តដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១។ នៅក្នុងន័យនេះ រដ្ឋបាលកណ្តាលផ្ទេរអំណាចទៅឲ្យរដ្ឋបាលមូលដ្ឋាន ដែលនៅក្នុងអំណាចនេះ មានលក្ខណៈពិសេសបីគឺ បុគ្គលភាពគតិយុត្ត សមត្ថកិច្ចផ្ទាល់ និងការទទួលបានស្វ័យភាពកំណត់[41] ពោលគឺរដ្ឋ ឬរដ្ឋបាលកណ្តាលមិនអាចចូលធ្វើអន្តរាគមន៍បាននោះទេ ក្រោយពេលរដ្ឋបាលមូលដ្ឋានទទួលបានសមត្ថកិច្ចដែលកំណត់ដោយច្បាប់ ឬមានការឯកភាពពីរដ្ឋ។ នៅក្នុងនោះ រដ្ឋបាលកណ្តាលអាចប្រើអំណាចរបស់ខ្លួនដើម្បីពិនិត្យក្នុងនាមជាអាណាព្យាបាល ឬតាមរយៈស្ថាប័នតុលាការតែប៉ុណ្ណោះ។

---

[39] យ៉ន សារ៉េត និង ក. យឹម វណ្ណឌីម៉ង់ (២០១៥), សារណាបញ្ចប់ការសិក្សា៖ *ការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ*, ទំព័រ១៦។

[40] ខាំ សុមករា (២០០៣), *រដ្ឋបាលសាធារណៈ*, ទំព័រ៧១។

[41] ខាំ សុមករា (២០០៣), *រដ្ឋបាលសាធារណៈ*, ទំព័រ៧៣។

### ១.៦.៥-គ្រឹះស្ថានសាធារណៈរដ្ឋបាល

គ្រឹះស្ថានសាធារណៈរដ្ឋបាល ជាយន្តការនៃការផ្តល់សេវាសាធារណៈមួយផ្សេងទៀតដែលមានស្វ័យភាពខាងហិរញ្ញវត្ថុ ឬរដ្ឋបាល និងជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកជាចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈជាលក្ខណៈរដ្ឋបាល សង្គម សុខាភិបាល វប្បធម៌ វិទ្យាសាស្ត្រ ឬបច្ចេកទេស។[42]

ក្នុងក្របខណ្ឌនេះ គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជា ត្រូវមានលក្ខណៈសម្បត្តិជារួមដូចតទៅ៖[43]

១-នាមករណ៍ និងទីស្នាក់ការ

២-មានកម្មវត្ថុដែលកំណត់អំពីប្រភេទសកម្មភាព

៣-មានក្រុមប្រឹក្សាភិបាលដើម្បីដឹកនាំគ្រប់គ្រងដំណើរការ និងការគ្រប់គ្រងដោយឡែក

៤-មានថវិកាផ្ទាល់ខ្លួន

៥-មានទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាព ដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល

៦-មានសមត្ថភាពចុះកិច្ចសន្យា និងប្តឹង ឬការពារខ្លួននៅចំពោះមុខច្បាប់ និងតុលាការ និង

៧-ទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី លើទង្វើរបស់អ្នកតំណាងស្របច្បាប់ ឬនិយោជិតរបស់ខ្លួន ក្នុងពេលបំពេញការងារជូនគ្រឹះស្ថាន។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺមិនមានចែងអំពីវិធីសាស្ត្រនៃការបង្កើតគ្រឹះស្ថានសាធារណៈរដ្ឋបាលនោះទេ ពោលគឺពេលខ្លះត្រូវបានបង្កើតឡើងដោយច្បាប់ ឬព្រះរាជក្រឹត្យ និងអនុក្រឹត្យ ដែលមានលក្ខណៈខុសពីគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅក្នុងប្រទេសបារាំងដែលត្រូវបង្កើតឡើងដោយច្បាប់តែប៉ុណ្ណោះ។[44] នៅក្នុងនោះ គ្រឹះស្ថានសាធារណៈរដ្ឋបាលនៅប្រទេសកម្ពុជា ត្រូវបានកំណត់ ជាពិសេសនូវបេសកកម្ម បុព្វសិទ្ធិ កាតព្វកិច្ច សមាសភាពនៃក្រុមប្រឹក្សា

---

[42] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៣៨។

[43] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៣៩។

[44] កៅ មុយថង (២០០៧), *រដ្ឋបាលសាធារណៈទំនើប*, ទំព័រ១៨០។

ភិបាល ព្រមទាំងវិធានពិសេសសម្រាប់អនុវត្តក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យលើគ្រឹះស្ថាន និង ត្រូវបញ្ជាក់ផងដែរនូវក្រសួង ឬអាជ្ញាធរអាណាព្យាបាល។[45] ឧទាហរណ៍៖ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAS) ត្រូវបានបង្កើតឡើងក្រោមព្រះរាជក្រឹត្យលេខ ១៧៧ នាថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០០០ ក្នុងគោលបំណងគ្រប់គ្រង និងតាមដានសម្របសម្រួលវិស័យសកម្មភាពមីននៅកម្ពុជា តាមរយៈការប្រគល់ភារកិច្ចទៅដល់ប្រតិបត្តិករដោះមីនជាអ្នកទទួលខុសត្រូវ និងរៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារផ្សេងៗទៀត ដោយអាជ្ញាធរមីនដើម្បីសម្រេចបាននូវផែនការអាទិភាពនានាដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ជាដើម[46]។

ក្រៅពីអាជ្ញាធរកំចាត់មីនកម្ពុជា អាជ្ញាធរអប្សរា រាជបណ្ឌិត្យសភាកម្ពុជា សាលាភូមិន្ទរដ្ឋបាល សាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា សាកលវិទ្យាល័យជាតិគ្រប់គ្រង និង អាជ្ញាធរអគ្គិសនីកម្ពុជា...ជាដើម គឺត្រូវបានចាត់បញ្ចូលទៅក្នុងគ្រឹះស្ថានសាធារណៈរដ្ឋបាលនៅកម្ពុជា។

### ១.៦.៦-សហគ្រាសសាធារណៈ

សហគ្រាសសាធារណៈ ជាយន្តការផ្តល់សេវាសាធារណៈរបស់រដ្ឋដែលស្ថិតក្រោមការគ្រប់គ្រងនៃនីតិឯកជន និង នីតិសាធារណៈ និងជានីតិបុគ្គលដែលមានស្វ័យភាពហិរញ្ញវត្ថុ ហើយដែលមានដើមទុនទាំងអស់ ឬភាគច្រើនជារបស់រដ្ឋ។ បេសកកម្មរបស់សហគ្រាសសាធារណៈ គឺបង្កឲ្យមានលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម មានជាអាទិ៍ការបង្កើនតម្លៃ ធនធានធម្មជាតិ និងការបង្កើតអាជីព។[47]

សហគ្រាសសាធារណៈ មានទម្រង់ជា៖[48]

- គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច
- ក្រុមហ៊ុនរដ្ឋ

[45] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៥០។

[46] អំពីអាជ្ញាធរមីន, www.cmaa.gov.kh/background/background

[47] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៥១។

[48] មាត្រា៣, *ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ*, ដាក់ឲ្យអនុវត្តនាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦។

- ក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលលើសពីហាសិបមួយភាគរយនៃដើមទុនក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត។

សហគ្រាសសាធារណៈ ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួងស្ថាប័ន ឬអាជ្ញាធរសាធារណៈមួយ អាស្រ័យលើប្រភេទនៃកម្មរបស់សហគ្រាសនោះ។

**ក. គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច**

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ជានីតិបុគ្គលនៃនីតិសាធារណៈដែលមានស្វ័យភាពហិរញ្ញវត្ថុ។ គ្រឹះស្ថាននេះ ផលិតទំនិញ និងសេវាសម្រាប់បម្រើទីផ្សារ។ [49]

គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងតាមការសម្រេចរបស់រាជរដ្ឋាភិបាល (អនុក្រឹត្យ) តាមការស្នើរួមគ្នារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន អាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ នៅក្នុងការសម្រេចត្រូវមានកំណត់ ជាអាទិ៍អំពីភារកិច្ច ដើមទុន ក្រសួងស្ថាប័នអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល សមាសភាពក្រុមប្រឹក្សាភិបាល ការរៀបចំរដ្ឋបាល និងហិរញ្ញវត្ថុ វិធាននៃការប្រព្រឹត្តទៅរបស់គ្រឹះស្ថាន។ ក្រៅពីនេះគ្រឹះស្ថានសា- ធារណៈនេះ ជានីតិបុគ្គលដែលមានលក្ខណៈចម្រុះ ពោលគឺមានបុព្វសិទ្ធិសាធារណៈផង (ស្ថិតនៅក្រោមនីតិសាធារណៈ) និងមានកម្មវត្ថុធ្វើឧស្សាហកម្ម និងពាណិជ្ជកម្មផង (ស្ថិតនៅក្រោមនីតិឯកជន)។[50]

ឧទាហរណ៍៖ គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ (គ.ប.ច) ជាគ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ចមួយ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួងអប់រំយុវជន និងកីឡា និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅក្នុងនោះ គ្រឹះស្ថានសាធារណៈនេះ មានទិសដៅធ្វើអាជីវកម្ម និងបោះពុម្ពផ្សាយដូចខាងក្រោម៖[51]

- បោះពុម្ពផ្សាយសៀវភៅសិស្ស និងសៀវភៅគ្រូ ដែលមានគុណភាពក្នុងការរៀន និងការបង្រៀនគ្រប់មុខវិជ្ជានៅបឋមសិក្សា និងមធ្យមសិក្សា

[49] មាត្រា២៦, *ច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ*, ដាក់ឲ្យអនុវត្តនាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦។

[50] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ៨៥។

[51] មាត្រា២, អនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ *ស្ដីពីការបង្កើត គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយ*។

- បោះពុម្ពផ្សាយសៀវភៅអានបន្ថែម សៀវភៅលំហាត់សម្រាប់សិស្ស ព្រមទាំងសៀវភៅសម្រាប់បណ្តុះបណ្តាលគ្រូ ទស្សនាវដ្តីផ្សេងៗ ដែលទាក់ទងនឹងវិស័យអប់រំ និងវិស័យសុខាភិបាល។ល។
- អភិវឌ្ឍ និងផលិតសម្ភារៈឧបទេសងាយៗ សម្រាប់ជំនួយដល់គ្រូ ក្នុងការបង្រៀន
- ទទួលសេវាបោះពុម្ពឯកសារផ្សេងៗ ដែលបម្រើផលប្រយោជន៍សាធារណៈ
- ទទួលសេវាដឹកជញ្ជូនសៀវភៅដល់សាលារៀន និង
- រៀបចំបណ្តាញលក់សៀវភៅសិក្សាគ្រប់ប្រភេទ ដល់គ្រប់ខេត្ត-ក្រុង និងសាលារៀន។

**ខ. ក្រុមហ៊ុនរដ្ឋ**

ក្រុមហ៊ុនរដ្ឋ គឺជាក្រុមហ៊ុនដែលមានដើមទុនទាំងអស់ជារបស់រដ្ឋ។[52] ក្នុងនោះ ក្រុមហ៊ុនរដ្ឋក៏ជាយន្តការមួយផងដែរក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងអ្នកប្រើប្រាស់ដើម្បីធ្វើការប្រកួតប្រជែង នៅក្នុងបរិស្ថានទីផ្សារសេដ្ឋកិច្ច ហើយដែលរដ្ឋអាចដំណើរការទៅបានដោយខ្លួនឯង បន្ទាប់ពីត្រូវបានបង្កើតឡើងដោយការសម្រេចរបស់រាជរដ្ឋាភិបាល (តាមរយៈអនុក្រឹត្យ) តាមការស្នើររួមគ្នាពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងស្ថាប័នអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល។ នៅក្នុងការសម្រេចនេះ ត្រូវបានកំណត់ជាអាទិ៍អំពីកម្មវត្ថុរបស់ក្រុមហ៊ុន ទម្រង់គតិយុត្ត ក្រសួងស្ថាប័នអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាល របបត្រួតពិនិត្យដែលត្រូវអនុវត្តសមាសភាពរបស់ក្រុមប្រឹក្សាភិបាល។

ក្រសួងអាណាព្យាបាល ឬអាជ្ញាធរអាណាព្យាបាលបច្ចេកទេស ទទួលខុសត្រូវបំពេញទម្រង់បែបបទនៃការបង្កើតក្រុមហ៊ុនដោយៈ

- រៀបចំលក្ខន្តិកៈរបស់ក្រុមហ៊ុន ដោយមានការព្រមព្រៀងជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ចាត់ចែងចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង
- បំពេញទម្រង់បែបបទទាំងអស់តាមគោលការណ៍ និងបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម។

[52] មាត្រា៣០, *ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ*, ដាក់ឲ្យអនុវត្តនាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦។

ឧទហរណ៍៖ កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ជាសហគ្រាសសាធារណ:មួយ ដែលត្រូវបានចាត់បញ្ចូលទៅក្នុងក្រុមហ៊ុនរដ្ឋ ដែលស្ថិតក្រោមអាណាព្យាបាលក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ នៅក្នុងនោះ កំពង់ផែស្វយ័តក្រុងព្រះសីហនុ មានភារកិច្ចធ្វើអាជីវកម្ម-សេវាកម្មលើការងារដូចជា[53]៖

- កណ្ណធារកិច្ច នាំនាវាចេញ-ចូល និងផ្តល់ភស្តុភាដល់នាវា
- លើកដាក់ផ្ទេរ-ផ្ទុក និងដឹកជញ្ជូនទំនិញ
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំង ទីលាន និង
- ការងារអភិវឌ្ឍ និងស្តារហេដ្ឋារចនាសម្ព័ន្ធដែល ក.ស.ស មាន។

**គ. ក្រុមហ៊ុនចំរុះ**

ក្រុមហ៊ុនចំរុះ ជាក្រុមហ៊ុនដែលត្រូវបានបង្កើតឡើងតាមគោលការណ៍ និងតាមបែបបទទាំងឡាយនៃនីតិក្រុមហ៊ុនពាណិជ្ជកម្ម ហើយដែលដើមទុនត្រូវកាន់កាប់រួមដោយនីតិបុគ្គល ឬរូបវន្តបុគ្គល បុគ្គលឯកជន និងនីតិបុគ្គលរដ្ឋ។[54] ក្រុមហ៊ុនចំរុះនេះត្រូវបានចាត់បញ្ចូលទៅក្នុងសហគ្រាសសាធារណ: លុត្រាតែភាគកម្មលាភសាធារណ:លើសពី៥១ភាគរយ នៃដើមទុន ឬសិទ្ធិបោះឆ្នោត។

ឧទាហរណ៍៖ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (ផ.ម.ក) ជាក្រុមហ៊ុនចំរុះនៃសហគ្រាសសាធារ-ណ:មួយ ដែលមានបេសកម្មក្នុងការផ្តល់សេវាសាធារណ:នៅកម្ពុជា។ ក្រុមហ៊ុនចំរុះនេះ ត្រូវបានចុះអនុស្សារណ:រវាងក្រុមរាជរដ្ឋាភិបាលកម្ពុជា តំណាងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX) ក្រោមកិច្ចព្រមព្រៀងមួយស្តីពីការបង្កើតក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដែលប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។ នៅក្នុងនោះ ភាគហ៊ុននៃក្រុមហ៊ុនចំរុះគឺ ៥៥% កាន់កាប់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលតំណាងឲ្យរាជរដ្ឋាភិបាលកម្ពុជា និង៤៥% ផ្សេងទៀតកាន់កាប់ដោយក្រុមហ៊ុនផ្សារមូលបត្រកូរ៉េ (KRX)។[55]

[53] មាត្រា២, អនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ *ស្តីពីការបង្កើតកំពុងផែស្វយ័តក្រុងព្រះសីហនុ*។

[54] មាត្រា៣៧, *ច្បាប់ស្តីពីលក្ខន្តិក:ទូទៅនៃសហគ្រាសសាធារណ:*, ដាក់ឲ្យអនុវត្តនាថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦។

[55] សុន្ទរកថារបស់ឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណ:កម្មការមូលបត្រកម្ពុជា និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា, ១១ កក្កដា ២០១១។

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានចក្ខុវិស័យ និងបេសកកម្មដូចខាងក្រោម[56]៖

- ដើម្បីសម្របសម្រួលក្នុងការកៀរគរមូលធនរបស់ក្រុមហ៊ុននៅកម្ពុជា
- ដើម្បីបង្កើតនូវបរិយាកាសជួញដូរមូលបត្រដែលអំណោយផលដល់អ្នកវិនិយោគិនទាំងក្នុង និងក្រៅប្រទេស
- ដើម្បីបង្កើតនូវផលិតផល និងសេវាកម្មដ៏ទំនើបជាច្រើនប្រភេទសម្រាប់អ្នកចូលរួមទីផ្សារទាំងអស់ និង
- ដើម្បីដាក់ឲ្យដំណើរការនូវសហគ្រាសសាធារណៈមួយដែលមានស្វ័យចីរភាពក្រោមមគ្គុទេសក៍ដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ២.៦.៧-កិច្ចសន្យា

កិច្ចសន្យា គឺជាយន្តការមួយនៃការផ្តល់សេវាសាធារណៈ ក្នុងពេលដែលរដ្ឋពុំទាន់មានលទ្ធភាពគ្រប់គ្រាន់ក្នុងការដាក់ឲ្យដំណើរការនូវការផ្តល់សេវា ស្របទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់ ដែលសំដៅពង្រឹងប្រសិទ្ធភាពការងារ លើកកម្ពស់គុណភាពសេវា ដើម្បីទទួលបាននូវទំនុកចិត្តពីអ្នកប្រើប្រាស់សេវា។ រាល់ការសម្រេចដាក់ឲ្យដំណើរការផ្តល់សេវាសាធារណៈតាមយន្តការនៃការបង្កើតកិច្ចសន្យានេះ ត្រូវធ្វើឡើងតាមគំនិតផ្តួចផ្តើមរបស់ក្រសួង ស្ថាប័នសាមី និងដោយមានការយល់ព្រមពីរាជរដ្ឋាភិបាលផងដែរ។[57]

កិច្ចសន្យាដែលធ្វើឡើងក្នុងការផ្តល់សេវាសាធារណៈត្រូវបានបែងចែកជាពីរគឺ កិច្ចសន្យាក្នុង និងកិច្ចសន្យាក្រៅ។[58]

**ក-កិច្ចសន្យាក្នុង** ៖ គឺជាកិច្ចដំណើរការនៃការផលិតទំនិញ និងសេវា និងការផ្តល់ ឬលក់ទំនិញ និងសេវាដោយអង្គភាពគ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ ហើយដែលជួលមនុស្សមួយក្រុមជាឯកជនមកដឹកនាំ គ្រប់គ្រង ក៏ប៉ុន្តែមន្ត្រីរាជការ និងស្ថាប័ន គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋដដែល។

[56] អំពី ផ.ម.ក http://csx.com.kh/kh/about/mission.jsp?MNCD=1020

[57] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៤៨។

[58] កៅ មុយថង (២០០៦), *សេវាសាធារណៈនៅកម្ពុជា*, ទំព័រ៨៦-៨៧។

**ខ-កិច្ចសន្យាក្រៅ** ៖ គឺជាយន្តការនៃការដឹកនាំគ្រប់គ្រងដំណើរការទាំងស្រុងនូវអង្គភាព ឬ គ្រឹះ ស្ថានសាធារណៈ ឬសហគ្រាសាធារណៈណាមួយ ដែលធ្វើឡើងដោយឯកជនតាមកិច្ចព្រមព្រៀងមួយមានកំណត់ និងច្បាស់លាស់។

ជារួមមក ការផ្តល់សេវាសាធារណៈតាមយន្តការនៃកិច្ចសន្យានេះ បានបង្ហាញឲ្យឃើញពីភាពជោគជ័យតាមរយៈបទពិសោធន៍នៃការអនុវត្ត ជាពិសេសនោះគឺកិច្ចសន្យាក្រៅ ដែលសកម្មភាពមួយចំនួននៃសេវាសាធារណៈត្រូវបានផ្តល់សិទ្ធិ និងអំណាចទៅដល់ក្រុមហ៊ុនឯកជនដោយដាក់ឲ្យស្ថិតនៅក្រោមរបបគតិយុត្តពិសេស។

## ២.៦.៨-ភ្នាក់ងារប្រតិបត្តិការពិសេស

ភ្នាក់ងារប្រតិបត្តិការពិសេស គឺជាទស្សនទានថ្មីមួយនៃយន្តការក្នុងការផ្តល់សេវាសាធារណៈនៅកម្ពុជា ដែលមានអង្គភាពសាធារណៈពោលគឺក្រសួង ស្ថាប័ន ដែលចាត់តាំងឡើងដើម្បីអនុវត្តឲ្យបានសម្រេចនូវគោលដៅពិសេសណាមួយរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើលក្ខខណ្ឌបេសកកម្ម ហើយដែលមានភាពអនុគ្រោះ និងភាពបត់បែនបានទៅលើការរៀបចំ និងការប្រព្រឹត្តទៅ ការគ្រប់ គ្រងធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ ខុសពីអង្គភាពដទៃទៀតនៅក្នុងក្រសួងស្ថាប័ននោះ។លក្ខខណ្ឌបេសកកម្មដើម្បីអនុវត្តយន្តការភ្នាក់ងារប្រតិបត្តិការពិសេស ត្រូវផ្អែកលើចំណុចជាមូលដ្ឋានបួនយ៉ាងគឺ៖[59]

១-ផ្តោតការយកចិត្តទុកដាក់លើតម្រូវការជាអាទិភាពរបស់អ្នកប្រើប្រាស់សេវា ដោយកំណត់ឲ្យបានច្បាស់លាស់អំពីប្រភេទ គុណភាព និងតម្លៃនៃសេវាដែលត្រូវផ្តល់ជូន

២-កំណត់ឲ្យបានច្បាស់លាស់អំពីលទ្ធផលរំពឹងទុក និងធនធានចាំបាច់នានា

៣-កំណត់ឲ្យបានច្បាស់លាស់អំពីការរៀបចំ និងប្រព្រឹត្តទៅរបស់ភ្នាក់ងារនេះ និង

៤-កំណត់ឲ្យបានច្បាស់លាស់អំពីយន្តការនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

[59] ក្រសួងមុខងារសាធារណៈ (២០០៦), *គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ*, ទំព័រ៩៩។

## ១.៦.៩-ឯកជនភាវូបនីយកម្ម

ឯកជនភាវូបនីយកម្ម ជាជម្រើសមួយនៃយន្តការក្នុងការជួយសម្រួលដល់ការផ្ដល់សេវាសាធារណៈ តាមរយៈការជម្រុញ និងការលើកទឹកចិត្តវិស័យឯកជន និងកាត់បន្ថយនូវតួនាទីរបស់រដ្ឋដោយផ្ទាល់ក្នុងកិច្ចការសហគ្រាសនានា ប៉ុន្តែពង្រឹងតួនាទីរបស់រដ្ឋជាបញ្ញត្តិករ។ នៅក្នុងយន្តការនៃការផ្ដល់សេវាសាធារណៈតាមរយៈឯកជនភាវូបនីយកម្ម ធ្វើឡើងក្រោមទម្រង់ជាច្រើនដែលអាស្រ័យទៅតាមការអនុវត្តរបស់ប្រទេសនីមួយ។ សម្រាប់ប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជា ជម្រើសនៃការផ្ដល់សេវាសាធារណៈតាមរយៈឯកជនភាវូបនីយកម្ម ជាផែនការអាទិភាពមួយផងដែរនៅក្នុងកំណែទម្រង់ដ៏ស៊ីជម្រៅ របស់រាជរដ្ឋាភិបាលសម្រាប់ដាក់ឲ្យអនុវត្តនៅតាមបណ្ដាក្រសួង ស្ថាប័ននីមួយៗ។

សរុបជារួមមក ការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា គឺមានលក្ខណៈស្ដង់ដារគ្រប់គ្រាន់ សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាពិសេសបម្រើប្រជាពលរដ្ឋឲ្យមានភាពប្រសើរឡើង ដោយអនុវត្តតាមគោលការណ៍ដែលមានចែងនៅក្នុងច្បាប់ ក៏ដូចជាគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលបានដាក់ឲ្យអនុវត្តពីមួយដំណាក់កាលទៅមួយដំណាក់កាល។ នៅក្នុងនោះ គឺមានការបែងចែកនូវការទទួលខុសត្រូវទៅតាមវិស័យ ឬចង្កោមនៃសេវាសាធារណៈនីមួយៗ ដែលមានទាំងស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ច គឺជាតួអង្គដ៏សំខាន់ៗ។ ក្រៅពីនេះ ការរៀបចំ និងការគ្រប់គ្រងសេវាសាធារណៈនៅកម្ពុជា ក៏បានរួមបញ្ចូលផងដែរនូវយន្តការនៃការផ្ដល់សេវាសាធារណៈ ដែលធ្វើឡើងក្រោមរូបភាពផ្សេងៗគ្នា ដោយមានតួអង្គពីរសំខាន់ៗដែលមានជាអាទិ៍ គឺវិស័យសាធារណៈ និងវិស័យឯកជន។ ប៉ុន្តែ ដោយសារតែទំហំ និងភាពទូលំទូលាយនៃវិសាលភាពទៅលើរដ្ឋបាលសាធារណៈ ជាពិសេសការរៀបចំ និងការគ្រប់គ្រងទៅលើសេវាសាធារណៈនៅកម្ពុជា សារណាបញ្ចប់ការសិក្សានេះធ្វើការបកស្រាយ និងរំលេចឲ្យឃើញឡើងតែបរិបទនៃការអនុវត្តឯកជនភាវូបនីយកម្ម ទៅលើការសាងសង់ និងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ លើប្រសិទ្ធភាពសេវាសាធារណៈ និងផលប៉ះពាល់ ដែលស្ថិតនៅក្រោមយន្តការនៃការផ្ដល់សេវាសាធារណៈ និងស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងសាធារណការ និងដឹកជញ្ជូនតែប៉ុណ្ណោះ។

# ជំពូកទី២

# ឯកជនភាវូបនីយកម្មនៃ

# សេវាសាធារណៈ

# ជំពូកទី២

## ឯកជនភាវូបនីយកម្មនៃសេវាសាធារណៈ

ផ្តើមចេញពីការរិះគន់ផ្នែករដ្ឋបាលសាធារណៈបុរាណ និងសេចក្តីត្រូវការផ្នែកសេវាសាធារណៈដែលមានប្រសិទ្ធភាព និងសក្តិសិទ្ធភាពនៅដើមទសវត្សឆ្នាំ១៩៧០ ឯកជនភាវូបនីយកម្ម ដែលគេស្គាល់ថាជាឧបករណ៍ដ៏សំខាន់ក្នុងសកម្មភាពសាធារណៈ ត្រូវបានបណ្តាប្រទេសមួយចំនួនយកទៅអនុវត្ត និងមានភាពទូលំទូលាយនៅដើមទសវត្សរ៍ឆ្នាំ១៩៨០។ ជាការពិត ឯកជនភាវូបនីយកម្ម គឺជាទម្រង់មួយនៃទម្រង់ជាច្រើនផ្សេងៗទៀតនៅក្នុងការគ្រប់គ្រងរដ្ឋបាលបែបថ្មី ដែលត្រូវកើតមានឡើងនៅចន្លោះទសវត្សឆ្នាំ១៩៧០មកម្លេះ ក្រោមគំនិតផ្តួចផ្តើមរបស់អង់គ្លេស[60]។ យោងទៅតាមទស្សនៈរបស់លោក Martin Minogue បានសរសេរនៅក្នុងសៀវភៅមួយក្បាលក្រោមចំណងជើងថា The Internationalization of Public Management Reinventing the Third World State បានបង្ហាញថា មានទម្រង់ជាច្រើនត្រូវបានចាត់បញ្ចូលទៅក្នុងឧបករណ៍ការគ្រប់គ្រងរដ្ឋបាលបែបថ្មី រួមមានជាអាទិ៍កិច្ចសន្យាក្រៅ ឯកជនភាវូបនីយកម្មទៅលើសេវាសាធារណៈ កំណែទម្រង់ប្រព័ន្ធនៃការផ្តល់សេវាសាធារណៈ ការធ្វើទំនើបកម្មទៅលើស្ថាប័នទទួលសមត្ថកិច្ច និងមានសមត្ថកិច្ច បង្កើតប្រព័ន្ធនៃការផ្តល់សេវាសាធារណៈអោយស្របទៅតាមតម្រូវការនៃអ្នកទទួលសេវាសាធារណៈ និងការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnership)[61]។ ប៉ុន្តែ ដើម្បីឲ្យស្របទៅតាមទំហំ និងដែនកំណត់នៃការស្រាវជ្រាវនៅក្នុងសារណាបញ្ចប់ការសិក្សានេះ មានឧបករណ៍ពីរសំខាន់តែប៉ុណ្ណោះដែលជាកម្មវត្ថុ រួមមានឯកជនភាវូបនីយកម្មទៅលើសេវាសាធារណៈ និងការអនុវត្តយន្តការភាពជាដៃគូរវាងវិស័យរដ្ឋ និងឯកជន។

ដូចនេះ ដើម្បីជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងនូវការអនុវត្តឯកជនភាវូបនីយកម្មទៅលើសេវាសាធារណៈ និងការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅកម្ពុជា យើងទាំងអស់គួរតែស្វែងយល់បន្តិចនូវទំនាក់ទំនងរវាងការគ្រប់គ្រងរដ្ឋបាលបែបថ្មី និងការអនុវត្តនូវឧបករណ៍ឯកជនភាវូបនីយ កម្ម ជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

[60] Korng, V. (2016). *The New Public Management Paradigm: Concept Analysis and Implications in the context of Cambodian Public Service Reform.*
[61] Korng, V. (2016). *The New Public Management Paradigm: Concept Analysis and Implications in the context of Cambodian Public Service Reform.*

## ២.១-ការគ្រប់គ្រងរដ្ឋបាលបែបថ្មី

### ២.១.១-និយមន័យ

ពាក្យ ការគ្រប់គ្រងរដ្ឋបាលបែបថ្មី ត្រូវបានអ្នកសិក្សាអោយនិយមន័យ និងការបកស្រាយផ្សេងៗពីគ្នា និងមិនមាននិយមន័យណាមួយដែលកំណត់ជាក់លាក់នោះទេ។ ដូចនេះ ដើម្បីជាគន្លឹះក្នុងការយល់ដឹងថាតើអ្វីទៅជាការគ្រប់គ្រងរដ្ឋបាលបែបថ្មី សារណាបញ្ចប់ការសិក្សានេះនឹងលើកយកនូវទស្សនៈ និងការសន្និដ្ឋានរបស់អ្នកស្រាវជ្រាវចំនួនបីរូបរួមមាន៖

១-លោក **Christopher Hood** ជាឯកទេសជនក្នុងវិស័យសាធារណៈ និងជាអ្នកបង្កើតទ្រឹស្តីនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី បានបញ្ជាក់ថា ការគ្រប់គ្រងរដ្ឋបាលបែបថ្មីនេះជាលទ្ធផលនៃការរួមបញ្ចូលគ្នារវាងគំនិតពីផ្សេងគ្នា[62]។ គំនិតទី១ ផ្តោតទៅលើទ្រឹស្តីសេដ្ឋកិច្ចប្រពៃណី (Conventional Economic Theory) មានន័យថា ប្រសិនបើប្រៀបធៀបទៅក្នុងវិស័យសាធារណៈ អ្នកទទួលសេវាសាធារណៈគួរតែបង់ថវិកា និងបង់ពន្ធទាបបំផុតតាមដែលអាចធ្វើទៅបាន និងមានការបង់ថ្លៃខ្ពស់ចំពោះសេវាទាំងឡាយណាដែលសំខាន់ៗ ដូចជាការជួលនូវទ្រព្យសម្បត្តិសាធារណៈជាដើម ក្នុងគោលបំណងទទួលបានផលប្រយោជន៍ផ្ទាល់ខ្លួនជាអាទិភាព។ យោងទៅតាមលោក David Korten នៅក្នុងទ្រឹស្តីសេដ្ឋកិច្ចប្រពៃណី (Conventional Economic Theory) ត្រូវបានគេឃើញមាននៅក្នុងទម្រង់ផ្សេងៗគ្នារួមមានជាអាទិ៍ឯកជនភាវូបនីយកម្ម ទីផ្សារសេរី សកលភាវូបនីយកម្មសេដ្ឋកិច្ច ប្រទេសដែលមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព និងការទទួលខុសត្រូវជាចម្បងរបស់រាជរដ្ឋាភិបាលទៅលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជម្រុញកិច្ចប្រតិបត្តិការពាណិជ្ជកម្មនៅក្នុងប្រទេស និងពង្រឹងនីតិរដ្ឋទាក់ទងទៅនឹងសិទ្ធិលើអចលនទ្រព្យ និងកិច្ចសន្យាជាដើម។ ចំណែកឯគំនិតទីពីរ សំដៅដល់ការតម្រង់ទិសទៅលើការគ្រប់គ្រងតាមរយៈ ការធ្វើកំណែទម្រង់វិស័យសាធារណៈដោយយកគំរូតាមវិស័យឯកជនមកអនុវត្តក្នុងវិស័យសាធារណៈ។

២-លោក **George A. Larbi** ជាអ្នកនិពន្ធសៀវភៅមួយក្បាលក្រោមចំណងជើងថា The New Public Management Approach and Crisis States បានឲ្យសេចក្តីសន្និដ្ឋានទៅលើពាក្យ ការគ្រប់ គ្រងរដ្ឋបាលបែបថ្មីថា ជារបៀបនៃការគ្រប់គ្រង និងការអនុវត្តមួយនៅក្នុងរដ្ឋបាលសាធារណៈ ដែលក្នុងនោះទម្រង់ភាគច្រើនយកគំរូចេញមកពីវិស័យឯកជន។ ទម្រង់នៃការគ្រប់គ្រង និងការអនុវត្តនោះរួមមាន ការធ្វើវិមជ្ឈការសេវាសាធារណៈ ការបង្កើតអោយមានការប្រកួតប្រជែងនៅ

[62] Fatemi, Mahboubeh, Behmanesh, Mohammad Reza (2012). *New Public Management Approach and Accountability*. International Journal of Management, Economics and Social Sciences (IJMESS).

ក្នុងវិស័យសាធារណៈ ការផ្តោតជាសំខាន់ទៅលើការអនុវត្តដោយមានការទទួលខុសត្រូវខ្ពស់ពីស្ថាប័នមានសមត្ថកិច្ច ការផ្តោតទៅលើលទ្ធផល និងការតម្រង់ទិសដល់អ្នកទទួលសេវា។[63]

៣-លោក **Mathiasen, D** ជាអ្នកនិពន្ធសៀវភៅ The New Public Management and Its Critics បានអោយនិយមន័យទៅលើពាក្យការគ្រប់គ្រងរដ្ឋបាលបែបថ្មីថា ជាគំរូនៃការផ្លាស់ប្តូររដ្ឋបាលសាធារណៈមួយ (Paradigm Shift) ដែលបានរៀបចំ និងចេញផ្សាយដោយអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) សម្រាប់ឲ្យប្រទេសដែលជាសមាជិករបស់ខ្លួនអនុវត្ត។ នៅក្នុងការកែប្រែ ឬផ្លាស់ប្តូរនោះ មានគោលបំណងលុបបំបាត់បែបបទនៃការធ្វើការងារក្រោមទម្រង់បែបការិយាធិបតេយ្យ (Bureaucracy) ដែលត្រូវបានគេស្គាល់ថា ជាប្រព័ន្ធនៃការគ្រប់គ្រងមួយនៃរដ្ឋបាលសាធារណៈតាមបែបបុរាណ។ យោងទៅតាមលោកសាស្ត្រាចារ្យ Geryy Stoker ជាអ្នកសិក្សាទៅលើវិទ្យាសាស្ត្រនយោបាយ បានបញ្ជាក់ផងដែរថាការផ្លាស់ប្តូរ (Paradigm Shift) នៅក្នុងការគ្រប់គ្រងរដ្ឋបាលបែបថ្មីនេះ មានគោលបំណងចង់ផ្លាស់ប្តូរ ឬកែទម្រង់វិស័យសាធារណៈដើម្បីអោយវិស័យនេះមានប្រសិទ្ធិភាព ប្រសិទ្ធិផល និងការទទួលបានសេវាដោយមានសមភាព ដើម្បីឲ្យស្របទៅតាមទ្រឹស្តីនៃអភិបាលកិច្ច ដែលមានចែងនៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

### ២.១.២-សញ្ញាណនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី

ជាការឆ្លើយតបទៅនឹងការរិះគន់នៃការគ្រប់គ្រងរដ្ឋបាលបែបបុរាណ ការគ្រប់គ្រងរដ្ឋបាលបែបថ្មី ត្រូវបានចាប់បដិសន្ធិឡើងនៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ ក្រោមរូបភាព និងរបៀបវារៈផ្សេងៗគ្នាអាស្រ័យទៅតាមបរិបទនៃប្រទេសនីមួយៗ។ ប៉ុន្តែ នៅក្នុងនោះមានលក្ខណៈប្រហាក់ប្រហែលគ្នាជាមួយនឹងគោលការណ៍ ដែលមានចែងនៅក្នុងការគ្រប់គ្រងរដ្ឋបាលបែបថ្មីនេះ។

ជារួមមក សារណាបញ្ចប់ការសិក្សានឹងលើកយកនូវគោលគារណ៍ចំនួនប្រាំពីរដើម្បីធ្វើជាគន្លឹះក្នុងការយល់នូវសញ្ញាណទូទៅនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី រួមមានជាអាទិ៍[64]៖

១-មន្ត្រីរាជការទាំងអស់នៅក្នុងស្ថាប័នតម្រូវឲ្យមានជំនាញច្បាស់លាស់ ដោយរួមបញ្ចូលទាំងគោលបំណង និងការប្តេជ្ញាចំពោះស្ថាប័ន ឬអង្គភាពរបស់ខ្លួន។

[63] Larbi, G. A. (1999). *The New Public Management Approach and Crisis States*, governance 2000 – 2009 by UNRISD.
[64] Fatemi, Mahboubeh, Behmanesh, Mohammad Reza (2012). *New Public Management Approach and Accountability*. International Journal of Management, Economics and Social Sciences (IJMESS).

២-ធ្វើការកំណត់នូវស្តង់ដារ និងការវិនិច្ឆ័យទៅលើសកម្មភាពការងារដែលមានចែងនៅក្នុងកម្មវិធីគោលនយោបាយនានា តាមរយៈការកំណត់នូវទិសដៅ និងសូចនាករនៅក្នុងរបៀបវារៈនៃការបង្កើតគោលនយោបាយសាធារណៈ។

៣-នៅក្នុងគោលនយោបាយសាធារណៈរបស់រដ្ឋាភិបាល គប្បីត្រូវតែយកចិត្តទុកដាក់លើលទ្ធផល ជាជាងការផ្តោតជាសំខាន់ទៅលើសកម្មភាព និងនីតិវិធី។

៤-ជម្រុញឲ្យមានការធ្វើវិមជ្ឈការនៅក្នុងវិស័យសាធារណៈ ក្នុងគោលបំណងឲ្យមានផ្តល់នូវស្វ័យភាពសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយស្ថិតនៅក្រោមលក្ខខណ្ឌច្បាប់ និងអំណាចអាណាព្យាបាល។

៥-បង្កើតឲ្យសកម្មភាពនៅក្នុងវិស័យសាធារណៈមានភាពប្រកួតប្រជែងកាន់តែខ្លាំង និងមានស្តង់ដារល្អប្រសើរជាងមុនក្នុងគោលបំណងកាត់បន្ថយនូវការចំណាយទាំងពេលវេលា និងហិរញ្ញវត្ថុ ពោលគឺមានលក្ខណៈដូចទៅនឹងការអនុវត្តឯកជនភាវូបនីយកម្ម។

៦-ការគ្រប់គ្រងនៅក្នុងវិស័យសាធារណៈ មានលក្ខណៈស្រដៀងទៅនឹងការគ្រប់គ្រងរបស់វិស័យឯកជន។

៧-សេវាសាធារណៈ គប្បីត្រូវតែមានប្រសិទ្ធភាព និងប្រសិទ្ធផល។

### ២.១.៣-ប្រវត្តិនៃការអនុវត្តការគ្រប់គ្រងរដ្ឋបាលបែបថ្មីនៅប្រទេសអភិវឌ្ឍ

ការធ្វើកំណែទម្រង់រដ្ឋបាលសាធារណៈពីការគ្រប់គ្រងរដ្ឋបាលសាធារណៈបុរាណ មកជាការគ្រប់គ្រងរដ្ឋបាលបែបថ្មី ត្រូវបានដាក់បញ្ចូលទៅក្នុងរបៀបវារៈនៃអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) នៅចុងទសវត្សរ៍ឆ្នាំ១៩៧០ និងមានការអនុវត្តនៅប្រទេសមួយចំនួនដែលជាសមាជិករបស់អង្គការនេះ។[65] ជាក់ស្តែង នៅដើមទសវត្សឆ្នាំ១៨៨០ ទស្សនៈនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី ត្រូវបានលេចឡើងដំបូងនៅក្នុងចក្រភពអង់គ្លេស នៅក្រោមទម្រង់នៃការធ្វើទំនើបកម្មរបស់រដ្ឋបាលនាយករដ្ឋមន្ត្រី លោកស្រី Margaret Thatcher និងមានការអនុវត្តយ៉ាងទូលំទូលាយនៅតាមបណ្តាប្រទេសផ្សេងៗទៀតក្នុងទសវត្សឆ្នាំ១៩៩០។

[65] Larbi, G. A. (1999). *The New Public Management Approach and Crisis States*, governance 2000 – 2009 by UNRISD

នៅក្នុងចក្រភពអង់គ្លេស ក្រោមកម្មវិធីនយោបាយទំនើបកម្មរដ្ឋបាលរបស់លោកស្រីនាយករដ្ឋមន្ត្រី Margaret Thatcher បានប្រែក្លាយរដ្ឋបាលរបស់ប្រទេសនេះទៅជាការគ្រប់គ្រងរដ្ឋបាលបែបថ្មីដំបូងគេបំផុតនៅដើមទសវត្សឆ្នាំ១៩៨០។ ក្នុងកំណែទម្រង់នេះ ដើម្បីស្វែងរកដំណោះស្រាយទៅលើបញ្ហាសេដ្ឋកិច្ចដែលកើតមានឡើងមុនទសវត្សឆ្នាំ១៩៨០ រួមមានអាទិ៍ការកើនឡើងនៃអត្រាគ្មានការងារធ្វើ និងមានអតិផរណាខ្ពស់ ព្រមទាំងមានការរិះគន់ទៅលើប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈផងដែរ[66]។ ជាដំបូង រដ្ឋបាលរបស់លោកស្រីនាយករដ្ឋមន្ត្រី បានរៀបចំកែទម្រង់វិស័យរដ្ឋបាលសាធារណៈរបស់ខ្លួនឲ្យអ៊ីៗ ក្លាយទៅជាឯកជនភាវូបនីយកម្មនៃសហគ្រាសសាធារណៈរបស់រដ្ឋ ក្នុងនោះមានការកាត់បន្ថយផ្នែកជាច្រើនទៀតដែលមាននៅក្នុងវិស័យរដ្ឋបាលសាធារណៈ តាមរយៈការខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យមាន “3Es” ពោលគឺសេដ្ឋកិច្ច (Economy) សមត្ថភាពក្នុងការបំពេញការងារ (Efficiency) និងធ្វើការឲ្យមានប្រសិទ្ធភាព (Effectiveness) នៅគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលចក្រភពអង់គ្លេស។[67] ក្រោយមក ចន្លោះពីទសវត្សឆ្នាំ១៩៨០ រហូតដល់ទសវត្សឆ្នាំ១៩៩០ ចក្រភពអង់គ្លេសបានកែប្រែទាំងស្រុងនូវរដ្ឋបាលរបស់ខ្លួនពីការិយាធិបតេយ្យបែបត្រួតត្រា ឆ្ពោះទៅរកការិយាធិបតេយ្យឲ្យគេគ្រប់គ្រង និងពីប្រព័ន្ធរដ្ឋបាលសាធារណៈឆ្ពោះទៅរកការគ្រប់ គ្រងរដ្ឋបាលបែបថ្មី (From an administered to a managed bureaucracy and from a system of public administration to one of new public management-NPM)។[68]

ចំណែកឯនៅសហរដ្ឋអាមេរិកវិញ មុននឹងឈានដល់ការធ្វើកំណែទម្រង់ទាំងស្រុងនៅដើមទសវត្សឆ្នាំ១៩៩០ ក្រោមពាក្យស្លោកមួយពោលថាការបង្កើតឡើងវិញនូវរដ្ឋាភិបាល (Reinventing Government) ដែលបានរៀបចំដោយលោក Al Gore ដែលជាអតីតអនុប្រធានាធិបតីរបស់រដ្ឋបាលលោកប្រធានធិបតី Bill Clinton សហរដ្ឋអាមេរិកបានជួបនូវបញ្ហាសេដ្ឋកិច្ចស្រដៀងគ្នាទៅនឹងចក្រភពអង់គ្លេសដែល[69] ពោលគឺស្ថានភាពសេដ្ឋកិច្ចត្រូវបានចោទជាបញ្ហា សេវាសាធារណៈបានជួបការលំបាក និងតួនាទីរបស់វិស័យសាធារណៈត្រូវបានមតិហាជនរិះគន់ តាមរយៈការចោទសួរជាសំណួរជាច្រើនពាក់ព័ន្ធទៅនឹងបញ្ហាដែលកើតមានឡើង ដូចជាបំណុលសាធារណៈមានការ

66 Yamamoto, H. (2003). *New Public Management-Japan's Practice*. Institute for International Policy Studies, 1.

67 កៅ មុយថង (២០០៧), *រដ្ឋបាលសាធារណៈទំនើប*, ទំព័រ៨១។

68 កៅ មុយថង (២០០៧), *រដ្ឋបាលសាធារណៈទំនើប*, ទំព័រ៨១។

69 Yamamoto, H. (2003). *New Public Management-Japan's Practice*. Institute for International Policy Studies, 1-2

កើនឡើង ព្រមជាមួយសកម្មភាពខាងក្រៅមានការប៉ះពាល់ធ្ងន់ធ្ងរ[70]។ ជាការឆ្លើយតប រដ្ឋាភិបាលរបស់លោកប្រធានាធិបតី Bill Clinton បានខិតខំធ្វើកំណែទម្រង់នូវវប្បធម៌រដ្ឋាភិបាលសហព័ន្ធអាមេរិក ដោយការដាក់ចេញគោលការណ៍បួនយ៉ាងគឺ ទី១-កាត់បន្ថយនូវរបៀបរបបធ្វើការងារដ៏ស្មុគស្មាញ ទី២-ចាត់ទុកអតិថិជនជាធំ ទី៣-ផ្តល់សិទ្ធិដល់អ្នកធ្វើការឲ្យគេដើម្បីឲ្យមានលទ្ធផល និងទី៤-កាត់បន្ថយការចំណាយដែលមិនចាំបាច់ដើម្បីធ្វើឲ្យរដ្ឋាភិបាលមានភាពប្រសើរឡើង (US: Reinventing Government took place before and during Bill Clinton era. The Government changed culture of American federal government through four key principles: 1-cutting red tape, 2-putting customers first, 3-empowering employees to get results, and 4-cutting back to basics and “producing better government for less”)។

ក្រៅពីប្រទេសអភិវឌ្ឍន៍ទាំងពីរខាងលើនេះ គេឃើញមានផងដែរនូវការអនុវត្តការគ្រប់គ្រងរដ្ឋបាលបែបទំនើប ក្នុងការដឹកនាំរបស់បណ្តាប្រទេសផ្សេងៗទៀត ដែលភាគច្រើនជាសមាជិករបស់ អង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច(OECD)។ ក្នុងនោះរួមមានជប៉ុន អូស្ត្រាលី កាណាដា នូវែលសេឡង់ ឥណ្ឌា និងប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួនរួមមានជាអាទិ៍ ប្រទេសហ្សាម៉ាអ៊ីក និងថៃ ជាដើម។ ខុសពីប្រទេសជប៉ុន[71] ប្រទេសផ្សេងៗទៀតរួមទាំងចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិកផងដែរ សុទ្ធសឹងតែទទួលបានការគាំទ្រយ៉ាងពេញទំហឹង ចំពោះកំណែទម្រង់ តាមរយៈការទទួលបាននូវគោលការណ៍នៃការគ្រប់គ្រងរដ្ឋបាលបែបថ្មីមកពីអង្គការសម្រាប់ការអភិវឌ្ឍ និងសហប្រតិបត្តិការសេដ្ឋកិច្ច (OECD) ធនាគារពិភពលោក (The World Bank) និង មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។

### ២.១.៤-ផលវិបាកនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី

ក្រោយពីមានការអនុវត្តយ៉ាងទូលំទូលាយ ទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលបែបថ្មីមក គេឃើញមាននូវឧបសគ្គមួយចំនួន ដែលបានជះឥទ្ធិពលដល់កិច្ចប្រតិបត្តិនៃការគ្រប់គ្រង និងការធ្វើកំណែទម្រង់នៅប្រទេសមួយចំនួនធំ។ ឧបសគ្គទាំងអស់នោះត្រូវបានបង្រួមទៅជាបីផ្សេងៗគ្នារួមមាន៖[72]

[70] Fatemi, Mahboubeh, Behmanesh, Mohammad Reza (2012). *New Public Management Approach and Accountability*, International Journal of Management, Economics and Social Sciences (IJMESS).
[71] Insisted by Christopher Hood, specialist in New Public Management.
[72] លោក ម៉ឹប ព្រុយណេ និង កញ្ញា សន សូរិយា (២០១៨), សារណាបញ្ចប់ការសិក្សា៖ *ការគ្រប់គ្រងបុគ្គលិកអប់រំក្នុងបរិបទរដ្ឋបាលសាធារណៈបែបថ្មីនៅកម្ពុជា*, ទំព័រ១០-១១។

- **ផលលំបាកលើរចនាសម្ព័ន្ធ៖** ការគ្រប់គ្រងរដ្ឋបាលបែបថ្មី បានធ្វើអោយមានការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធរដ្ឋបាលមានភាពខ្លាំងក្លាដូចជា ការកាត់បន្ថយរចនាសម្ព័ន្ធធ្វើឲ្យការគ្រប់គ្រងរដ្ឋមានភាពរួមតូចនូវតួនាទី និងអំណាចសាធារណៈមានភាពធ្លាក់ខ្សោយ ដោយការចូលរួម និងតួនាទីរបស់ផ្នែកឯកជនកាន់មានភាពធំឡើង។ ការធ្វើវិមជ្ឈការ បានផ្តល់នូវស្វ័យភាពទូលំទូលាយដល់អាជ្ញាធរថ្នាក់ក្រោម អាចធ្វើអោយប្រព័ន្ធគ្រប់គ្រងមានភាពខុសគ្នាទៅតាមតំបន់ និងអាចឈានទៅដល់ការបំបែករដ្ឋជាដើម។ ក្រៅពីនេះ ការប្រកួតប្រជែងក្នុងសេវាសាធារណៈបានធ្វើឲ្យរដ្ឋបាលសាធារណៈក្លាយជារដ្ឋបាលដែលគិតលើផលចំណេញ។

- **ផលលំបាកលើធនធានមនុស្ស៖** ការផ្លាស់ប្តូរការគ្រប់គ្រងរដ្ឋជារឿងចាំបាច់បំផុតដែលត្រូវតែធ្វើ ប៉ុន្តែក្នុងស្ថានភាពនោះ កម្រិតសមត្ថភាពនៃធនធានមនុស្សនៅមិនទាន់មានភាពឆ្លើយតបដែលជាបញ្ហាអវិជ្ជមានទៅលើកំណែទម្រង់ ការផ្លាស់ប្តូរឥរិយាបថរបស់មន្ត្រីមិនទាន់អាចបត់បែនបានមួយរយភាគរយពីអ្នកគ្រប់គ្រងទៅអ្នកបម្រើប្រជាពលរដ្ឋ។ ការកាត់បន្ថយចំនួនបុគ្គលិកបានធ្វើឲ្យ ចំនួននិកម្មភាពមានការកើនឡើងផងដែរ។

- **ផលវិបាកសង្គម៖** តួនាទីរបស់ផ្នែកឯកជនកាន់តែកើនឡើង បានបង្ហាញឲ្យឃើញពីភាពកំសោយរបស់សមត្ថភាពនៃការគ្រប់គ្រងសេវាសាធារណៈរបស់រដ្ឋ ដែលបានធ្វើឲ្យតម្លៃនៃវប្បធម៌សេវាសាធារណៈមានការធ្លាក់ចុះ។ ការប្រើប្រាស់សេវាសាធារណៈដែលផ្តល់ដោយឯកជនកាន់តែមានភាពច្រើនឡើង បានបង្ហាញពីការបាត់បង់ទំនុកចិត្តរបស់ប្រជាពលរដ្ឋចំពោះសេវាសាធារណៈដែលផ្តល់ដោយរដ្ឋ។

## ២.២-ឯកជនភាវូបនីយកម្ម

ដូចបានដឹងរួចមកហើយ ឯកជនភាវូបនីយកម្ម ជាសញ្ញាណមួយដ៏សំខាន់នៃការគ្រប់គ្រងរដ្ឋបាលបែបថ្មី ពោលគឺវាកំពុងក្លាយជាជម្រើសមួយដ៏មានប្រជាប្រិយភាពសម្រាប់បង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការផ្តល់សេវាសាធារណៈ។ នៅក្នុងនោះ ការអនុវត្តឯកជនភាវូបនីយកម្ម ត្រូវបានចាប់ផ្តើមអនុវត្តដំបូងនៅក្នុងប្រទេសឈីលី នៅពាក់កណ្តាលទសវត្សឆ្នាំ១៩៧០ និងបន្តការអនុវត្តនៅចក្រភពអង់គ្លេសក្នុងឆ្នាំ១៩៧៩ នូវែលសេឡង់ និងបារាំងក្នុងឆ្នាំ១៩៨៤ សិង្ហបុរី និងម៉ាឡេស៊ីក្នុងឆ្នាំ១៩៨៥ និងអាមេរិកឡាទីន និងបណ្តាប្រទេសនៅអឺរ៉ុបផ្សេងៗទៀតនៅក្នុងទសវត្ស

ឆ្នាំ១៩៩០[73]។ សម្រាប់ចក្រភពអង់គ្លេស ស្ថិតក្រោមរដ្ឋបាលរបស់លោកស្រីនាយករដ្ឋមន្ត្រី Margaret Thatcher បានអនុវត្តឯកជនភាវូបនីយកម្មយ៉ាងពេញទំហឹង និងបានជួយពង្រឹងវិស័យសេដ្ឋកិច្ចអង់គ្លេសផងដែរ តាមរយៈការដកហូតកម្មសិទ្ធិរបស់រដ្ឋនៅក្នុងឧស្សាហកម្មធ្យូងថ្ម ដែក ថែប ប្រេង និងអគ្គិសនី ទៅឲ្យវិស័យឯកជនកាន់កាប់ជំនួស។[74]

យ៉ាងណាមិញ នៅក្នុងប្រទេសកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជា ការអនុវត្តឯកជនភាវូបនីយកម្មត្រូវបានដាក់ឲ្យអនុវត្តដំបូងនៅក្នុងឆ្នាំ១៩៨៥ ក្រោមរូបភាពជាការវិនិយោគលើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ។[75]

ដូចនេះ ដើម្បីជាគន្លឹះក្នុងការឈានដល់ការយល់ឲ្យបានស៊ីជម្រៅអំពីការអនុវត្តឯកជនភាវូបនីយកម្ម ជាពិសេសទៅលើការសាងសង់ និងកិច្ចប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធលើប្រសិទ្ធភាពសេវាសាធារណៈនៅប្រទេសកម្ពុជា ដែលនឹងត្រូវសិក្សានៅក្នុងជំពូកទី៤ យើងទាំងអស់គ្នាគួរគប្បីស្វែងយល់នូវចំណុចសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងទ្រឹស្តីនៃឯកជនភាវូបនីយកម្មរួមមានជាអាទិ៍ កម្មវត្ថុនៃឯកជនភាវូបនីយកម្ម ទម្រង់នៃឯកជនភាវូបនីយកម្ម និងការអនុវត្តឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។

### ២.២.១-និយមន័យ

ឯកជនភាវូបនីយកម្ម គឺជាការផ្ទេរអំណាចនៃការសម្រេចចិត្ត ការផ្តល់នូវសេវាសាធារណៈ និងការធ្វើហិរញ្ញប្បទាន ពីវិស័យសាធារណៈ ទៅកាន់វិស័យឯកជន។ ការផ្ទេរ ឬផ្លាស់ប្តូរនេះ អាចកើតមានឡើងតាមរយៈការចុះកិច្ចសន្យាដោយផ្ទាល់ទៅឲ្យវិស័យឯកជន ឬអាចជាលទ្ធផលបានពីការរៀបចំដោយប្រយោលផ្សេងៗទៀតរវាងវិស័យឯកជន និងវិស័យសាធារណៈក្នុងគោលបំណងឲ្យមានការប្រកួតប្រជែងនៅក្នុងសេវាសាធារណៈ។ នៅក្នុងនោះ គឺមិនផ្តោតទៅលើថាតើក្រុមហ៊ុនឯកជនជាក្រុមស្វែងរកប្រាក់ចំណេញ និងមិនស្វែងរកប្រាក់ចំណេញនោះទេ ប៉ុន្តែអ្វីដែលពិសេសនោះគឺការត្រួតពិនិត្យទៅលើការផ្តល់សេវាសាធារណៈត្រូវបានផ្លាស់ប្តូរទៅអោយវិស័យឯកជន។[76] នៅក្នុងន័យនេះ ពេលខ្លះត្រូវបានអ្នកសិក្សាសន្និដ្ឋានចំពោះឯកជនភាវូបនីយកម្មថា ការចូលរួម

[73] ADB. (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries.*
[74] CDIAC. (2007). *Privatization Vs. Public-Private Partnerships: A Comparative Analysis.*
[75] ADB. (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries.*
[76] Gollust & Jacobson (2006). Privatization of Public Services: Organizational Reform Efforts in Public Education Public Health. *American Journal of Public Health*, Vol 96.

របស់រាជរដ្ឋាភិបាលនៅក្នុងសកម្មភាពសាធារណៈត្រូវបានកាត់បន្ថយ នៅពេលដែលការផ្តល់សេវាសាធារណៈត្រូវបានផ្លាស់ប្តូរទៅឲ្យវិស័យឯកជន ប៉ុន្តែក្នុងន័យនេះវាមិនប៉ះពាល់ទាំងស្រុងនោះទេចំពោះរាជរដ្ឋាភិបាល ផ្ទុយទៅវិញវាសបញ្ជាក់ឲ្យឃើញពីប្រសិទ្ធភាព និងប្រសិទ្ធផលរបស់រាជរដ្ឋាភិបាលទៅវិញទេ។

ក្រៅពីនេះ ឯកជនភាវូបនីយកម្ម អាចត្រូវបានកំណត់ថាជាការផ្ទេរនូវកម្មសិទ្ធិនៃទ្រព្យសម្បត្តិសាធារណៈដូចជាអគារ ផ្លូវថ្នល់ ឬសហគ្រាសសាធារណៈនានា ទៅឲ្យវិស័យឯកជនផងដែរ ក្នុងគោលបំណងបម្រើឲ្យផលប្រយោជន៍ទូទៅ។[77]

### ២.២.២-កម្មវត្ថុនៃឯកជនភាវូបនីយកម្ម

ការអនុវត្តឯកជនភាវូបនីយកម្ម ត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សេងៗគ្នា ដោយអាស្រ័យទៅតាមបរិបទនៃបណ្តាប្រទេសនីមួយ។ ឧទាហរណ៍ នៅក្នុងប្រទេសនូវែលសេឡង់ ការអនុវត្តឯកជនភាវូបនីយកម្មត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ១៩៨៧ ក្រោយពេលមើលឃើញថាប្រទេសនេះបានជួបប្រទះនូវបញ្ហាហិរញ្ញវត្ថុ ពោលគឺអតិផរណាហិរញ្ញវត្ថុមានការកើនឡើងខ្ពស់ និងការទូទាត់ចំណាយមានការពិបាក។ ដើម្បីជាការឆ្លើយតប រដ្ឋាភិបាលបានធ្វើកំណែទម្រង់ និងដាក់ឲ្យអនុវត្តនូវគោលនយោបាយសារពើពន្ធ គោលនយោបាយរូបិយវត្ថុ និងធ្វើកំណែទម្រង់ច្បាប់ស្តីពីការងារដែលបានផ្តល់ឱកាសជាច្រើនទៅដល់វិស័យឯកជន។[78]

ជារួមមកវិញ បើទោះបីជាប្រទេសដែលអនុវត្តឯកជនភាវូបនីយកម្មមានកម្មវត្ថុផ្សេងៗគ្នា ប៉ុន្តែនៅក្នុងនោះ គេបានកំណត់នូវកម្មវត្ថុចំនួនបីធំៗរួមមាន៖[79]

- **ធ្វើឲ្យប្រសើរឡើងនូវការប្រើប្រាស់សហគ្រាសសាធារណៈ៖** ផ្តល់ឱកាសទៅដល់ក្រុមហ៊ុនឯកជនដើម្បីធ្វើការវិនិយោគទៅលើសហគ្រាសសាធារណៈ ក្នុងគោលបំណងជម្រុញ និងបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចជាតិ។ ក្នុងនោះ វាបានបម្រើ ឬបំពេញតម្រូវការសង្គមផងដែរ ពីព្រោះថាបន្ទាប់ពីសហគ្រាសសាធារណៈត្រូវបានធ្វើឯកជនភាវូបនីយកម្ម លទ្ធផលមានការកើនឡើង ដែលជាហេតុជម្រុញឲ្យតម្លៃនៃសេវាមានការធ្លាក់ចុះ ចំណាយពេលវេលាតិច និងកាត់បន្ថយភាពក្រីក្រ។

---

[77] CDIAC. (2007). *Privatization Vs. Public-Private Partnerships: A Comparative Analysis.*
[78] ADB. (2001). *Special Evaluation Study on the Privatization of Public Sector Enterprises*: *Lessons for Developing Member Countries.*
[79] Shirley, M. M. (1992). *The What, Why, and How of Privatization: A World Bank Perspective*, Vol 60, Issue 6.

- **បង្កើនប្រសិទ្ធភាពប្រតិបត្តិការនៅក្នុងវិស័យសាធារណៈ៖** ជាគោលការណ៍ ឯកជនភាវូបនីយកម្មតម្រូវឲ្យមានតម្លាភាព និងមានការប្រកួតប្រជែង ដូចនេះវាបានធ្វើឲ្យប្រតិបត្តិការនៅក្នុងសកម្មភាពសាធារណៈមានប្រសិទ្ធភាពជាមុន។ ទិដ្ឋភាពបែបនេះ ជាលទ្ធផលកើតចេញពីចំណុចអវិជ្ជមានចំនួនពីររបស់រដ្ឋាភិបាលមុនពេលធ្វើឯកជនភាវូបនីយកម្ម។ ទីមួយ ការផ្តល់សេវាសាធារណៈមិនមានតម្លាភាព ជាពិសេសរវាងអ្នកមាន និងអ្នកក្រ និងទីពីរ សំដៅដល់អសមត្ថភាពមួយចំនួនរបស់រាជរដ្ឋាភិបាលនៅក្នុងសកម្មភាពសាធារណៈ។
- **បង្កើនប្រសិទ្ធភាពថាមវន្ត៖** អ្នកស្រាវជ្រាវបានបង្ហាញថា នៅក្នុងសកម្មភាពរបស់វិស័យឯកជនមានភាពច្នៃប្រឌិត និងការអភិវឌ្ឍជានិច្ចទៅលើការវិនិយោគ ដែលជាហេតុធ្វើឲ្យភាពជោគជ័យមានច្រើនជាងវិស័យសាធារណៈ។ ដូចនេះ ការអនុវត្តឯកជនភាវូបនីយកម្មនៅតែជាផែនការអាទិភាពនៅក្នុងយន្តការនៃការផ្តល់សេវាសាធារណៈ។

### ២.២.៣-ទម្រង់នៃឯកជនភាវូបនីយកម្ម

ការអនុវត្តឯកជនភាវូបនីយកម្ម អាចធ្វើឡើងក្រោមទម្រង់បីផ្សេងៗគ្នារួមមានជាអាទិ៍ ការផ្ទេរ (Delegation) ការមិនវិនិយោគ (Disvestment) និងការផ្លាស់ប្តូរ (Displacement)។[80]

**ក-ការផ្ទេរ**(Delegation)៖ ជាទម្រង់នៃការអនុវត្តឯកជនភាវូបនីយកម្មមួយដែលរដ្ឋាភិបាលនៅតែមានការទទួលខុសត្រូវចំពោះមុខងាររបស់ខ្លួន ប៉ុន្តែបានផ្ទេរនូវសកម្មភាព ឬអំណាចមួយចំនួនទៅឲ្យវិស័យឯកជនដូចជាការផ្តល់សេវាសាធារណៈ។ នៅក្នុងទម្រង់នេះ អាចធ្វើឡើងក្រោមរូបភាពជាកិច្ចសន្យា (Contract) ការលក់ (Franchise) ភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Part-nership) ការធានា (Voucher) ការប្រគល់អោយ (Mandate) ការប្រកួតប្រជែងរវាងវិស័យសាធារណៈ និងឯកជន (Public-Private Competititon) និង ការធ្វើអនុប្រទាន និងឧបត្ថម្ភទុនផ្សេងៗទៀត (Grants and Other Subsidies)។

**ខ-ការមិនវិនិយោគ**(Disvestment)៖ នៅក្នុងទម្រង់នេះមានលក្ខណៈស្រដៀងគ្នាបន្តិចទៅនឹងការផ្ទេរ (Delegation) ត្រង់ថារដ្ឋាភិបាលនៅតែមានសិទ្ធិចូលរួមទៅក្នុងសកម្មភាពរបស់សកម្មភាព វិស័យឯកជន ក្រោយពេលឯកជនភាវូបនីយកម្មត្រូវបានអនុវត្ត។ ប៉ុន្តែវាមានលក្ខណៈខុសពីការផ្ទេរ (Delegation) ត្រង់ថារដ្ឋបានផ្តល់នូវស្វ័យភាព (Denetionalization) ទៅឲ្យវិស័យ

[80] Savas, E. S. (2000). *Privatization and Public-Private Partnership*, Page 2-13.

ឯកជនក្រោមរូបភាពផ្សេងៗគ្នា។ នៅក្នុងទម្រង់បែបនេះ មានដូចជាការលក់ (Sale) ការផ្ទេរដោយឥតគិតថ្លៃ (Free Transfer) និងការលក់ហ៊ុន ឬទូទាត់សំណង (Liquidation)។

**គ-ការផ្លាស់ប្តូរ**(Displacement)៖ មានលក្ខណៈខុសគ្នាពីទម្រង់ពីរផ្សេងទៀត ពោលគឺមិនតម្រូវឲ្យមានមុខងារ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលទៀតទេ បន្ទាប់ពីធ្វើឯកជនភាវូបនីយកម្ម។ ក្នុងន័យនេះចង់បញ្ជាក់ថា មុខងារ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាលត្រូវបានរួមតូចទៅៗ។ ក្រៅពីនេះ ការអនុវត្តឯកជនភាវូបនីយកម្មតាមវិធីសាស្ត្រនេះ មិនសូវមានការប្រកួតប្រជែងនោះទេក្នុងកិច្ចលទ្ធកម្មសាធារណៈ។ នៅក្នុងទម្រង់បែបនេះមានដូចជា អវត្តមាន (Default) សំដៅដល់អវត្តមាន ឬភាពមិនគ្រប់គ្រាន់របស់រដ្ឋាភិបាល នៅក្នុងការបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋតាមរយៈការផ្តល់សេវាសាធារណៈ។ នៅក្នុងន័យចង់បញ្ជាក់ថា អ្នកទទួលសេវាសាធារណៈមិនពេញចិត្តចំពោះសកម្មភាពរបស់រដ្ឋាភិបាលតទៅទៀត ពីព្រោះតែភាពធ្វេសប្រហែសរបស់រដ្ឋក្នុងប្រការណាមួយ។ ក្រៅពី អវត្តមាន (Default) គឺនៅមានការដកហូត (Withdrawal) ការធ្វើដោយស្ម័គ្រចិត្ត (Voluntary Action) និងកាត់បន្ថយការត្រួតត្រា (Deregulation)។ ចំពោះការដកហូត (Withdrawal) សំដៅដល់ការដកហូតនូវសកម្មភាពទាំងឡាយណាពីរដ្ឋ ដោយក្រុមហ៊ុនឯកជន។ ក្នុងន័យនេះចង់បញ្ជាក់ពីការដកហូតនូវមុខងារពីភ្នាក់ងាររបស់រដ្ឋាភិបាលក្រោយពេលដែលរដ្ឋបានផ្តល់អោយ ប៉ុន្តែមិនអាចអនុវត្តបានដោយជោគជ័យ។ ចំពោះការធ្វើដោយស្ម័គ្រចិត្ត (Voluntary Action) សំដៅដល់ការអនុវត្តឯកជនភាវូបនីយកម្ម ដែលរដ្ឋបានលើកទឹកចិត្តទៅដល់វិស័យឯកជន ជាពិសេសនោះអង្គការមិនស្វែងរកប្រាក់ចំណេញ អាចទទួលបានការជួយឧបត្ថម្ភពីរដ្ឋដើម្បីបំពេញសេចក្តីត្រូវការរបស់អ្នកទទួលសេវាសាធារណៈ។ ចំណែកឯ ការកាត់បន្ថយការត្រួតត្រា (Deregu- lation) សំដៅដល់ការធ្វើឯកជនភាវូបនីយកម្ម ក្នុងករណីដែលក្រុមហ៊ុនឯកជនអាចយកឈ្នះទៅលើការប្រកួតប្រជែងជាមួយវិស័យសាធារណៈ ដើម្បីផ្តល់នូវផលប្រយោជន៍សាធារណៈ។

ជារួមមកវិញ ទម្រង់នៃការអនុវត្តឯកជនភាវូបនីយកម្មដូចបានបកស្រាយខាងលើនេះ គឺភាគច្រើនត្រូវបានអនុវត្តជាយូរមកហើយ ជាពិសេសក្រោយពេលទ្រឹស្តីនៃឯកជនភាវូបនីយកម្មត្រូវបានដាក់ឲ្យអនុវត្ត។ ប៉ុន្តែដោយសារតែការវិវត្តនៃបរិបទពិភពលោក ទម្រង់ខ្លះមិនត្រូវបានអនុវត្តតទៅទៀត និងទម្រង់ខ្លះទៀតត្រូវបានបង្កើតឡើង និងមានការអនុវត្តយ៉ាងទូលំទូលាយ។ នៅក្នុងនោះមានដូចជា ភាពជាដៃគូរវាងរដ្ឋ និងឯកជនជាដើម។ ដូចនេះ ដើម្បីឲ្យស្របទៅតាមទំហំ និងដែន

កំណត់នៃការស្រាវជ្រាវនៃសារណាបញ្ចប់ការសិក្សានេះ គឺមានតែទម្រង់នៃការអនុវត្តឯកជនភាវូបនីយកម្មតែមួយប៉ុណ្ណោះ ត្រូវបានជ្រើសរើសដើម្បីសិក្សា និងធ្វើជាមូលដ្ឋានគ្រឹះក្នុងការយល់ដឹងនូវយន្តការនៃការផ្តល់សេវាសាធារណៈនៅកម្ពុជា។ នៅក្នុងទម្រង់នោះ គឺភាពជាដៃគូរវាងរដ្ឋ និងឯកជន។

### ២.២.៣.១-ភាពជាដៃគូរវាងរដ្ឋ និងឯកជន

#### ២.២.៣.១.១-និយមន័យ

យោងទៅតាមធនាគារពិភពលោក (World Bank) ភាពជាដៃគូរវាងរដ្ឋ និងឯកជន សំដៅដល់កិច្ចសន្យារយះពេលវែងដែលបង្កើតឡើងដោយភាគីក្រុមហ៊ុនឯកជន និងស្ថាប័នរដ្ឋ សម្រាប់ធ្វើការផ្តល់សេវាសាធារណៈ ដែលក្នុងនោះភាគីក្រុមហ៊ុនឯកជន ជាតួអង្គសំខាន់ក្នុងការទទួលខុសត្រូវទៅលើហានិភ័យ និងការគ្រប់គ្រង។[81]

នៅក្នុងគម្រោងដែលអនុវត្តតាម ភាពជាដៃគូរវាងរដ្ឋ និងឯកជននេះ ការចំណាយជាដំបូងគឺជាបន្ទុករបស់ភាគីក្រុមហ៊ុនឯកជន ព្រមជាមួយនឹងការទទួលខុសត្រូវមួយចំនួនផងដែរដូចជាការសាងសង់ ការជួសជុល និងការថែរក្សាទៅលើគម្រោង។ នៅក្នុងគម្រោងដែលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ភាគច្រើនជាគម្រោងដែលអភិវឌ្ឍទៅលើផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន ប្រព័ន្ធធារាសាស្ត្រ ប្រព័ន្ធបង្ហូរទឹក និងការអភិវឌ្ឍទៅលើរោងចក្រអគ្គិសនីជាដើម។[82]

#### ២.២.៣.១.២-លក្ខណៈនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន

លក្ខណៈនៃភាពជាដៃគូររវាងរដ្ឋ និងឯកជនត្រូវបានកំណត់ដូចខាងក្រោម៖[83]

**១-ហិរញ្ញប្បទាន៖** ប្រភពធនធានហិរញ្ញវត្ថុដែលចំណាយទៅលើគម្រោងដំបូង គឺជាបន្ទុករបស់ភាគីឯកជន ក្រោយពេលដែលរដ្ឋាភិបាលធ្វើការជ្រើសរើសធ្វើជាអ្នកទទួលកិច្ចសន្យា។ ក្នុងករណីនេះ រដ្ឋនឹងផ្តល់ហិរញ្ញប្បទានត្រឡប់ទៅឲ្យភាគីឯកជនវិញ នៅពេលដែលគម្រោងត្រូវបានបញ្ចប់ជាស្ថាពរ ប៉ុន្តែភាគីរដ្ឋក៏អាចធ្វើការកាត់បន្ថយនូវហិរញ្ញប្បទានផងដែរ ប្រសិនបើមើលឃើញថាលទ្ធផលដែលទទួលបាន ផ្ទុយពីលក្ខខណ្ឌដែលកំណត់ក្នុងកិច្ចសន្យា។ ឧទាហរណ៍ ប្រសិនបើគម្រោងលើផ្លូវមួយក្រោយពេលដែលសាងសង់ និងបើកឲ្យប្រើប្រាស់រួចហើយ ប៉ុន្តែគុណភាពមិនស្របតាមស្តង់ដារជាដើម។ ទន្ទឹមនឹងការអនុវត្តគម្រោងនេះផងដែរ ភាគីឯកជនក៏អាចសង្ឃឹមថា

[81] Deep, Kim, and Lee (2019). *Realizing the Potential of Public-Private Partnerships to Advance Asia's Infrastructure Development.*
[82] Savas, E. S. (2000). *Privatization and Public-Private Partnership*, Page 2-13.
[83] The United Nations Economic and Social Commission for Asia and the Pacific. *Public-Private Partnerships*, Training Modules: Cambodia Verson.

នឹងអាចទទួលបានប្រាក់ចំណេញ តាមរយៈការទទួលបាននូវសិទ្ធិក្នុងការប្រមូលកម្រៃសេវាពីការប្រើប្រាស់គម្រោង ដែលខ្លួនកំពុងសាងសងដូចជាគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធដែលបានមកពីការប្រើប្រាស់ផ្លូវពីសំណាក់ប្រជាពលរដ្ឋ។ ក្រៅពីនេះ ភាគីឯកជនក៏អាចទទួលបានការទូទាត់ផ្អែកលើថវិកាជាតិពីរដ្ឋ ដោយផ្អែកលើលទ្ធផលការងារទៅតាមពេលវេលាកំណត់ទុក។

**២-រយៈពេល៖** សម្រាប់គម្រោងដែលអនុវត្តតាមភាពជាដៃគូរវាងរដ្ឋ និងឯកជន រយៈពេលនៅតែបន្តទៅមុខទោះបីជាការសាងសង់ត្រូវបានបញ្ចប់។ ក្នុងករណីនេះ ភាគីឯកជននៅតែទទួលខុសត្រូវ មិនត្រឹមតែការស្ថាបនាហេដ្ឋារចនាសម្ព័ន្ធនោះទេ ប៉ុន្តែថែមទាំងការងារប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធទៅមុខជាច្រើនឆ្នាំ តាមការកំណត់ទុកនៅក្នុងកិច្ចសន្យាដូចជា តម្រូវឲ្យមានរយៈពេលច្រើនជាង២០ឆ្នាំជាដើម។ ស្របពេលនេះ អាជ្ញាធរសាធារណៈត្រូវតែពិនិត្យតាមដានទៅលើការអនុវត្តការងាររបស់ប្រតិបត្តិការីឯកជនពេញមួយរយៈពេល មុនពេលដែលកិច្ចសន្យានៃគម្រោងត្រូវបានបញ្ចប់ និងប្រគល់កម្មសិទ្ធិលើទ្រព្យទៅឲ្យអាជ្ញាធរសាធារណៈ។

**៣-លទ្ធផល ឬសមិទ្ធិផលការងារ៖** គម្រោងដែលអនុវត្តតាមភាពជាដៃគូរវាងរដ្ឋ និងឯកជន ផ្តោតជាសំខាន់ទៅលើសុចនាករនៃគុណភាព ឬសមិទ្ធិផលការងារដែលទទួលបាន ច្រើនជាងការបញ្ជាក់អំពីពត៌មានលំអិតដែលសម្រេចបាននៃគម្រោង។ ធ្វើបែបនេះអាចផ្តល់ឱកាសក្នុងការបង្កើតគំនិតដើម្បីដោះស្រាយបញ្ហាថ្មីៗ ក្នុងគោលបំណងអោយការផ្តល់សេវាសាធារណៈអាចសន្សំសំចៃថវិកាបានច្រើន។

**៤-ហានិភ័យ៖** ហានិភ័យដែលកើតពីការប្រតិបត្តិការគម្រោង ត្រូវបានចែករំលែកក្នុងការទទួលខុសត្រូវរវាងភាគីទាំងសងខាង ដោយពិនិត្យមើលថាតើភាគីខាងណាដែលមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងហានិភ័យនោះ។ ហានិភ័យទាំងអស់នោះអាចជាការចំណាយទៅលើការសាងសង់ និងប្រតិបត្តិការ ពោលគឺលើសពីថវិកាដែលបានគ្រោងទុក ដូចជាការផ្គត់ផ្គង់ តម្រូវការ ហិរញ្ញវត្ថុ ឬមូលនិធិថវិកា ហានិភ័យមានការពាក់ព័ន្ធនឹងការផ្លាស់ប្តូរក្នុងក្របខណ្ឌច្បាប់ ឬការសម្រេចចិត្តខាងផ្នែកនយោបាយ និងហានិភ័យដែលកើតចេញពីករណីប្រធានសក្តិជាដើម។

ក្រៅពីលក្ខណៈទាំងបួននេះ ភាពជាដៃគូរវាងរដ្ឋ និងឯកជន មានគំរូ ឬម៉ូឌែល សំខាន់ៗផ្សេងទៀតសម្រាប់អោយប្រទេសដែលអនុវត្តអាចគិត ឬពិចារណា។ គំរូទាំងអស់នោះរួមមានសាងសង់-អាជីវកម្ម-ផ្ទេរ (Build-Operate-Transfer) សាងសង់-គ្រប់គ្រង-អាជីវកម្ម-ផ្ទេរ (Build-Own-

Operate-Transfer) សាងសង់-គ្រប់គ្រង-អាជីវកម្ម (Build-Own-Operate) និង សាងសង់-អាជីវកម្ម-ការជួល-ផ្ទេរ (Build-Operate-Lease-Transfer)។ល។ ក្នុងគំរូទាំងអស់នោះត្រូវបានពន្យល់ និងបកស្រាយដូចខាងក្រោម៖

**ក-សាងសង់-អាជីវកម្ម-ផ្ទេរ** (Build-Operate-Transfer)៖ ជាគំរូមួយដែលភាគីក្រុមហ៊ុនឯកជនទទួលខុសត្រូវទៅលើការរចនា ការសាងសង់ និងប្រតិបត្តិការ ឬធ្វើអាជីវកម្ម នៅក្នុងពេលអនុវត្តកិច្ចសន្យា និងមានការផ្ទេរនូវការសម្របសម្រួលចំពោះលទ្ធផលនៃគម្រោងទៅឲ្យភាគីរដ្ឋវិញនៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់។ ជាធម្មតា តួនាទីរបស់ភាគីក្រុមហ៊ុនឯកជននៅក្នុងគំរូនេះត្រូវប្រើហិរញ្ញវត្ថុផ្ទាល់ខ្លួនទៅលើការសាងសង់នៃគម្រោង និងការទទួលខុសត្រូវចំពោះការស្ថាបនា និងការថែរក្សា។ ប៉ុន្តែ ភាគីឯកជនអាចទទួលបានចំណូលពីគម្រោងតាមរយៈការបង់ថ្លៃសេវាពីអ្នកទទួលបានសេវាសាធារណៈ។ នៅក្នុងគំរូនេះភាគច្រើនត្រូវបានយកទៅអនុវត្តចំពោះការសាងសង់ផ្លូវជាតិ (National Highways)។[84]

**ខ-សាងសង់-គ្រប់គ្រង-អាជីវកម្ម-ផ្ទេរ** (Build-Own-Operate-Transfer)៖ នៅក្នុងគំរូនេះគឺមានលក្ខណៈស្រដៀងគ្នាស្ទើរតែទាំងស្រុងនឹង គំរូសាងសង់-អាជីវកម្ម-ផ្ទេរ (Build-Operate-Transfer) ប៉ុន្តែវាខុសគ្នាត្រង់ថា រាល់ហិរញ្ញវត្ថុទាំងអស់រួមបញ្ចូលទាំងចំណាយទៅប្រតិបត្តិការផ្សេងៗនៅក្នុងគម្រោងជាបន្ទុករបស់ក្រុមហ៊ុនឯកជនទាំងស្រុង ពោលគឺមិនមានស្ថាប័នហិរញ្ញវត្ថុណាមួយរបស់រដ្ឋចូលរួមពាក់ព័ន្ធនោះទេ។ គំរូនេះភាគច្រើនត្រូវបានយកទៅអនុវត្តចំពោះការសាងសង់ផ្លូវជាតិ និងកំពង់ផែ។

**គ-សាងសង់-គ្រប់គ្រង-អាជីវកម្ម** (Build-Own-Operate)៖ ជាគំរូមួយដែលបញ្ជាក់ពីការទទួលខុសត្រូវរបស់ភាគីក្រុមហ៊ុនឯកជន ទៅលើប្រតិបត្តិការនៃគម្រោងដូចគំរូផ្សេងៗទៀត ប៉ុន្តែលទ្ធផលនៃគម្រោងមិនត្រូវបានប្រគល់ទៅឲ្យភាគីរដ្ឋវិញនោះទេ ពោលគឺភាពជាម្ចាស់កម្មសិទ្ធិត្រូវបានកាន់កាប់ដោយភាគីក្រុមហ៊ុនឯកជន។[85] នៅក្នុងករណីនេះ ភាគីរដ្ឋអាចត្រូវបានយល់ព្រម

[84] Tojo Jose. (2016). *What are the different models for Public Private Partnership (PPP) in infrastructure?*. Retrieved from https://www.indianeconomy.net/splclassroom/what-are-the-different-models-for-public-private-partnership-ppp-in-infrastructure/

[85] Public Private Partnership Commission. *Models of PPPs*. Retrieved from http://www.pppc.mw/articles/models-of-ppps

អោយទិញនូវផលិតផល និងសេវាកម្មពីភាគីក្រុមហ៊ុនឯកជន ក្នុងលក្ខខណ្ឌណាមួយដែលមានចែងនៅក្នុងកិច្ចសន្យា[86]។

**ឃ-សាងសង់-អាជីវកម្ម-ការជួល-ផ្ទេរ** (Build-Operate-Lease-Transfer)៖ នៅក្នុងគំរូនេះ ភាគីរដ្ឋធ្វើសម្បទានទៅដល់ភាគីក្រុមហ៊ុនឯកជនដើម្បីសាងសង់អគារមួយ ឬច្រើន ធ្វើជាម្ចាស់កម្មសិទ្ធិទៅលើអគារ និងជួលអគារនោះទៅឲ្យភាគីរដ្ឋ។ ប៉ុន្តែ ភាគីក្រុមហ៊ុនឯកជនត្រូវប្រគល់នូវអគារនោះទៅឲ្យភាគីរដ្ឋវិញ ក្នុងករណីដែលរយៈពេលនៃកិច្ចសន្យាត្រូវបានបញ្ចប់ ដូចមានចែងនៅក្នុងកិច្ចសន្យាសម្បទាន។[87]

ជារួមមក លក្ខណៈនៃគម្រោងដែលអនុវត្តនៅក្នុង ភាពជាដៃគូរវាងរដ្ឋ និងឯកជ មានលក្ខណៈខុសគ្នា និងស្រដៀងគ្នាទៅលើករណីមួយចំនួនដូចជាប្រតិបត្តិការ ឬហិរញ្ញវត្ថុនៃគម្រោងជាដើម។ ប៉ុន្តែ លក្ខណៈខុសគ្នា និងស្រដៀងគ្នានេះ មិនសូវជាមានបញ្ហាសម្រាប់ភាគីទាំងសងខាងនោះទេ អ្វីដែលសំខាន់នោះការកំណត់នូវគោលដៅ ឬសូចនាករនៃគម្រោង និងការទទួលខុសត្រូវ ឬការបែងចែកនូវហានិភ័យរវាងភាគីទាំងសងខាង មុនពេលដែលសម្រេចចិត្តជ្រើសរើសនូវគំរូ ឬម៉ូឌែលណាមួយដែលខ្លួនពេញចិត្ត។

### ២.២.៣.១.៣-ដំណើរការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន

គម្រោងដែលអនុវត្តតាមភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានរៀបចំដោយគោរពទៅតាមដំណើរការ ឬដំណាក់កាលចំនួនបួនសំខាន់ៗរួមមានជាអាទិ៍ ការធ្វើអត្តសញ្ញាណកម្មគម្រោង ការរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងដំណាក់កាលនៃការគ្រប់គ្រងគម្រោង។ ដំណាក់កាលទាំងបួននោះត្រូវបានបកស្រាយដូចខាងក្រោម៖[88]

**១-ការធ្វើអត្តសញ្ញាណកម្មគម្រោង៖** ជាដំណាក់កាលមួយដែលរៀបចំឡើងដោយរដ្ឋាភិបាល ក្នុងគោលបំណងកំណត់ថាតើគម្រោងដែលត្រូវបានលើកឡើង អាចអនុវត្តតាមយន្តការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន បានដែរ ឬទេ។ នៅក្នុងដំណាក់កាលនេះ មានគោលការណ៍វិនិច្ឆ័យមួយចំនួនដែលជាមូលដ្ឋានគ្រឹះ ដើម្បីឲ្យការធ្វើអត្តសញ្ញាណកម្មគម្រោងទទួលបានជោគជ័យ។

[86] Tojo Jose. (2016). *What are the different models for Public Private Partnership (PPP) in infrastructure?*. Retrieved from https://www.indianeconomy.net/splclassroom/what-are-the-different-models-for-public-private-partnership-ppp-in-infrastructure/

[87] Tojo Jose. (2016). *What are the different models for Public Private Partnership (PPP) in infrastructure?*. Retrieved from https://www.indianeconomy.net/splclassroom/what-are-the-different-models-for-public-private-partnership-ppp-in-infrastructure/

[88] The United Nations Economic and Social Commission for Asia and the Pacific. *Public-Private Partnerships*, Training Modules: Cambodia Version.

គោលការណ៍វិនិច្ឆ័យនោះ ត្រូវពិនិត្យទៅលើទំហំពោលគឺថាតើគម្រោងធំល្មមគ្រប់គ្រាន់ដែរ ឬទេ ពីព្រោះថាគម្រោងដែលយកយន្តការតាមភាពជាដៃគូរវាងរដ្ឋ និងឯកជន តម្រូវឲ្យមានលក្ខណៈធំល្មមដែលរដ្ឋាភិបាលផ្ទាល់មិនមានលទ្ធភាពក្នុងការចំណាយ។ គោលការណ៍វិនិច្ឆ័យមួយទៀត ត្រូវសិក្សាទៅលើភាពយូរអង្វែងនៃការប្រើប្រាស់លទ្ធផលនៃគម្រោង មានន័យថាប្រសិនបើគម្រោងធ្វើការអភិវឌ្ឍទៅវិស័យហេដ្ឋារចនាសម្ព័ន្ធ ភាគីដែលពាក់ព័ន្ធត្រូវសិក្សាពីតម្រូវការទាំងក្នុងបច្ចុប្បន្នកាល និងអនាគតកាល។ ក្រៅពីនេះ រដ្ឋាភិបាលត្រូវសិក្សាទៅលើសមត្ថភាពរបស់ភាគីក្រុមហ៊ុនឯកជន ដើម្បីធានាធ្វើយ៉ាងណាឲ្យក្រុមហ៊ុនឯកជនមានហិរញ្ញវត្ថុគ្រប់គ្រាន់ និងបច្ចេកទេសនៃការសាងសង់។ នៅក្នុងនោះផងដែរ ក្រុមហ៊ុនឯកជនក្រៅស្រុកត្រូវបានផ្តល់ឱកាសជាអាទិភាពចំពោះយន្តការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជននេះ។ ចំណែកឯលក្ខណៈវិនិច្ឆ័យចុងក្រោយ ផ្តោតសំខាន់ទៅលើការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមទៅក្នុងការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេសនោះគឺការរៀបចំផែនការ និងគោលការណ៍ច្បាប់ឲ្យបានគ្រប់គ្រាន់។

**២-ដំណាក់កាលនៃការរៀបចំគម្រោង៖** សំដៅដល់ការចាប់ផ្តើម និងរៀបចំផែនការអាជីវកម្មរបស់គម្រោង។ នៅក្នុងនោះមានចំណុចមួយចំនួន ដែលត្រូវពិចារណារួមមានជាអាទិ៍ការសិក្សាទៅលើផ្នែកបច្ចេកទេស ការសិក្សា ឬវាយតម្លៃលើផលប្រយោជន៍សង្គម និងសេដ្ឋកិច្ច ពិចារណាទៅលើកត្តាហិរញ្ញវត្ថុ ច្បាប់ និងបទបញ្ញត្តិ និងចុងក្រោយនោះត្រូវសិក្សាពីផលប៉ះពាល់ដល់សង្គម និងបរិស្ថាន ពោលគឺធានាធ្វើយ៉ាងណាឲ្យមានផងប៉ះពាល់តិច និងទទួលបានលទ្ធផលល្អ។

**៣-ដំណាក់កាលប្រតិបត្តិការគម្រោង៖** នៅក្នុងដំណាក់កាលនេះ គោលការណ៍នៃការប្រកួតប្រជែងដោយយុត្តិធម៌ និងតម្លាភាពតម្រូវឲ្យមានជាចាំបាច់ ក្នុងគោលបំណងទាក់ទាញទៅដល់ក្រុមហ៊ុនឯកជននៅក្នុងកិច្ចលទ្ធកម្មនៃគម្រោង។ ដូចនេះ ដើម្បីអោយដំណាក់កាលនេះប្រព្រឹត្តទៅទទួលបានជោគជ័យ រាជរដ្ឋាភិបាលត្រូវរៀបចំអោយមានដំណាក់កាលបួនផ្សេងៗទៀតដូចជា ការរៀបចំឯកសារដេញថ្លៃ ការកំណត់បុរេលក្ខណៈវិនិច្ឆ័យ ការដេញថ្លៃ និងការសម្រេចចិត្តជ្រើសរើស ៖

- **ការរៀបចំឯកសារដេញថ្លៃ៖** រដ្ឋត្រូវធ្វើសេចក្តីព្រាងកិច្ចសន្យាភាពជាដៃគូរវាងរដ្ឋ និងឯកជន។ នៅក្នុងសេចក្តីព្រាងនៃកិច្ចសន្យានេះ តម្រូវឲ្យបញ្ជាក់យ៉ាងច្បាស់នូវសំណើរដៃគូឯកជន និងតួនាទី និងការទទួលខុសត្រូវរបស់ភាគីដែលពាក់ព័ន្ធ។

- **ការកំណត់បុរេលក្ខណៈវិនិច្ឆ័យ៖** ជាជំហានដំបូងនៃប្រតិបត្តិការគម្រោង។ នៅក្នុងនោះ ភាគីរដ្ឋត្រូវរៀបចំសំណើអំពីលក្ខណៈវិនិច្ឆ័យ ក្នុងគោលបំណងផ្តល់ពត៌មានទៅអោយវិនិយោគិនឲ្យបានជ្រាបអំពីលក្ខខណ្ឌពាណិជ្ជកម្មសំខាន់ៗមួយចំនួននៃគម្រោង និងស្តីពីដំណើរការរួមនៃការដេញថ្លៃ និងកត្តាវិនិច្ឆ័យសម្រាប់ជ្រើសរើសគុណសម្បត្តិ។ តាមរយៈការកំណត់បុរេលក្ខណៈវិនិច្ឆ័យនេះ ភាគីរដ្ឋអាចជ្រើសរើសបានក្រុមហ៊ុនមួយចំនួនដែលមានបទពិសោធន៍ សមត្ថភាព និងធនធាន ដើម្បីអនុវត្តគម្រោង។
- **ការដេញថ្លៃ៖** នៅក្នុងដំណាក់កាលនេះ ភាគីរដ្ឋត្រូវបញ្ជូនសេចក្តីព្រាងនៃកិច្ចសន្យាដែលខ្លួនបានរៀបចំទៅភាគីក្រុមហ៊ុនឯកជន ឬអ្នកដេញថ្លៃ ដើម្បីឲ្យដឹងពីឱកាស និងចំណុចសំខាន់មួយចំនួននៅក្នុងកិច្ចសន្យានេះ។ ប៉ុន្តែ ក្នុងករណីដែលភាគីក្រុមហ៊ុនឯកជនមានមន្ទិលចំពោះកិច្ចសន្យានេះ សិក្ខាសាលាត្រូវបានរៀបចំ និងសម្របសម្រួលដើម្បីស្រាយបំភ្លឺ និងបញ្ជាក់។ នៅក្នុងដំណាក់កាលនេះដែរ ការដេញថ្លៃអាចធ្វើឡើងបានពីរដំណើរការផ្សេងៗគ្នា ពោលគឺអាស្រ័យទៅតាមការសម្រេចចិត្តរបស់ភាគីទាំងសងខាង។ ទី១- ការដេញថ្លៃអាចធ្វើឡើងក្នុងរយៈពេលតែមួយដង ដោយឲ្យអ្នកដេញថ្លៃដាក់ស្នើទាំងឯកសារបច្ចេកទេស និងសំណើហិរញ្ញវត្ថុមកជាមួយគ្នា។ ទី២-អ្នកដេញថ្លៃត្រូវដាក់ស្នើអំពីគម្រោងបច្ចេកទេសសិន បន្ទាប់មកភាគីទាំងសងខាងអាចធ្វើការពិភាក្សាទៅលើគម្រោងផែនការដាក់ស្នើ និងអាចមានការកែសម្រួលឯកសារដេញថ្លៃក្នុងករណីចាំបាច់ មុននឹងឈានដល់ការចាប់ផ្តើមរៀបចំគម្រោងផែនការរួមទាំងខាងបច្ចេកទេស និងហិរញ្ញវត្ថុជាលើកចុងក្រោយ។
- **ការវាយតម្លៃ៖** នៅក្នុងការវាយតម្លៃនេះ ភាគីរដ្ឋ ឬទាំងសងខាងអាចសម្រេចចិត្តដោយផ្អែកទៅលើកត្តាហិរញ្ញវត្ថុជាមួយនឹងប្រព័ន្ធសម្រោមសំបុត្រពីរ ដែលក្នុងនោះ ជាដំបូងត្រូវបើកគម្រោងសំណើរបច្ចេកទេស និងវាយតម្លៃទៅលើគោលការណ៍ជាប់ ឬធ្លាក់។ ប្រសិនបើគម្រោងសំណើបច្ចេកទេសជាប់ សំណើហិរញ្ញវត្ថុត្រូវបានដាក់ឲ្យពិនិត្យ ដែលក្នុងនោះត្រូវបានវាយតម្លៃធៀបនឹងកត្តាវិនិច្ឆ័យ ដូចជាអត្រាតម្លៃទាបផុតសម្រាប់អ្នកប្រើប្រាស់ ឬចំណាយតិចបំផុតសម្រាប់រដ្ឋាភិបាលទទួលបន្ទុក។
- **ការចរចារចុងក្រោយ៖** យោងតាមលទ្ធផលនៃការវាយតម្លៃ អ្នកដេញថ្លៃដែលឈ្នះត្រូវបានជ្រើសរើស និងធ្វើការចរចារចុងក្រោយមុននឹងឈានដល់ការចាប់ផ្តើមអនុវត្ត។ ការ

ចរចារបែបនេះ ក្នុងគោលបំណងដើម្បីបញ្ជាក់អំពីបញ្ហាដែលនៅសេសសល់ និងធ្វើបច្ចុប្បន្នកម្មកិច្ចសន្យា ស្របតាមការស្នើជាក់លាក់ណាមួយរបស់អ្នកឈ្នះការដេញថ្លៃ។ ប៉ុន្តែ នៅក្នុងនោះ ពុំមានការផ្លាស់ប្តូរខាងសម្ភារៈណាមួយឡើយ ដែលបានព្រមព្រៀងនៅក្នុងដំណើរការនៃការដេញថ្លៃ។

**៤-ដំណាក់កាលនៃការគ្រប់គ្រងគម្រោង៖** ភាពជោគជ័យនៃគម្រោងដែលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តម្រូវឲ្យមានដំណាក់កាលនេះជាចាំបាច់ ពោលគឺត្រូវរៀបចំនីតិវិធីច្បាស់លាស់សម្រាប់ការគ្រប់គ្រងគម្រោង និងចែករំលែកធនធានឲ្យបានគ្រប់គ្រាន់ដើម្បីពិនិត្យតាមដានការបំពេញការងាររបស់ដៃគូឯកជន និងមានការផាកពិន័យក្នុងករណីចាំបាច់។ នៅក្នុងនោះ ទាមទារឲ្យមានការទំនាក់ទំនងគ្នាប្រកបដោយប្រសិទ្ធភាពរវាងភាគីទាំងសងខាងផងដែរ។ ការទាម ទារអាចការធ្វើរបាយការណ៍អំពីការវឌ្ឍភាពនៃគម្រោងទៅដល់ភាគីឯកជនជាដើម។ នីតិវិធីពីរផ្សេងទៀតនៅក្នុងដំណាក់កាលនេះរួមមាន ការបង្កើតពិធីការ និងការបង្កើតយន្តការដោះស្រាយជម្លោះ។ ចំពោះការបង្កើតពិធីការ អាចផ្តល់ឱកាសអោយមានការចរចារម្តងទៀតទៅលើកិច្ចសន្យា ប្រសិនបើមានព្រឹត្តការណ៍ដែលនឹងស្មានមិនដល់។ ចំណែកឯការបង្កើតយន្តការដោះស្រាយជម្លោះ អាចធ្វើការដោះស្រាយទៅលើភាពខុសគ្នានៃមតិរវាងភាគីរដ្ឋ និងភាគីក្រុមហ៊ុនឯកជនឲ្យបានឆាប់រហ័ស និងមានយុត្តិធម៌។

### ២.២.៣.១.៤-គុណសម្បត្តិ និងគុណវិបត្តិនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន

បើទោះបីជាយន្តការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន បានផ្តល់នូវចំណុចវិជ្ជមាន និងមានការអនុវត្តយ៉ាងទូលំទូលាយក៏ពិតមែន ប៉ុន្តែនៅក្នុងនេះវាក៏បានជះឥទ្ធិពលមួយចំនួនផងដែរសម្រាប់ភាគីទាំងសងខាង។

ខាងក្រោមនេះ ជាគុណសម្បត្តិ និងគុណវិបត្តិសម្រាប់ភាគីទាំងសងនៅក្នុងការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន៖

**ក. ភាគីរដ្ឋ**

- **គុណសម្បត្តិ៖**
  - រដ្ឋាភិបាលមិនសូវជាទទួលរងនូវសម្ពាធថវិកាជាតិ តាមរយៈការធ្វើហិរញ្ញប្បទានទៅឲ្យភាគីឯកជន មានន័យថាថវិកាជាតិទទួលបាននូវភាពធូរស្រាលក្នុងរយៈពេលខ្លី និងបានជួយដោះស្រាយបញ្ហាហិរញ្ញវត្ថុនៃគម្រោងបានខ្លះ។

- សេវាសាធារណៈរបស់រដ្ឋ មានប្រសិទ្ធភាព និងសក្តិសិទ្ធិភាព តាមរយៈការផ្តល់សិទ្ធិទៅឲ្យវិស័យឯកជនក្នុងការជួយលើកកម្ពស់ក្នុងការគ្រប់គ្រង និងប្រើប្រាស់បច្ចេកទេសទំនើបឲ្យមានគុណភាពខ្ពស់។ ឧទាហរណ៍ ប្រសិនបើគម្រោងទាក់ទងទៅនឹងវិស័យហេដ្ឋារចនាសម្ព័ន្ធ វាបង្កើតឲ្យមានការដោះស្រាយរយៈពេលយូរ ដើម្បីផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធសាធារណៈមានគុណភាពស្របតាមស្តង់ដារ និងទទួលបានការថែទាំគ្រប់គ្រាន់។
- រដ្ឋអាចបង្កើនប្រាក់ចំណូលពីទ្រព្យសម្បត្តិមានពីមុនមកស្រាប ពីព្រោះរដ្ឋមានភាគីប្រតិបត្តិការឯកជន ដែលមានសមត្ថភាពគ្រប់គ្រាន់ដែលអាចធ្វើឲ្យគម្រោងសង្ឃឹមនឹងទទួលបានជោគជ័យខ្ពស់។

- **គុណវិបត្តិ៖**
  - បង្កធ្វើឲ្យអ្នកទទួលសេវាសាធារណៈ មិនពេញចិត្តចំពោះតម្លៃដែលភាគីឯកជនបានកំណត់ ពីព្រោះថាការអនុវត្តគម្រោងតាមយន្តការ ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន គឺមានការចំណាយប្រតិបត្តិការខ្ពស់ដែលក្រុមហ៊ុនក្នុងស្រុកមួយចំនួនសឹងតែមិនមានលទ្ធភាព។ ដូចនេះ គោលការណ៍នៃការកំណត់ថ្លៃសេវាក៏កំណត់ទៅតាមនឹងដែរ។
  - សុចនាករនៃគម្រោងអាចនឹងមិនទទួលបានលទ្ធផលល្អ ប្រសិនបើភាគីរដ្ឋមិនមានសិទ្ធិគ្រប់គ្រាន់ក្នុងការឃ្លាំមើលការថែរក្សាទ្រព្យសម្បត្តិ។ ដូចនេះ ការធ្វើការកែប្រែទម្រង់ផ្ទៃក្នុងនៃភាគីរដ្ឋ ដូចជាកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្រ ដើម្បីបង្កើតឲ្យមានប្រព័ន្ធការឃ្លាំមើលគឺជារឿងដ៏សំខាន់មួយ ក្នុងគោលបំណងធានាថាកិច្ចសន្យាអនុវត្តទៅតាមការរៀបចំដែលបានគ្រោងទុក។ ឧទាហរណ៍៖ នៅក្នុងបទបញ្ញត្តិ ភាគីរដ្ឋអាចឃ្លាំមើលប្រតិបត្តិការឯកជនពីការប្រព្រឹត្តិអំពើខុសច្បាប់ ឬកេងចំណេញពីស្ថានភាពផ្តាច់មុខរបស់ពួកគេ ដោយទាមទារយកតម្លៃសេវាខ្ពស់ពីអ្នកប្រើប្រាស់។
  - ទោះបីជាតម្រូវការលើហិរញ្ញវត្ថុសាធារណៈមានការថយចុះក៏ដោយ រដ្ឋាភិបាលនៅតែធានាផ្តល់ការឧបត្ថម្ភ និងការធានាដោយរដ្ឋ តាមរយៈការទូទាត់ថវិកាដោយទៀងទាត់ទៅឲ្យភាគីឯកជន ក្នុងលក្ខខ័ណ្ឌដូចបានកំណត់ក្នុងកិច្ចសន្យា។

**ខ. ភាគីឯកជន**

- **គុណសម្បត្តិ៖**
  - ទទួលបានប្រាក់កម្រៃពីការបណ្តាក់ទុនខ្លះ ទោះបីជាខ្លួនត្រូវចំណាយលើការគ្រប់គ្រងគម្រោងស្ទើរតែទាំងស្រុង។ ប្រាក់កម្រៃនោះអាចបានមកពីការប្រើប្រាស់ទៅលើគម្រោងរបស់ខ្លួន ឬប្រាក់ចំណូលបន្ថែមដែលអាចរកបានពីទ្រព្យសម្បត្តិសាធារណៈដ៏ទៃទៀត។ ប្រាក់ទាំងនោះ អាចជួយដោះស្រាយបញ្ហាថវិកានៃគម្រោងបានមួយរយៈពេល។
  - ភាគីឯកជនមិនសូវមានការភ័យខ្លាចទៅលើហានិភ័យផ្នែកពាណិជ្ជកម្ម និងហិរញ្ញវត្ថុរបស់ខ្លួន ពីព្រោះថាកិច្ចសន្យាគឺមានរយៈពេលវែង ដែលជាហេតុធ្វើឲ្យខ្លួនអាចទទួលបានប្រាក់ចំណេញលើការបណ្តាក់ទុនវិនិយោគលើប្រតិបត្តិការក្នុងរយៈពេលយូរ។
- **គុណវិបត្តិ៖**
  - ភាគីខាងឯកជនអាចនឹងទទួលបានហានិភ័យខ្ពស់ជាងភាគីរដ្ឋ ពីព្រោះថាភាគីរដ្ឋមានសិទ្ធិផ្ទេរហានិភ័យមួយចំនួនទៅឲ្យភាគីឯកជនដូចជា ផ្នែកប្រតិបត្តិការ និងការថែទាំជាដើម។
  - ទោះបីជាភាគីឯកជនទទួលបានការយល់ព្រមនូវលក្ខខ័ណ្ឌ ដូចមានចែងក្នុងការអនុវត្តកិច្ចសន្យាក៏ពិតមែន ប៉ុន្តែខ្លួននៅតែស្ថិតក្រោមការគ្រប់គ្រងដោយភាគីរដ្ឋ ពោលគឺភាគីរដ្ឋដើរតួនាទីជាបញ្ញត្តិករ។

### ២.២.៤-ឯកជនភាវូបនីយកម្មនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

ជាការពិតណាស់ថា ការធ្វើឯកជនភាវូបនីយកម្មអាចនាំមកនូវគ្រោះមហន្តរាយ ជាពិសេសទៅដល់សេដ្ឋកិច្ចជាតិទាំងមូល។ ប៉ុន្តែក្នុងករណីនេះ មិនមែនមានន័យថាវាជាហេតុផលមួយដែលរារាំងដល់ដំណើរការនៃការអនុវត្តឯកជនភាវូបនីយកម្មនោះទេ។ ដូចនេះ ដើម្បីជួយសម្រួលដល់ដំណើរការ និងមហិច្ឆតានៃការអនុវត្តឯកជនភាវូបនីយឲ្យទទួលបានជោគជ័យ ជាពិសេសនោះនៅក្នុងប្រទេសកំពុងអភិវឌ្ឍ មានគោលការណ៍ ឬវិធីសាស្ត្រមួយចំនួនដែលតម្រូវឲ្យធ្វើការពិចារណាឲ្យបានល្អិតល្អន់មុននឹងឈានដល់ការសម្រេចចិត្ត។ គោលការណ៍ ឬវិធីសាស្ត្រនោះរួមមានជាអាទិ៍

ប្រសិទ្ធភាពនៃច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធ ភាពច្បាស់លាស់នៃគោលនយោបាយ តុល្យភាពរវាងសេដ្ឋកិច្ចជាតិ និងឯកជន និង សន្តិភាព និងស្ថេរភាពនយោបាយនៃប្រទេសជាតិ។

### ២.២.៤.១-ប្រសិទ្ធភាពនៃច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធ

ការអនុវត្តឯកជនភាវូបនីយកម្ម តម្រូវឲ្យមានជាសំខាន់ណាស់នូវការចូលរបស់វិនិយោគិនទាំងក្នុង និងក្រៅប្រទេស ប៉ុន្តែដើម្បីជាថ្នូរនឹងការចូលរួម ភាគីរដ្ឋត្រូវរកវិធីសាស្ត្រដែលអាចជាទីទុក ចិត្តសម្រាប់ធ្វើការទាក់ទាញដល់វិនិយោគិនទាំងអស់នោះ។ សម្រាប់រដ្ឋាភិបាល វិធីសាស្ត្រជាចម្បងត្រូវតែមានច្បាប់ និងស្ថាប័នរដ្ឋបាលដែលមានមុខងារអនុវត្តត្រឹមត្រូវ[89]។ នៅក្នុងច្បាប់ទាំងអស់នោះ ចាំបាច់តម្រូវឲ្យមានការពង្រឹង ដូចជាការអនុវត្តនូវសិទ្ធិលើទ្រព្យសម្បត្តិឯកជន មានច្បាប់កិច្ចសន្យា ច្បាប់សហគ្រាសនានា ក៏ដូចជាការបង់ពន្ធដារដ៏ត្រឹមត្រូវច្បាស់លាស់ និងយុត្តិធម៌។ ក្រៅពីនេះ វាក៏ត្រូវតែមានផងដែរអំពីទីផ្សារហិរញ្ញវត្ថុ ការប្រកួតប្រជែង និងភាពផ្តាច់មុខទាំងឡាយ។ ចំពោះការប្រកួតប្រជែង វាជាធាតុមួយដ៏សំខាន់ ពីព្រោះថាវាអាចធ្វើឲ្យមានការរីកចម្រើននៅក្នុងការអនុវត្ត ពោលគឺវាជួយឲ្យប្រតិបត្តិការមានប្រសិទ្ធភាពខ្ពស់ និងរួមបញ្ចូលទាំងការចំណាយតិច[90]។ ចំណែកស្ថាប័នរដ្ឋបាលវិញ តម្រូវឲ្យមានសមត្ថភាពខ្ពស់ មានន័យថាត្រូវតែមានអភិបាលកិច្ចល្អ ពីព្រោះថាការអនុវត្តឯកជនភាវូបនីយកម្ម អាចជាឧបសគ្គប្រសិនបើការប្តេជ្ញាចិត្តជាពិសេសខាងនយោបាយនៅមានកម្រិត និងមិនបង្កើតឲ្យមានបរិយាកាសនៃទិសដៅទីផ្សារ ពោលគឺមិនបានបំពេញតម្រូវការរបស់អ្នកទទួលសេវា[91]។

### ២.២.៤.២-ភាពច្បាស់លាស់នៃគោលនយោបាយ

នៅក្នុងប្រតិបត្តិការនៃឯកជនភាវូបនីយកម្ម ការចូលរួម និងអភិបាលកិច្ចល្អរបស់រដ្ឋាភិបាលក្នុងការបង្កើតច្បាប់មិនទាន់មានភាពគ្រប់គ្រាន់នៅឡើយទេ។ ក្នុងករណីនេះ តម្រូវឲ្យមានការបង្កើតនូវភាពច្បាស់លាស់នៃគោលនយោបាយ។ ចំពោះពាក្យ "គោលនយោបាយ" នៅកន្លែងចង់សំដៅដល់គោលនយោបាយសាធារណៈ ដែលបង្កើតឡើងដោយរដ្ឋាភិបាល ឬជាសេចក្តីសម្រេចចិត្តរបស់រដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាឲ្យប្រជាពលរដ្ឋ[92]។ ដូចនេះ ដើម្បីជួយសម្រួលដល់

---

[89] កៅ មុយថង (២០០៧), រដ្ឋបាលសាធារណៈទំនើប, ទំព័រ១៦៥។

[90] Estrin, S. & Pelletier, A. (2018). *Privatization in Developing Countries: What Are the Lessons of Recent Experience?*. Published by Oxford University Press.

[91] Asian Development Bank (ADB) (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries.*

[92] សាស្ត្រាចារ្យ ឈុន ណារ៉េត និង សាស្ត្រាចារ្យ ខៀវ វិជ្ជានន្ទ, *គោលនយោបាយសាធារណៈ*, ទំព័រ៤។

ដំណើរការនៃការអនុវត្តឯកជនភាវូបនីយកម្ម មានគោលនយាបាយមួយចំនួនដែលរដ្ឋាភិបាលត្រូវតែរៀបចំឡើង និងធ្វើឲ្យមានភាពពិតប្រាកដ ដូចជាគោលនយោបាយដោយផ្តោតជាសំខាន់ទៅលើផលប្រយោជន៍សង្គម និងសេដ្ឋកិច្ច។ ក្រៅពីនេះ នៅក្នុងគោលនយោបាយទាំងអស់នោះ អាចបញ្ជាក់អំពីតួនាទី អំណាចរវាងភាគី និងការទទួលខុសត្រូវរវាងភាគីទាំងសងខាងផងដែរ។

**២.២.៤.៣-តុល្យភាពរវាងសេដ្ឋកិច្ចជាតិ និងឯកជន**

នៅពេលដែលសេដ្ឋកិច្ចជាតិមានភាពខ្លាំង និងរីកចម្រើនដូចខាងវិស័យឯកជន នៅពេលនោះកម្លាំងកម្មករត្រូវបានសម្របសម្រួល ពោលគឺមិនត្រូវបានប្រើប្រាស់ហួសការកំណត់។ ក្រៅពីនេះ វាក៏បានជួយកាត់បន្ថយនូវការចំណាយថ្លៃសង្គមដែលមិនពាក់ព័ន្ធផងដែរ បន្ទាប់ពីធ្វើការពិចារណា។ ផ្ទុយទៅវិញ ក្នុងស្ថានភាពដែលប្រទេសជាតិមានវិបត្តិសេដ្ឋកិច្ច ការធ្វើឯកជនភាវូបនីយកម្មពិតជាមិនអាចទទួលបានជោគជ័យជាដាច់ខាត។[93]

**២.២.៤.៤-សន្តិភាព និងស្ថេរភាពនយោបាយនៃប្រទេសជាតិ**

យើងគួរកត់សម្គាល់ថា ឯកជនភាវូបនីយកម្ម គឺជាដំណើរការប្រកបដោយនយោបាយ។[94] នៅក្នុងករណីនេះ រដ្ឋាភិបាលត្រូវធានាកិច្ចការពារប្រទេសជាតិជាពិសេស រួមបញ្ចូលទាំងស្ថេរភាព និងសុខមាលភាពសង្គមជាដើម ក្នុងគោលបំណងផ្តល់ឱកាស និងសេចក្តីទុកចិត្តទៅដល់វិស័យក្នុងការចូលរួមទៅក្នុងសកម្មភាពសាធារណៈឲ្យបានទូលំទូលាយ។

[93] កៅ មុយថង (២០០៧), *រដ្ឋបាលសាធារណៈ:ទំនើប*, ទំព័រ១៦៣-១៦៤។

[94] កៅ មុយថង (២០០៧), *រដ្ឋបាលសាធារណៈ:ទំនើប*, ទំព័រ១៥៥។

# ជំពូកទី៣

# ឯកជនភាវូបនីយកម្ម និងយន្តការ

# ភាពជាដៃគូរវាងរដ្ឋ និងឯកជន

# នៅកម្ពុជា

# ជំពូកទី៣

# ឯកជនភាវូបនីយកម្ម និងភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា

## ៣.១-សាវតាសង្ខេបនៃការអនុវត្តឯកជនភាវូបកម្មនៅកម្ពុជា

ដូចបានលើកឡើងពីខាងដើមរួចហើយថា យន្តការនៃឯកជនភាវូបនីយកម្មនៅកម្ពុជាត្រូវបានអនុវត្តដំបូងនៅក្នុងឆ្នាំ១៩៨៥ ក្រោមរូបភាពជាការវិនិយោគទៅលើការអភិវឌ្ឍន៍វិស័យហេដ្ឋារចនាសម្ព័ន្ធ។ នៅក្នុងសម័យកាលនោះ សករាជថ្មីនៃឯកជនភាវូបនីយកម្មនៅកម្ពុជា ប្រព្រឹត្តទៅបានដោយសារការគាំទ្រផ្នែកកម្ចី និងជំនួយផ្នែកបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB)។ កម្មវត្ថុជាចម្បងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដែលផ្តល់ដល់បណ្តាប្រទេសសមាជិកកំពុងអភិវឌ្ឍដូចជាប្រទេសកម្ពុជា គឺជម្រុញអោយមានការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការធ្វើឲ្យមានការរីកចម្រើនទៅលើវិស័យឧស្សាហកម្ម ដោយមានការលើកទឹកចិត្តទៅដល់ក្រុមហ៊ុនឯកជនក្នុងការចូលរួមទៅលើសកម្មភាពសាធារណៈក្នុងនាមជាដៃគូអភិវឌ្ឍន៍។ ក្រៅពីនេះ វាក៏ត្រូវបានផ្តោតជាសំខាន់ផងដែរ ដើម្បីជានាំឲ្យមានកំណើនទៅលើផលិតកម្មកសិកម្ម និងឧស្សាហកម្ម ថាមពល ការដឹកជញ្ជូន និងការតភ្ជាប់នៃហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនលទ្ធភាព ដើម្បីផ្តល់ឥណទានសម្រាប់ការអភិវឌ្ឍវិស័យឯកជននៅក្នុងចន្លោះឆ្នាំ១៩៨៤ ទៅដល់ទសវត្សឆ្នាំ១៩៩០។[95]

នៅក្នុងជំហានដំបូងនៃការអនុវត្តឯកជនភាវូបនីយកម្មនៅប្រទេសកម្ពុជា គឺមានលក្ខណៈខុសពីសមាជិកប្រទេសកំពុងអភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីដទៃទៀតត្រង់ថា ប្រទេសកម្ពុជាមិនបានបើក ឬផ្តល់ឱកាសឲ្យក្រុមហ៊ុនវិនិយោគអន្តរជាតិចូលរួមក្នុងការធ្វើជាភាគីនៃកិច្ចសន្យានៅក្នុងដំណើរការនៃការអនុវត្តឯកជនភាវូបនីយកម្មនោះទេ។[96] ប៉ុន្តែ វិធានការបែបនេះត្រូវបានផ្លាស់ប្តូរ និងមានការលើកទឹកចិត្តយ៉ាងទូលំទូលាយ ក្រោយពេលដែលប្រទេសកម្ពុជាបានបោះជំហានយ៉ាងស្វាហាប់ចាកចេញពីប្រទេសមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ នៅក្នុងនោះផងដែរ រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំវិនិយោគយ៉ាងគំហុក និងប្រកបដោយវិចារណកម្មខ្ពស់លើការសាងសង់ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងរៀបចំ និងបង្កើត ឬធ្វើវិសោធនកម្មទៅលើក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្តិ និង

[95] ADB. (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries*.

[96] ADB. (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries*.

យន្តការស្ថាប័នបន្ថែមទៀត ពីព្រោះថាផ្នែកមួយដែលសំខាន់សម្រាប់ការអភិវឌ្ឍនៅកម្ពុជា ជាពិសេសទៅលើកំណើនសេដ្ឋកិច្ច កើតចេញពីក្បាលម៉ាស៊ីននៃវិស័យឯកជន ដែលត្រូវបានសង្កេតឃើញក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះ។ គោលនយោបាយ និងច្បាប់មួយ ក្នុងចំណោមនោះបាននឹងកំពុងដាក់ឲ្យអនុវត្ត និងដំណើរការ ដែលក្នុងនោះរដ្ឋាភិបាលសង្ឃឹមថានឹងមានការអនុវត្តប្រកបដោយប្រទាក់ក្រឡា និងគ្រប់ជ្រុងជ្រោយនៅមុនដំណាច់ឆ្នាំ២០២០ និងដើម្បីអោយស្របតាមឧត្តមានុវត្តជាអន្តរជាតិ។

### ៣.២-គោលបំណងនៃភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា

នៅចន្លោះជាងមួយទសវត្សចុងក្រោយនេះ ប្រទេសកម្ពុជាដើបឡើងក្នុងសន្ទុះលឿនគួរឲ្យកត់សម្គាល់ ពោលគឺបានធ្វើឲ្យកម្ពុជាទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ នៅក្នុងសន្ទុះទៅលើការអភិវឌ្ឍនេះ គឺជាផ្នែកមួយនៃការវិនិយោគរបស់វិស័យឯកជនចំពោះសហគ្រាសសាធារណៈក្រោម ឧបករណ៍នៃឯកជនភាវូបនីយកម្មដែលបានដាក់ឲ្យអនុវត្តកន្លងមក។ ដូចនេះ ដើម្បីបំពេញបំណងប្រាថ្នារបស់ប្រទេសកម្ពុជា រដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយថ្មីមួយនៅក្នុងឆ្នាំ២០១៦ ដែលត្រូវបានស្គាល់ថា "គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"។

គោលនយោបាយខាងលើនេះ បានបង្កើតឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានគោលបំណងដូចខាងក្រោម៖

- ជម្រុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការចូលរួមស្តារ កសាង ជួសជុល ប្រតិបត្តិការ និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។
- បង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង។
- បង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ច និងសកលលោក។

ក្រៅពីនេះ ដើម្បីសម្រេចនូវគោលបំណងនេះ រាជរដ្ឋាភិបាលមានគោលដៅដាក់ចេញនូវយុទ្ធសាស្ត្រ កំណត់យន្តការស្ថាប័ន និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព សង្គតិភាព និងភាពប្រទាក់ក្រឡាគ្នា ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។[97]

## ៣.៣-ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ

បច្ចុប្បន្នភាពនៃច្បាប់នៅក្នុងប្រទេសកម្ពុជា សម្រាប់ជម្រុញ និងលើកទឹកចិត្តវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ឲ្យចូលរួមវិនិយោគសាធារណៈរួមមាន[98]៖

- ច្បាប់ស្តីពីការវិនិយោគ
- ច្បាប់ស្តីពីសម្បទាន
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- ច្បាប់ស្តីពីភូមិបាល
- ច្បាប់ស្តីពីផ្លូវថ្នល់
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានការធានា
- ច្បាប់ស្តីពីសារពើពន្ធ
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- ច្បាប់ស្តីពីមូលបត្ររដ្ឋ
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- ច្បាប់ស្តីពីអស្សាមិករណ៍
- ច្បាប់ស្តីពីគណេយ្យ និងសវនកម្ម
- ច្បាប់ស្តីពីគយ

[97] រាជរដ្ឋាភិបាលកម្ពុជា (២០១៦), *ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (២០១៦-២០២០)*។

[98] រាជរដ្ឋាភិបាលកម្ពុជា (២០១៦), *ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (២០១៦-២០២០)*។

- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ និង
- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។

ប៉ុន្តែ បើទោះបីជាមានលិខិតបទដ្ឋានគតិ យុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍ដូចបានបកស្រាយខាងលើរួចក្តី ការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ជាពិសេសតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ ពីព្រោះថាវាមិនទាន់បានបំពេញល័ក្ខខ័ណ្ឌតម្រូវជាសារវន្ត ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ដូច្នេះ ដើម្បីបំពេញនូវតម្រូវការកាលានុវត្តភាពថ្មីៗ និងតបតាមសំណើររបស់វិនិយោគិន រដ្ឋាភិបាលកម្ពុជាបាននឹងកំពុងខិតខំបង្កើតនូវគោលនយោបាយមួយ ដើម្បីគ្រប់គ្រងទៅលើយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ នៅក្នុងគោលនយោបាយនោះត្រូវបានគេស្គាល់ថាជា "គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"។ ក្រៅពីគោលនយោបាយនេះ រដ្ឋាភិបាលក៏បាននឹងកំពុងធ្វើសេចក្តីព្រាងច្បាប់ សម្រាប់គ្រប់គ្រងទៅលើយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។ ក្នុងសេចក្តីព្រាងច្បាប់នេះ បានផ្តោតជាសំខាន់តាមការចង្អុលបង្ហាញ និងការកំណត់នៅក្នុងឯកសារគោលនយោ បាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រងគ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០។ នៅក្នុងនោះរួមមាន៖

- ការរៀបចំស្ថាប័ន និងការទទួលខុសត្រូវដើម្បីធានាការប្រើប្រាស់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជនឲ្យបានត្រឹមត្រូវ និងជាប្រយោជន៍ជូនសាធារណៈ។
- ការបង្កើតក្របខ័ណ្ឌសម្រាប់ការរៀបចំការអនុវត្ត និងការត្រួតពិនិត្យគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។
- ការបង្កើតនីតិវិធីលទ្ធកម្ម សម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។

- កំណត់យន្តការគាំទ្រនានាពីភាគីរដ្ឋ ការលើកទឹកចិត្តលើការវិនិយោគ និងកាតព្វកិច្ចដទៃដែលមានចែងក្នុងកិច្ចសន្យា។[99]

## ៣.៤-គណៈកម្មការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅកម្ពុជា

ដើម្បីសម្រួលដល់ដំណើរការនៃការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅកម្ពុជា ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល បានរៀបចំគណៈកម្មការមួយដែលមានសមាសភាពដូចខាងក្រោម៖[100]

| | | |
|---|---|---|
| - ឯកឧត្តម វង្សី វិស្សុត | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - ឯកឧត្តម ហែម វណ្ណឌី | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| - ឯកឧត្តម ជា វុទ្ធី | អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| - ឯកឧត្តម ថេង បញ្ញាធន | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការនៃក្រសួងផែនការ | អនុប្រធាន |
| - ឯកឧត្តម ហ៊ីង ថូរ៉ាក់ស៊ី | រដ្ឋលេខាធិការទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - លោកជំទាវ ប៉ែន ឆដា | រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពល | សមាជិក |
| - ឯកឧត្តម នូ សុវត្ថិ | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - លោកជំទាវ តឹករ៉េក កំរង | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| - ឯកឧត្តម គីម ទូច | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| - ឯកឧត្តម ម៉ម អំណត់ | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង និងនេសាទ | សមាជិក |
| - ឯកឧត្តម ទេព ធន | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

[99] Fresh News (២៨ មករា ២០១៩), "*រាជរដ្ឋាភិបាលកំពុងរៀបចំសេចក្ដីព្រាងច្បាប់ស្ដីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន*"។

[100] ប្រការ១៖ លិខិតលេខ០៥០ សហវ នៃសេចក្ដីសម្រេចស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្ដីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

- ឯកឧត្តម សៅ សុភាព ទីប្រឹក្សាអមក្រសួង និងជានាយកខុទ្ទកាល័យក្រសួងបរិស្ថាន សមាជិក
- ឯកឧត្តម សុង តុងហាប់ អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក
- ឯកឧត្តម ជិន ម៉ាលីន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក
- ឯកឧត្តម ចាប ឬទ្ធី អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សមាជិក
- ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ សមាជិក
- ឯកឧត្តម ប្រាក់ សំអឿន អគ្គនាយនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ សមាជិក
- ឯកឧត្តម គុណ ញឹម អគ្គនាយកនៃអគ្គនាយដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក
- ឯកឧត្តម ហាវ រតនៈ អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា សមាជិក
- ឯកឧត្តម អ៊ឹម សិទ្ធីរ៉ា អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ សមាជិក
- ឯកឧត្តម ប៉ែន ធីរុង្គ អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល សមាជិក
- លោក គីមទី កោមលី អគ្គនាយករងបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា សមាជិក
- លោក ស៊ីន ចាន់សេរីវុត្ថា អគ្គនាយករងនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក
- លោក ចន ណារិទ្ធ អគ្គនាយករងនៃអគ្គនាយដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ សមាជិក
- លោក ស៊ាង ផល្លា ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម សមាជិក

សមាសភាពរបស់គណៈកម្មការអន្តរក្រសួង ដែលបង្កើតឡើងដើម្បីដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍន៍យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានមុខងារ និងភារកិច្ចដូចខាងក្រោម៖[101]

- ពិនិត្យឡើងវិញលើបទបញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងរៀបចំ និងផ្តល់អនុសាសន៍ក្នុងធ្វើវិសោធនកម្ម ឬធ្វើសំណើរៀបចំសេចក្តីព្រាងច្បាប់ថ្មីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមការចាំបាច់។
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាព រួមទាំងគម្រោងដែលនឹងដាក់ឲ្យអនុវត្តសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- បូកសរុបរបាយការណ៍ប្រចាំឆមាស និងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នៅក្នុងការដឹកនាំការអនុវត្តគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន របស់គណៈកម្មការដូចបានរៀបរាប់ខាងលើ គឺមានក្រុមការងារបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលបន្ថែមទៀត ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមានសមាសភាពដូចខាងក្រោម៖

- ឯកឧត្តម ប៉ែន ធីរុង្គ អគ្គនាយកនៃអគ្គនាយដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ប្រធាន
- លោក រស់ បរម អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា អនុប្រធាន

[101] ប្រការ២៖ លិខិតលេខ០៥០ សហវ នៃសេចក្តីសម្រេចស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

| | | |
|---|---|---|
| - លោក ម៉ាង សុភារ៉ា | ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុលនៃអគ្គនាយកសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | អនុប្រធាន |
| - លោក វង្សី វិចិត្រ | អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| - លោក ឱម ម៉ាក់ធារិទ្ធ | អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| - លោក ហុល បុណ្ណារ័ត្ន | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគីនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| - លោក ចាន់ សុបញ្ញាវ័ន្ត | អនុប្រធានការិយាល័យសហប្រតិបត្តិការពហុភាគីទី១នៃនាយដ្ឋានសហប្រតិបត្តិការពហុភាគី | សមាជិក |

- ការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជននៃនាយកដ្ឋានវិនិយោគ សមាជិក
- ការិយាល័យវិភាគបំណុលនៃនាយកដ្ឋានគ្រប់គ្រងបំណុល សមាជិក

សមាសភាពក្រុមការងារបច្ចេកទេស ដូចបានរៀបរាប់ខាងលើ មានភារកិច្ចដូចខាងក្រោម៖

ក-សម្របសម្រួល និងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ខ-ផ្តល់ការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចចុះកិច្ចសន្យាជាមួយដៃគូឯកជន ក្នុងការកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងការអនុវត្តគម្រោង។

គ-ពិនិត្យ និងតាមដានលើកិច្ចប្រតិបត្តិការនៅគ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ឃ-ផ្តល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងលើការអនុវត្ត និងធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ង-គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់គាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារសិក្សា និងការរៀបចំគម្រោង ព្រមទាំងប្រតិបត្តិការនានាដើម្បីឈានដល់ការប្រគល់កិច្ចសន្យាអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ច-តាមដានត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួង។

ឆ-បំពេញភារកិច្ចពាក់ព័ន្ធផ្សេងៗទៀត ស្របតាមការកំណត់របស់ប្រធានគណៈកម្មការអន្តរក្រសួង។

## ៣.៥-ទ្រព្យសម្បត្តិរដ្ឋដែលជាកម្មវត្ថុនៃឯកជនភាវូបនីយកម្មនៅកម្ពុជា

ទ្រព្យសម្បត្តិរដ្ឋទាំងឡាយដែលជាកម្មសិទ្ធិ ឬការប្រើប្រាស់ អាចធ្វើជាកម្មវត្ថុនៃការផ្ទេរទៅឲ្យវិស័យឯកជន ភាគច្រើនឃើញមានតែសហគ្រាសសាធារណៈរួមមានជាអាទ៏គ្រឹះស្ថានសាធារណៈដែលមានលក្ខណៈសេដ្ឋកិច្ច ក្រុមហ៊ុនរដ្ឋ និងក្រុមហ៊ុនចម្រុះដែលក្នុងនោះរដ្ឋបានកាន់កាប់ដោយផ្ទាល់ ឬប្រយោលលើសពីហាសិបមួយភាគរយនៃដើមទុកក្រុមហ៊ុន ឬសិទ្ធិបោះឆ្នោត។

ដោយឡែកចំពោះគម្រោង ដែលដាក់ឲ្យអនុវត្តក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាកំណត់យកវិស័យអាទិភាពមួយចំនួនដូចខាងក្រោម៖[102]

- ប្រព័ន្ធគមនាគមន៍ដឹកជញ្ជូន ដូចជាផ្លូវថ្នល់ ស្ពាន ផ្លូវដែក ផែ និងអាកាសយានដ្ឋាន
- ការផលិត ការបញ្ជូន និងការចែកចាយថាមពលអគ្គិសនី
- ការផលិត ការផ្គត់ផ្គង់ និងការចែកចាយទឹកស្អាត
- ការអភិវឌ្ឍ ការធ្វើទំនើបភាវូបនីយកម្ម និងចំណតរថយន្តសាធារណៈ ឬមជ្ឈមណ្ឌលពាណិជ្ជកម្មសាធារណៈ
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈតំបន់ឧស្សាហកម្ម
- សេវាគ្រប់គ្រង និងសម្អាតកាកសំណល់

[102] រាជរដ្ឋាភិបាលកម្ពុជា (២០១៦), *ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (២០១៦-២០២០)*។

- ប្រព័ន្ធចម្រោះ និងប្រព័ន្ធបង្ហូរទឹកស្អុយ
- ការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ
- ហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋានសង្គមកិច្ច
- ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ដូចជារមណីយដ្ឋានទេសចរណ៍ សារមន្ទីរជាដើម
- វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និងវិស័យអាទិភាពផ្សេងៗទៀត។

សរុបមកវិញ បរិការណ៍បច្ចុប្បន្នភាពនៃការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ជាពិសេស យន្តការនៃភាពជាដៃគូរវាងរដ្ឋ និងឯកជន គឺមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយទេ សម្រាប់ឲ្យកម្ពុជាអាចធ្វើការប្រកួតប្រជែងទាំងក្នុងឆាកតំបន់ និងឆាកអន្តរជាតិ។ ដូចនេះសម្រាប់ប្រទេសកម្ពុជាមានតែជម្រើសពីរធំៗគឺ ទី១-អនុវត្តដោយអនុលោមទៅតាមគោលការណ៍មួយចំនួនដែលបានកំណត់ជាសកលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ និងទី២-រាជរដ្ឋាភិបាលផ្ទាល់ត្រូវតែបន្តជម្រុញ និងលើកទឹកចិត្តឲ្យក្រសួងស្ថាប័នមានសមត្ថកិច្ច ដើរតួនាទីជាយុទ្ធសាស្ត្រវិទូ អ្នកសម្របសម្រួល គាំទ្រ និងជាអ្នកផ្តួចផ្តើម ប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព។

# ជំពូកទី៤

# ករណីសិក្សានៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា

# ជំពូកទី៤

# ករណីសិក្សានៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា

ដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណពីដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៤ នៃរដ្ឋសភាបច្ចុប្បន្ន វិស័យអាទិភាពមួយក្នុងចំណោមវិស័យអាទិភាពជាច្រើន ត្រូវបានរដ្ឋាភិបាល ខិតខំវិនិយោគយ៉ាងគំហុក តាមរយៈការជម្រុញ និងផ្ដល់ឱកាសទៅដល់វិស័យឯកជន និងធ្វើការកៀរគរនូវប្រភពធនធានហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានា។ វិស័យអាទិភាពនោះ គឺការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងគោលបំណងឲ្យសេវាសាធារណៈនៅកម្ពុជាមានប្រសិទ្ធភាព ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និងពង្រឹងភាពប្រកួតប្រជែង។ល។

ដូចនេះ ដើម្បីធ្វើការឆ្លុះបញ្ចាំងអោយឃើញពីការចូលរួមរបស់វិស័យឯកជនទៅក្នុងវិស័យសាធារណៈក្រោមឧបករណ៍នៃឯកជនភាវូបនីយកម្ម នៅក្នុងជំពូកទី៤នេះនឹងលើកយកនូវករណីសិក្សាជាក់ស្ដែងមួយដែលកំពុងដាក់ឲ្យអនុវត្ត ពោលគឺពាក់ព័ន្ធនឹងការអភិវឌ្ឍទៅលើវិស័យហេដ្ឋារចនា សម្ព័ន្ធក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដូចបានបកស្រាយជាលក្ខណៈទ្រឹស្ដីនៅក្នុងជំពូកទី២ និងជំពូកទី៣។ ករណីសិក្សានេះផ្ដោតទៅលើ "គម្រោងសាងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ" ដែលបានបើកការដ្ឋានសាងសង់ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩។

ចំពោះពត៌មានលម្អិតទាក់ទងនឹងគម្រោងនេះត្រូវបានបញ្ជាក់ដូចខាងក្រោមៈ

## ៤.១-ពត៌មានទូទៅនៃគម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ

ដូចបានបញ្ជាក់ពីខាងដើម គម្រោងអភិវឌ្ឍទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធនោះគឺ "គម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ដែលក្នុងនោះបានដាក់ឲ្យអនុវត្តក្រោមទម្រង់វិនិយោគជា សាងសង់-ធ្វើអាជីវកម្ម-ផ្ទេរ (Build-Operate-Transfer)។ សម្រាប់គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុនេះ ត្រូវបានស្គាល់ថាជាគម្រោងដំបូងគេបំផុត និងជាប្រវត្តិសាស្ត្រ

នៅក្នុងព្រះរាជាណាចក្រកម្ពុជា[103] ដែលក្នុងនោះមានប្រវែងសរុប១៩០,០១ គីឡូម៉ែត្រ ដោយធ្វើការតភ្ជាប់ពីភូមិ១ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដល់ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហានុ ពោលគឺឆ្លងកាត់រាជធានីភ្នំពេញប្រវែង៨៣០ គីឡូម៉ែត្រ ខេត្តកណ្ដាលប្រវែង៩,១០ គីឡូម៉ែត្រ ខេត្តកំពង់ស្ពឺប្រវែង៨០,៨០ គីឡូម៉ែត្រ ខេត្តកោះកុង១,៩២ គីឡូម៉ែត្រ និងខេត្តព្រះសីហានុប្រវែង៨៩,៨៩ គីឡូម៉ែត្រ។

ចំពោះទទឹងផ្លូវសរុបនៃគម្រោង ត្រូវបានសាងសង់រហូតដល់២៨,៥ ម៉ែត្រ ដោយក្រាលបេតុងកៅស៊ូ (AC) កម្រាស់១០ សង់ទីម៉ែត្រ ទទឹង២៣ ម៉ែត្រ ដែលក្នុងនោះរួមមាន៖

- គន្លងផ្លូវធ្វើចរាចរណ៍សម្រាប់រថយន្ត ទទឹង១៥ ម៉ែត្រ ចែកជា៤ គន្លង (២គន្លងទៅ ២គន្លងមក) ដែលគន្លងនីមួយៗមានទទឹង៣,៧៥ ម៉ែត្រ ដែលអនុញ្ញាតឲ្យយានយន្តគ្រប់ប្រភេទអាចបើកបរក្នុងល្បឿនរហូតដល់១០០ គីឡូម៉ែត្រ ក្នុងមួយម៉ោង និងកន្លែងខ្លះអាចដល់១២០ គីឡូម៉ែត្រ ក្នុងមួយម៉ោង។
- ខឿនសួនចែកទិសចរាចរណ៍នៅចំកណ្ដាលទ្រូងផ្លូវ ដែលមានទទឹង៣ ម៉ែត្រ។
- ចិញ្ចើមផ្លូវក្រាលបេតុងកៅស៊ូ ទទឹង២,៥០ ម៉ែត្រ សងខាង និងចិញ្ចើមផ្លូវក្រាលក្រួសក្រហម ទទឹង០,៧៥ ម៉ែត្រ សងខាង។
- សាងសង់លូគ្រប់ប្រភេទចំនួន២៦៣ កន្លែង ស្ពានតូចចំនួន៥ កន្លែង ប្រវែងសរុប១០៥ ម៉ែត្រ ស្ពានធំ និងស្ពានមធ្យមចំនួន៨០ កន្លែង ប្រវែងសរុប៦.០១៥ ម៉ែត្រ។
- សាងសង់ផ្លូវប្ដូរទិសចរាចរណ៍ចំនួន៧ កន្លែង ផ្លូវប្រសព្វចំនួន២៨ កន្លែង ផ្លូវក្រោមផ្លូវល្បឿនលឿនចំនួន២៣៧ កន្លែង និងស្ពានរំលងផ្លូវចំនួន២០ កន្លែង។
- សាងសង់តំបន់សេវាកម្ម ឬចំណត់ឈប់សម្រាកចំនួន៣ កន្លែង ចំណតរថយន្តចំនួន១ កន្លែង មណ្ឌលប្រតិបត្តិការ និងថៃទាំផ្លូវចំនួន៤កន្លែង និងបញ្ជរបង់ប្រាក់ចំនួន៩ កន្លែង។
- បំពាក់គ្រឿងបរិក្ខាផ្លូវថ្នល់ រួមមានផ្លាកសញ្ញាចរាចរណ៍ ភ្លើងសញ្ញាចរាចរណ៍ និងគំនូសសញ្ញាចរាចរណ៍។

[103] ប្រសាសន៍របស់ឯកឧត្តមទេសរដ្ឋមន្ត្រី ស៊ុន ចាន់ថុល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ក្នុងឱកាសពិធីបើកការដ្ឋានសាងសង់គម្រោងផ្លូវល្បឿនលឿន។

ចំណែកឯថវិកាដែលចំណាយលើគម្រោងនេះជាទុនវិនិយោគរបស់ ក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC) ដែលចំណាយទឹកប្រាក់សរុបប្រមាណ២.០០០ លានដុល្លារអាមេរិក។ ក្រៅពីនេះ រដ្ឋាភិបាលចិនក៏បានផ្ដល់ហិរញ្ញប្បទានឥតសំណងចំនួនប្រមាណ១៥០ លានដុល្លារអាមេរិកផងដែរ ដើម្បីធ្វើជាវិភាគទានសម្រាប់គម្រោងខាងលើនេះ។

## ៤.២-នីតិវិធីនៃការរៀបចំគម្រោង

យោងតាមការលើកឡើងរបស់រាជរដ្ឋាភិបាល ប្រទេសកម្ពុជាមិនទាន់មានលក្ខណៈស្របតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយទេ ចំពោះគម្រោងវិនិយោគសាធារណៈមួយចំនួនជាពិសេសនៅក្នុងបច្ចុប្បន្នភាពនៃការអនុវត្តភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ដូចនេះ រដ្ឋាភិបាលមានតែជម្រើសមួយចំនួនក្នុងការចាប់យកនូវកាលានុវត្តភាព ដែលក្នុងនោះរួមមានជាអាទិ៍ការចាប់ផ្ដើមពិនិត្យ និងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្តិ និងការគោរពទៅតាមអភិក្រម "រៀនផង-ធ្វើផង" ជាដើមក្នុងគោលបំណងទទួលបានបទពិសោធន៍ជាក់ស្ដែង។

យ៉ាងណាមិញ ចំពោះ "គម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" នេះត្រូវបានសបញ្ជាក់ដ៏ច្បាស់ណាស់ ពោលគឺរដ្ឋាភិបាលមានតែផ្ដល់ឱកាសជាអាទិភាពទៅដល់ក្រុមហ៊ុនឯកជន ដើម្បីធ្វើការសិក្សាពីនីតិវិធីមួយចំនួន ប៉ុន្តែក្នុងករណីនេះមិនមែនមានន័យថារដ្ឋាភិបាលបានប្រគល់សិទ្ធិទាំងស្រុងទៅដល់ក្រុមហ៊ុនឯកជននោះទេ។ ជាការទប់ស្កាត់ រដ្ឋាភិបាលបានប្រើប្រាស់នូវច្បាប់ និងគោលនយោបាយដែលមានស្រាប់ រួមមានជាអាទិ៍ច្បាប់ស្ដីពីការវិនិយោគ និងច្បាប់ស្ដីពីសម្បទានជាដើម។ នៅក្នុងនីតិវិធីនៃការរៀបចំ "គម្រោងសាងសង់ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" នេះត្រូវបានប្រព្រឹត្តទៅដោយឆ្លងកាត់ដំណាក់កាលសំខាន់ៗដូចខាងក្រោមៈ

### ៤.២.១-ការចុះអនុស្សរណៈការយោគយល់

តាងនាមអោយរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ក្រសួងសាធារណការ និងដឹកជញ្ជូន បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយ ក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC) នៅក្នុងឆ្នាំ២០០៦។ នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នានេះ ផ្ដោតជាសំខាន់ទៅលើការរៀបចំគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវល្បឿនលឿន ដោយតភ្ជាប់ពីរាជធានីភ្នំពេញ ទៅកាន់ក្រុងព្រះសីហនុ។

### ៤.២.២-ការធ្វើអត្តសញ្ញាណកម្មគម្រោង

ជាមួយនឹងការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC) បានធ្វើការសិក្សា បទបង្ហាញ និងពិភាក្សាជាច្រើនលើកច្រើនសារជាមួយក្រសួងស្ថាប័នដែលពាក់ព័ន្ធ មុននឹងឈានដល់ការសម្រេចចិត្តជាលើកចុងក្រោយ។ ចំពោះការសម្រេចចិត្តនេះ ភាគីទាំងសងខាងបានជ្រើសរើសយកគម្រោងទៅវិនិយោគក្រោមយន្តការ ភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលផ្តល់អាទិភាពជាសំខាន់ទៅលើការវិនិយោគក្រោមរូបភាព សាងសង់-ធ្វើអាជីវកម្ម-ផ្ទេរ (Build-Operate-Transfer)។ នៅក្នុងនោះ កត្តាជាចម្បងដែលឈានដល់ការសម្រេចចិត្តនេះ ដោយសារតែតម្លៃនៃគម្រោង គឺខ្ពស់រហូតដល់ប្រមាណជាង២.០០០ លានដុល្លារអាមេរិក ដែលធំជាងពិដាននៃការខ្ចីប្រចាំឆ្នាំដែលអនុញ្ញាតដោយច្បាប់ និងកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់ គ្រងបំណុលសាធារណៈ២០១៥-២០១៨។

ក្រៅពីនេះ ការសម្រេចដូចបានលើកឡើងខាងលើក៏ផ្តោតជាសំខាន់ផងដែរ ចំពោះកត្តាធំៗចំនួនពីររួមមាន៖

- តម្រូវការជាក់ស្តែងមានការកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ ជាពិសេសនោះការវិនិយោគរបស់វិនិយោគិនជាតិ និងអន្តរជាតិ ចំពោះមធ្យោបាយធ្វើដំណើរដែលមានសុវត្ថិភាពខ្ពស់ និងមានភាពឆាប់រហ័ស។
- ចក្ខុវិស័យ ឬទស្សនទានវែងឆ្ងាយរបស់ប្រទេសកម្ពុជា ក្នុងការអភិវឌ្ឍប្រទេសឲ្យក្លាយជាដង្ហើមសេដ្ឋកិច្ចដ៏សំខាន់ទាំងក្នុងតំបន់ និងក្រៅតំបន់ ដើម្បីទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តទៅជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ ដូចការលើកឡើងរបស់រាជរដ្ឋាភិបាល។

### ៤.២.៣-ការរៀបចំគម្រោង

នៅក្នុងដំណាក់កាលនេះ ត្រូវបានពិនិត្យឃើញថា ភាគីទាំងសងខាងបានរៀបចំគម្រោងដែលក្នុងនោះមានការប្រជុំជាច្រើនលើកច្រើនសារ។ ក្នុងនោះ ភាគីរដ្ឋដែលមានក្រសួងសាធារណការ និងដឹកជញ្ជូន ដែលតំណាងឲ្យរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មការសម្របសម្រួលមួយក្នុងគោលបំណងរៀបចំ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" នេះ នៅថ្ងៃទី០១ ខែ

កក្កដា ឆ្នាំ២០១៤។ គណៈកម្មការនេះ បានប្រជុំរយៈពេល១៤ នៅក្នុងថ្ងៃក្នុង និង១៥ ដងទៀត ជាមួយ ក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC)។

## ៤.៣-នីតិវិធីលទ្ធកម្មនៃគម្រោង

### ៤.៣.១-ដំណាក់កាលនៃកិច្ចលទ្ធកម្ម

ដូចបានបញ្ជាក់នៅក្នុងដំណាក់កាលនៃនីតិវិធីរៀបចំគម្រោង និងការលើកឡើងរបស់រាជរដ្ឋាភិបាលកម្ពុជា ការអនុវត្តឯកជនភាវូបនីយកម្ម ជាពិសេសទៅលើយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានអនុលោមទៅតាមប្រព័ន្ធគ្រប់គ្រងដែលមានស្រាប់ និងប្រព័ន្ធគ្រប់គ្រងដែលមានការអនុវត្តជាសកល។ ដូចនេះ សម្រាប់ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" នេះ ត្រូវបានពិនិត្យឃើញថា កិច្ចលទ្ធកម្មទៅលើគម្រោងបានអនុលោមទៅតាមមាត្រា៦ នៃអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈ ដែលត្រូវបានចុះហត្ថលេខាឲ្យប្រើប្រាស់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦។ នៅក្នុងមាត្រានេះ បានចែងថាកិច្ចលទ្ធកម្មអាចធ្វើតាមវិធីសាស្ត្រលទ្ធកម្មដោយឡែក ពោលគឺការចុះកិច្ចសន្យាផ្ទាល់ "កជ"។ នៅក្នុងវិធីសាស្ត្រនេះ អាចប្រព្រឹត្តទៅបានលុះត្រាតែមានករណីដូចខាងក្រោមៈ

ក-ឧបករណ៍ដែលត្រូវការមានប្រភពតែមួយគត់

ខ-ករណីចាំបាច់សម្រាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង ហើយ តម្រូវការចាំបាច់បន្ទាន់រយៈពេលខ្លី មិនអាចរងចាំឲ្យប្រើវិធីផ្សេងទៀតបាន

គ-សម្រាប់គោលបំណងសិក្សាស្រាវជ្រាវដកបទពិសោធន៍ ឬអភិវឌ្ឍន៍។

ជារួមមក នៅក្នុងដំណាក់កាលនៃកិច្ចលទ្ធកម្មនេះ មិនត្រូវបានដាក់ឲ្យគោរពតាមការប្រកួតប្រជែងដូចមានចែងនៅក្នុងមាត្រាផ្សេងនៃអនុក្រឹត្យស្តីពីលទ្ធកម្មសាធារណៈនោះទេ។ ដោយឡែក វាត្រូវបានអនុលោមទៅតាមការចុះកិច្ចសន្យាផ្ទាល់ "កជ" ឬអាចត្រូវបានដាក់អនុវត្តទៅតាមឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។ នៅក្នុងឯកសារគោលនយោបាយនេះ បានបញ្ជាក់ផងដែរថា រាជរដ្ឋាភិបាលអាចអនុវត្តគម្រោងដែលផ្តួចផ្តើមដោយរដ្ឋ (Solicited

Proposals) និងអាចទទួលយកគម្រោងដែលផ្តួចផ្តើមដោយផ្នែកឯកជន (Unsolicted Proposals) ប្រសិនបើវាមាននវានុវត្តភាពកម្រិតខ្ពស់។

### ៤.៣.២-ដំណាក់កាលនៃកិច្ចសន្យា

នៅក្នុង "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ត្រូវបានរៀបចំចុះហត្ថលេខាលើកិច្ចសន្យាចំនួនពីរលើកធំៗរួមមាន៖

ក-លើកទី១៖ ជាការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខណ្ឌការងារ ដែលត្រូវធ្វើឡើងក្នុងអំឡុងទស្សនកិច្ចផ្លូវរដ្ឋរបស់ **ឯកឧត្តម ស៊ី ជិនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន** នៅព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។

ខ-លើកទី២៖ ជាការចុះហត្ថលេខាកិច្ចព្រមព្រៀងសម្បទាន នាថ្ងៃទី១១ ខែមករា ឆ្នាំ២០១៨ នៅក្នុងអំឡុងទស្សនកិច្ចផ្លូវការរបស់ **ឯកឧត្តម លី ខឺឈាង នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន** នៅព្រះរាជាណាចក្រកម្ពុជា។

## ៤.៤-ការអនុវត្តគម្រោង

នៅក្នុងដំណើរការនៃការអនុវត្ត "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ត្រូវបានវាយតម្លៃថាអាចប្រើប្រាស់រយៈពេល៤៨ ខែ ដែលក្នុងនោះមានស្ថាប័ន និងក្រុមហ៊ុនឯកជនចំនួនប្រាំ រួមមាន៖

- តំណាងរាជរដ្ឋាភិបាលកម្ពុជា៖ ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រុមហ៊ុនវិនិយោគ៖ ក្រុមហ៊ុនកម្ពុជាផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ
- ក្រុមហ៊ុនសាងសង់៖ សាខាក្រុមហ៊ុនសាជីវកម្មផ្លូវស្ពានចិន (កម្ពុជា)
- ទីប្រឹក្សាបច្ចេកទេស៖ ក្រុមហ៊ុនទីប្រឹក្សាបច្ចេកទេស
- ទីប្រឹក្សាឯករាជ្យ៖ ក្រុមហ៊ុនទីប្រឹក្សាឯករាជ្យ AECOM

សរុបមកវិញ គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ នេះត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាគម្រោងដំបូងបំផុតនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ដែលក្នុងនោះមានដំណាក់កាលពិសេសៗមួយចំនួន មុនឈានដល់ពិធីបើកការដ្ឋានដាក់ឲ្យអនុវត្តនៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩។ ដំណាក់កាលទាំងអស់នោះរួមមាន ការចុះអនុស្សរណៈនៃការយោគយល់រវាង

# ជំពូកទី៥

# ការរកឃើញ និងការពិភាក្សា

# ជំពូកទី៥

# ការរកឃើញ និងការពិភាក្សា

## ៥.១-ការរកឃើញពាក់ព័ន្ធគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ

យោងតាមឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០ ការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ជាពិសេសនោះចំពោះយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មិនទាន់ស្របតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយទេ ពោលគឺរាជរដ្ឋាភិបាលកម្ពុជាត្រូវពិនិត្យឡើងវិញលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយត្រូវធ្វើវិសោធនកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្តបន្ថែម តាមការចាំបាច់ដើម្បីបំពេញល័ក្ខខ័ណ្ឌតម្រូវជាសារវន្ត។

ដូចនេះ ដោយសារកត្តាដូចបានរៀបរាប់ខាងលើនេះហើយទើបបានជា "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ត្រូវបានពិនិត្យឃើញថាមានចំណុចខ្វះខាតមួយចំនួន។ ចំណុចខ្វះខាតទាំងអស់នោះត្រូវបានពិនិត្យឃើញនៅក្នុងដំណាក់កាលនីមួយៗនៃគម្រោង ដែលត្រូវបានបកស្រាយដូចខាងក្រោម៖

### ៥.១.១-នីតិវិធីនៃការរៀបចំគម្រោង

ចំណុចខ្វះខាតនៅក្នុងដំណាក់កាលនេះ ផ្តោតតែសំខាន់ទៅលើយន្តការស្ថាប័ន។ នៅក្នុងន័យនេះចង់បញ្ជាក់ពីតួនាទី និងភារកិច្ចរបស់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសនោះទៅលើនីតិវិធីនៃការរៀបចំ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ"។ យោងទៅតាមគោលការណ៍នៃការអនុវត្តជាសកល នៅក្នុងដំណាក់កាលនេះ មានតែរាជរដ្ឋាភិបាលតែមួយគត់ដែលមានភារកិច្ចក្នុងការរៀបចំគម្រោង ប៉ុន្តែសម្រាប់ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" បានទទួលជំនួយពីក្រុមហ៊ុនសាជីវកម្មស្ពាន និងថ្នល់ចិន (CRBC) ក្នុងការរៀបចំគម្រោង ពោលគឺគិតចាប់ពីដំណាក់កាលការចុះអនុស្សរណៈនៃការយោគយល់គ្នា រហូតដល់ដំណាក់កាលអនុវត្តគម្រោង។

**៥.១.២-នីតិវិធីលទ្ធកម្ម**

ចំពោះការអនុវត្តកិច្ចលទ្ធកម្មទៅលើ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" មិនទាន់មានលក្ខណ:គ្រប់ជ្រុងជ្រោយនៅឡើយទេ ដើម្បីធានាឲ្យមានការប្រកួតប្រជែងដោយតម្លាភាព និងយុត្តិធម៌ដូចមានចែងនៅក្នុងសញ្ញាណនៃការអនុវត្តឯកជនភាវូបនីយកម្ម។ នៅក្នុងនោះត្រូវបានពិនិត្យឃើញថា ក្របខ័ណ្ឌគតិយុត្តជាការរារាំងមួយដល់ដំណើរការនៃការអនុវត្តយន្តការភាពជាដូគូរវាងរដ្ឋ និងឯកជន ពោលគឺរាជរដ្ឋាភិបាលកម្ពុជាមានត្រឹមតែអនុក្រឹត្យស្តីពីកិច្ចលទ្ធកម្មសាធារណ:ដែលដាក់ឲ្យអនុវត្តក្នុងឆ្នាំ២០០៦ ប៉ុណ្ណោះ ដែលក្នុងន័យនេះបញ្ជាក់យ៉ាងច្បាស់ណាស់ពីភាពមិនគ្រប់គ្រាន់ ជាពិសេសនៅក្នុងបរិការណ៍ជាសកល។ ក្រៅពីនេះ គម្រោងនេះក៏សបញ្ជាក់ផងដែរពីកម្រិតនៃការចូលរួមរបស់ក្រុមហ៊ុនវិនិយោគសាធារណ: ដែលក្នុងនោះឃើញមានតែក្រុមហ៊ុនឯកជនមួយប៉ុណ្ណោះ ដែលបានចូលរួមក្នុងប្រតិបត្តិការនៃគម្រោងជាពិសេសនៅក្នុងកិច្ចលទ្ធកម្មនេះ។

**៥.១.៣-ការអនុវត្តគម្រោង**

នៅក្នុងដំណាក់កាលនេះ ចំណុចខ្វះខាតត្រូវបានមើលឃើញចំពោះភាគីរដ្ឋ ដែលក្នុងនោះត្រូវបានសង្កត់ធ្ងន់ទៅលើយន្តការស្ថាប័ន។ នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន បាននឹងកំពុងបង្កើតនិងដាក់ឲ្យមានយន្តការស្ថាប័នឲ្យមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ សម្រាប់គ្រប់គ្រងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ស្ថាប័នគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នោះរួមមានគណ:កម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេស សម្រាប់ដឹកនាំ និងគ្រប់គ្រងការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលរៀបចំដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៦។ ប៉ុន្តែ ទោះបីជាគណ:កម្មការអន្តរក្រសួងនេះត្រូវបង្កើតឡើងក៏ដោយ នៅក្នុងនោះការគ្រប់គ្រងគម្រោងនៅតែអនុវត្តតាមយន្តការចំពោះកិច្ចមានន័យថាការគ្រប់គ្រងការអនុវត្តគម្រោង ត្រូវបានអនុវត្តដោយឡែកពីគ្នាតាមក្រសួង ឬស្ថាប័នជំនាញនីមួយៗ។

## ៥.២-ការពិភាក្សាអំពីផលប៉ះពាល់នៃគម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ

ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល ទៅលើការសាងសង់ "គម្រោងផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ" ពិតជាមានសារ:សំខាន់ណាស់សម្រាប់ប្រទេសកម្ពុជាទាំងមូល ទោះបីជា

គម្រោងនេះមិនទាន់សម្រេចបានទាំងស្រុងក៏ដោយ ពោលគឺកំពុងដាក់ឲ្យអនុវត្ត។ ប៉ុន្តែ ក្នុងនោះ គម្រោងនេះក៏អាចបង្កឲ្យមានផលបះពាល់ជាអវិជ្ជមានផងដែរ។ ផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ត្រូវបានសន្និដ្ឋាន និងបកស្រាយដូចខាងក្រោមៈ

### ៥.២.១-ផលប៉ះពាល់ជាវិជ្ជមាន

- ខ្សែផ្លូវនេះនឹងបង្កើតឲ្យមានដង្ហើមសេដ្ឋកិច្ច និងប៉ូលទេសចរណ៍តាមរយៈការតភ្ជាប់ផ្លូវទៅកាន់តំបន់ប៉ូលសេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក និងជួយសម្រួលដល់មធ្យោបាយធ្វើដំណើររបស់ប្រជាពលរដ្ឋ និងវិស័យឯកជនក្នុងសកម្មភាពធុរកិច្ចនានា ដោយជៀសវាងការកកស្ទះ និងគ្រោះថ្នាក់ចរាចរណ៍ ដែលធ្លាប់កើតមានជាញឹកញាប់តាមបណ្តោយផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៤។ ក្រៅពីប្រសិទ្ធភាពនៃការធ្វើដំណើរ វាក៏បានលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធភស្តុភារ សំដៅសម្រួលការដឹកជញ្ជូនផលិត ផលដំណាំកសិផល និងផលិតផលកសិ-ឧស្សាហកម្មជាដើម។
- គម្រោងនេះអាចនឹងបំពេញនូវតម្រូវការសេដ្ឋកិច្ច និងសង្គម។ ចំពោះសេដ្ឋកិច្ច អាចជាផ្នែកមួយ ដែលធ្វើអោយកំណើនសេដ្ឋកិច្ចជាតិមានការរីកចម្រើនធំធាត់ជាងមុនក្នុងដំណើរការបោះជំហានយ៉ាងស្វាហាប់ ចាកចេញពីប្រទេសមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅក្នុងឆ្នាំ២០៣០ និងបន្តទៅជាប្រទេសចំណូលខ្ពស់នៅក្នុងឆ្នាំ២០៥០។ ចំណែកឯតម្រូវការសង្គម ចំណូលរបស់ប្រជាពលរដ្ឋ អាចនឹងកើនឡើងប្រសើរជាងមុន តាមរយៈការទទួលបានសេវាសាធារណៈដែលមានប្រសិទ្ធភាព និងសក្តិសិទ្ធភាព។ នៅក្នុងផលប្រយោជន៍សង្គមនេះផងដែរ តបតាមការស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ភាគីក្រុមហ៊ុនឯកជនបានឯកភាពមិនយកថ្លៃយានយន្តគ្រប់ប្រភេទដែលបើកបរលើផ្លូវល្បឿនលឿននេះ ក្នុងរយៈពេល១ខែដំបូង និងបញ្ចុះតម្លៃ២០% សម្រាប់រយៈពេល១ ឆ្នាំបន្ទាប់។
- គម្រោងនេះក៏បានជួយគាំទ្រ និងសម្រួលដល់ការចំណាយទៅហិរញ្ញវត្ថុសាធារណៈផងដែរ ដោយហេតុតែវាមានលក្ខណៈធំល្មម ដែលហួសពីពិដាននៃការខ្ចីប្រចាំឆ្នាំដែលអនុញ្ញាតដោយច្បាប់ និងកំណត់នៅក្នុងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈឆ្នាំ២០១៥-២០១៨។

### ៥.២.២-ផលប៉ះពាល់ជាអវិជ្ជមាន

- គម្រោងនេះបង្កើតអោយមានផលប៉ះពាល់ទៅលើដីធ្លី និងភូមិឋានរបស់ប្រជាពលរដ្ឋដែលរស់នៅជិតតំបន់នៃគម្រោងនេះ ប៉ុន្តែផលប៉ះពាល់អាចត្រូវបានជួយសម្រួលពីសំណាក់ភាគីរដ្ឋ តាមរយៈការអនុវត្តតាមច្បាប់ដែលបានចែងនៅក្នុងប្រទេសកម្ពុជា។
- បើទោះបីជាហិរញ្ញវត្ថុដែលចំណាយទៅលើគម្រោងសាងសង់ ជាបន្ទុករបស់ភាគីក្រុមហ៊ុនឯកជន ប៉ុន្តែនៅក្នុងនោះបញ្ហាប្រឈមនៃហានិភ័យ ឬសម្ពាធចំពោះថវិកាជាតិអាចនឹងកើតមានឡើង ប្រសិនបើចំណូលរបស់រដ្ឋមិនមានតុល្យភាព។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការរៀបចំ និងគ្រប់គ្រងនៃការផ្តល់សេវាសាធារណៈនៅកម្ពុជានាពេលបច្ចុប្បន្ន ត្រូវបានដាក់ឲ្យអនុវត្តក្រោមយន្តការផ្សេងៗគ្នារួមមានជាអាទិ៍ ការកែលំអកិច្ចដំណើរការការងារនៃការផ្តល់សេវាសាធារណៈ ច្រកចេញចូលតែមួយ វិសហមជ្ឈការសេវាសាធារណៈ វិមជ្ឈការសេវាសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ កិច្ចសន្យា ភ្នាក់ងារប្រតិបត្តិការពិសេស និង ឯកជនភាវូបនីយកម្ម។ នៅក្នុងនោះ ឯកជនភាវូបនីយកម្ម ដែលត្រូវបានស្គាល់ថាជាឧបករណ៍មួយក្នុងចំណោមឧបករណ៍ជាច្រើននៃការគ្រប់គ្រងរដ្ឋបាលសាធារណៈបែបថ្មី ត្រូវរាជរដ្ឋាភិបាលកម្ពុជាដាក់ចេញជាផែនការអាទិភាពមួយផងដែរ នៅក្នុងយុទ្ធសាស្រ្តចតុកោណពីមួយដំណាក់ការទៅមួយដំណាក់ការ ក្នុងគោលបំណងធានាឲ្យមានការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ជំហានដំបូងនៃការអនុវត្តឯកជនភាវូបនីយកម្មនៅកម្ពុជា ផ្តោតជាសំខាន់ទៅលើការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលទទួលបានការគាំទ្រពីសំណាក់ដៃគូអភិវឌ្ឍន៍មួយចំនួនដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ធនាគារពិភពលោក (World Bank) សហរដ្ឋអាមេរិក ប្រទេសជប៉ុន និងប្រទេសអូស្រ្តាលី។

នៅក្នុងយន្តការនៃការផ្តល់សេវាសាធារណៈតាមរយៈការធ្វើឯកជនភាវូបនីយកម្មនេះ អាចជាគ្រោះថ្នាក់ទៅដល់សេដ្ឋកិច្ចជាតិទាំងមូល ជាពិសេសចំពោះប្រទេសកំពុងអភិវឌ្ឍន៍។ ដូចនេះ ដើម្បីបម្រើឲ្យមហិច្ឆតានៃការអនុវត្តឯកជនភាវូបនីយនៅក្នុងប្រទេសកំពុងអភិវឌ្ឍ អោយទទួលបានជោគជ័យ រាជរដ្ឋាភិបាលនៃបណ្តាប្រទេសទាំងអស់នោះក៏ដូចជាដៃគូអភិវឌ្ឍដែលពាក់ព័ន្ធត្រូវពិចារណាឲ្យបានល្អិតល្អន់មុននឹងឈានដល់ការសម្រេចចិត្ត។ នៅក្នុងនោះ រួមមានច្បាប់ និងបទបញ្ញត្តិដែលពាក់ព័ន្ធ គោលនយោបាយសាធារណៈ តុល្យភាពរវាងសេដ្ឋកិច្ចជាតិ និងឯកជន និងសន្តិភាព និងស្ថេរភាពនយោបាយ។

ឯកជនភាវូបនីយកម្មនៅកម្ពុជា ត្រូវបានដាក់ឲ្យអនុវត្តដំបូងក្នុងឆ្នាំ១៩៨៥ ក្រោមរូបភាពជាការអភិវឌ្ឍទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធដោយគោរពទៅតាមទម្រង់ផ្សេងៗគ្នា។ ប៉ុន្តែ ដោយសារតែបរិបទពិភពលោកមានការប្រែប្រួល រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្នបានផ្តល់ផែនការជាអាទិភាពចំពោះយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ នៅក្នុងទម្រង់ ឬយន្តការនេះ ត្រូវបានដាក់ឲ្យអនុវត្តក្រោម "គោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯក

ជនសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០" ដែលក្នុងនោះរាជរដ្ឋាភិបាលក៏បានលើកទឹកចិត្តចំពោះការអនុវត្តដោយអនុលោមទៅតាមគោលការណ៍មួយចំនួនផងដែរ ដែលបានកំណត់ជាសកលសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ នៅក្នុងនោះ ដើម្បីសម្រេចអោយការអនុវត្តយន្តការនេះទទួលបានជោគជ័យ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវយុទ្ធសាស្ត្រ កំណត់យន្តការស្ថាប័ន និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុសម្រាប់រយៈពេលខ្លី មធ្យម និងរយៈពេលវែង សំដៅធានាឲ្យការអនុវត្តប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព សង្គតិភាព និងភាពប្រទាក់ក្រឡាគ្នា។

ជាក់ស្តែង "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" ត្រូវបានដាក់ឲ្យអនុវត្តក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលក្នុងនោះត្រូវបានសបញ្ជាក់ឲ្យឃើញថា វាបានបម្រើផលប្រយោជន៍ជាច្រើនសម្រាប់ប្រទេសកម្ពុជា បើទោះបីជាមានផលប៉ះពាល់បន្តិចបន្តួចក៏ដោយ។ នៅក្នុងផលប្រយោជន៍នោះ អាចបង្កើតបានជាប៉ូលទេសចរណ៍ ដង្ហើមសេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក សម្រួលដល់មធ្យោបាយធ្វើដំណើរ រួមបញ្ចូលទាំងសកម្មភាពធុរកិច្ច និងសកម្មភាពប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ក្រៅពីនេះ វាក៏សង្ឃឹមខ្ពស់ថានឹងបំពេញផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមជាតិផងដែរ ជាពិសេសនោះគឺជួយសម្រួលដល់ការចំណាយទៅលើហិរញ្ញវត្ថុសាធារណៈ។ ចំណែកឯ ផលប៉ះពាល់ជាអវិជ្ជមានត្រូវបានពិនិត្យឃើញថាបានប៉ះពាល់ទៅដល់ដីធ្លី និងភូមិឋានរបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនៃហានិភ័យ ឬសម្ពាធចំពោះថវិកាជាតិ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវទៅលើការអនុវត្តឯកជនភាវូបនីយកម្ម នៅប្រទេសកម្ពុជារួចមក ជាពិសេសនោះការអនុវត្តដែលស្ថិតក្រោមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ចំពោះ "គម្រោងផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ" គឺមាននូវចំណុចខ្វះខាតមួយចំនួនដែលត្រូវការដំណោះស្រាយ ក្នុងគោលបំណងឲ្យការអនុវត្តឯកជនភាវូបនីយកម្មដែលស្របតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ទទួលបានភាពជោគជ័យ និងប្រសិទ្ធភាពខ្ពស់។ ដូចនេះ ខ្ញុំបាទសូមលើកឡើងនូវអនុសាសន៍មួយចំនួន ដែលត្រូវបានរៀបរាប់ដូចខាងក្រោម៖

- ដាក់ចេញនូវវិធានការនៃការអនុវត្តច្បាប់អោយមានប្រសិទ្ធភាពខ្ពស់ ទៅលើការរៀបចំគម្រោង និងការអនុវត្តគម្រោងរបស់វិស័យឯកជន តាមរយៈការពង្រឹងចំពោះយន្តការស្ថាប័នរដ្ឋឲ្យមានភាពច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ពោលគឺធានាការលុបបំបាត់នូវយន្តការចំពោះកិច្ច ឬការអនុវត្តដោយឡែកពីគ្នាតាមក្រសួង ស្ថាប័នជំនាញនីមួយ។ ក្នុងនោះផងដែរ ត្រូវចាប់ផ្តើមរៀបចំបង្កើតច្បាប់ថ្មី ឬធ្វើវិសោធនកម្មទៅលើច្បាប់ដែលកំពុងដាក់ឲ្យអនុវត្ត ក្នុងគោលបំណងឲ្យស្របទៅតាមបរិការណ៍ជាសកល។ ឧទាហរណ៍៖ រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សជាដើម។
- ភាគីរដ្ឋត្រូវដើរតួនាទីជាបញ្ញត្តិករ តាមរយៈការដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ប្រកបដោយភាពជឿទុកចិត្ត និងការត្រួតពិនិត្យ (Inspection) ទៅលើការអនុវត្តគម្រោងរបស់វិស័យឯកជនក្នុងគោលបំណងលើកទឹកចិត្ត និងសម្របសម្រួល សំដៅធានាដល់ការអនុវត្តគម្រោងដោយជោគជ័យ។ ឧទាហរណ៍៖ បង្កើតយន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់ ដើម្បីសម្រួលដល់ហានិភ័យដែលកើតមានឡើងជាយថាហេតុ។ នៅក្នុងនោះ ផងដែរ ប្រសិនបើការត្រួតពិនិត្យរបស់រដ្ឋចំពោះគម្រោងវិស័យឯកជនមានភាពល្អប្រសើរ វាអាចផ្តល់នូវឱកាសជាចម្រើនសម្រាប់ភាគីរដ្ឋ ក្នុងការរៀបចំគម្រោងនៅពេលក្រោយៗទៀត។ ឧទហរណ៍៖ ការចូលរួមរបស់ក្រុមហ៊ុនឯកជនដ៏ច្រើនសន្ធឹកសន្ធាប់ដែលធានាឲ្យមានភាពប្រកួតប្រជែងខ្ពស់។
- ផ្តល់ពត៌មានអោយបានទូលំទូលាយ និងទទួលយកសំណើរបស់ប្រជាពលរដ្ឋ ពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍក្រោមទម្រង់ឯកជនភាវូបនីយកម្ម សំដៅធានាដល់ការចូលរួមពី

សំណាក់ប្រជាពលរដ្ឋ មានគណនេយ្យភាព និងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល និងរដ្ឋបាលសាធារណៈចំពោះប្រជាពលរដ្ឋ។ ការធ្វើបែបនេះ ដើម្បីឲ្យដឹងពីតថភាពនៅតាមមូលដ្ឋាន និងសបញ្ជាក់ឲ្យច្បាស់អំពីអ្នកខាតប្រយោជន៍ និងចំណេញប្រយោជន៍ពីគម្រោង។

- បង្កើតក្របខណ្ឌស្តីពីតួនាទី និងការទទួលខុសត្រូវរបស់តួអង្គពាក់ព័ន្ធនឹងការធ្វើឯកជនភាវូបនីយកម្ម (ភាគីរដ្ឋ ភាគីឯកជន និងប្រជាពលរដ្ឋដែលជាអតិថិជន) ឲ្យបានច្បាស់លាស់ និងធានាថាភាគីទាំងបីនេះ យល់ច្បាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន។ ក្របខណ្ឌស្តីពីតួនាទី និងការទទួលខុសត្រូវ ត្រូវបានពិនិត្យឃើញនៅក្នុងដំណើរការនៃគម្រោងដោយរួមបញ្ចូលទាំងដំណាក់ការធ្វើអត្តសញ្ញាណកម្មគម្រោង ការរៀបចំគម្រោង ប្រតិបត្តិការគម្រោង និងដំណាក់ការគ្រប់គ្រងគម្រោង។
- ការរៀបចំគម្រោង ត្រូវតែយកចិត្តទុកដាក់អំពីការរក្សានិរន្តរភាពនៃសេវាសាធារណៈ បន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ និងតម្រូវឲ្យបន្តការអភិវឌ្ឍធនធានមនុស្សនៅក្នុងវិស័យសាធារណៈ ដែលនឹងបន្តអនុវត្តការងារផ្តល់សេវាសាធារណៈ បន្ទាប់អំពីគម្រោងត្រូវបានបញ្ចប់។ឧទាហរណ៍៖ ការធានាជួសជុលទៅលើសមិទ្ធផលនៃគម្រោងជាប្រចាំ។
- បង្កើតយន្តការផ្តល់ការលើកទឹកចិត្តដល់ភាគីឯកជន ដែលអនុវត្តគម្រោងឯកជនភាវូបនីយកម្មបានល្អប្រសើរ ដើម្បីបង្កើតឲ្យមានការចូលរួមច្រើនពីសំណាក់ក្រុមហ៊ុនឯកជន រហូតឈានដល់មានការប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ចំពោះគម្រោងដែលដាក់ចេញនៅពេលក្រោយៗទៀត។ ឧទាហរណ៍៖ ការលើកលែង ឬកាត់បន្ថយពន្ធចំពោះក្រុមហ៊ុនឯកជន ដែលធ្លាប់អនុវត្តកន្លងមកជាដើម។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ ២០០៨
- ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦
- អនុក្រឹត្យលេខ២៣ អនក្រ.បក ស្តីពីការបង្កើត គ្រឹះស្ថានបោះពុម្ព និងចែកផ្សាយថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២
- អនុក្រឹត្យលេខ៥០ អនក្រ.បក ស្តីពីការបង្កើតកំពុងផែស្វយ័តក្រុងព្រះសីហនុ ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨
- អនុក្រឹត្យលេខ១០៥ អនក្រ.បក ស្តីពីលទ្ធកម្មសាធារណៈ ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦
- សេចក្តីសម្រេចលិខិតលេខ០៥០ សហវ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦
- ក្រសួងមុខងារសាធារណៈ ៖ គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ ថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៦
- រាជរដ្ឋាភិបាលកម្ពុជា៖ ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (២០១៦-២០២០)

## សៀវភៅតែងនិពន្ធ

- សៀវភៅ៖ សេវាសាធារណៈនៅកម្ពុជា របស់លោក កៅ មុយ ថង បោះពុម្ពផ្សាយក្នុងឆ្នាំ២០០៦
- សៀវភៅ៖ នីតិរដ្ឋបាលទូទៅ របស់សាស្ត្រាចារ្យ ហៀង សាង បោះពុម្ពផ្សាយក្នុងឆ្នាំ២០១១
- សៀវភៅ៖ នីតិរដ្ឋបាលទូទៅ របស់សាស្ត្រាចារ្យ សាយ បូរី បោះពុម្ពផ្សាយក្នុងឆ្នាំ២០១២
- សៀវភៅ៖ រដ្ឋបាលសាធារណៈ របស់សាស្ត្រាចារ្យ គង់ ប៊ុនធី - ប៊ុន ស្រុង - លីន ញក់ - ខាំ សុមករា - ឡាយ រតនា - ឡាយ ណូរ៉ា ឆ្នាំ២០០៣

- សៀវភៅ៖ រដ្ឋបាលសាធារណៈទំនើប របស់លោក កៅ មុយថង បោះពុម្ពផ្សាយក្នុងឆ្នាំ២០០៧
- សៀវភៅ៖ គោលនយោបាយសាធារណៈ របស់សាស្ត្រាចារ្យ ឈុន ណារ៉េត និងសាស្ត្រាចារ្យ ខៀវ វិជ្ជានន្ទ
- សារណាបញ្ចប់ការសិក្សា៖ ការផ្តល់សេវាសាធារណៈរបស់ការិយាល័យច្រកចេញចូលតែមួយ របស់និស្សិត យ៉ន សារ៉េត និងកញ្ញា យឹម វណ្ណឌីម៉ង់ រៀបចំឡើងក្នុងឆ្នាំ២០១៥
- សារណាបញ្ចប់ការសិក្សា៖ ការគ្រប់គ្រងបុគ្គលិកអប់រំក្នុងបរិបទរដ្ឋបាលសាធារណៈបែបថ្មីនៅកម្ពុជា របស់និស្សិត ម៉ឹប ព្រុយណេ និងកញ្ញា សន សូរិយា រៀបចំឡើងក្នុងឆ្នាំ២០១៨
- Korng, V. (2016). The New Public Management Paradigm: Concept Analysis and Implications in the context of Cambodian Public Service Reform. *International Journal of Public and Private Management.*


## សៀវភៅអេឡិចត្រូនិច


ADB (2001). *Special Evaluation Study on the Privatization of Public Sector Enterprises: Lessons for Developing Member Countries.* Retrieved from https://www.adb.org/sites/default/files/evaluation-document/35461/files/ses-public-sector.pdf

CDIAC (2007). *Privatization Vs. Public-Private Partnerships: A Comparative Analysis.* Retrieved from https://www.treasurer.ca.gov/cdiac/publications/privatization.pdf

Deep et al. (2019). *Realizing the Potential of Public-Private Partnerships to Advance Asia's Infrastructure Development.* Retrieved from https://www.adb.org/sites/default/files/publication/479396/potential-ppp-asia-infrastructure.pdf

Estrin, S. & Pelletier, A. (2018). *Privatization in Developing Countries: What Are the Lessons of Recent Experience?*. Published by Oxford University Press. Retrieved from https://academic.oup.com/wbro/article/33/1/65/4951686

Fatemi, Mohboubeh; Behmanesh, Mohammad Reza (2012). New Public Management Approach and Accountability. *International Journal of Management, Economics and Social Sciences (IJMESS).* Retrieved from http://www.ijmess.com/volumes/volume-I-2012/issue-II-12-2012/full-3.pdf

Gollust, S. E. & Jacobson, P. D. (2006). Privatization of Public Services: Organizational Reform Efforts in Public Education Public Health. *American Journal of Public Health*, Vol 96. Retrieved from https://pdfs.semanticscholar.org/b6d9/e5c24f1c2a00b382e50f83549ba930261bc1.pdf?_ga=2.140910704.370605741.1563436895-201521393.1563436895

Larbi, G. A. (1999). *The New Public Management Approach and Crisis States*, governance 2000 – 2009 by UNRISD. Retrieved from http://www.unrisd.org/80256B3C005BCCF9/(httpAuxPages)/5F280B19C6125F4380256B6600448FDB/$file/dp112.pdf

Savas, E. S. (2000). *Privatization and Public-Private Partnership.* Retrieved from https://www.academia.edu/779502/Privatization_and_public-private_partnerships

Shirley, M. M. (1992). *The What, Why, and How of Privatization: A World Bank Perspective,* Vol 60, Issue 6. Retrieved from https://ir.lawnet.fordham.edu/cgi/viewcontent.cgi?article=2976&context=flr

The United Nations Economic and Social Commission for Asia and the Pacific. *Public-Private Partnerships,* Training Modules: Cambodia Verson. Retrieved from https://www.unescap.org/sites/default/files/PPP%20Training%20Booklet%20Cambodian%20Revised%20Final%20Version%2005.06.16.pdf

Yamamoto, H. (2003). *New Public Management-Japan's Practice*. Institute for International Policy Studies, Page 1. Retrieved from http://www.iips.org/en/research/data/bp293e.pdf

## គេហទំព័រ

- គេហទំព័រ http://www.cmaa.gov.kh/background/background
- គេហទំព័រ http://csx.com.kh/kh/about/mission.jsp?MNCD=1020
- គេហទំព័រ https://www.indianeconomy.net/splclassroom/what-are-the-different-models-for-public-private-partnership-ppp-in-infrastructure/
- គេហទំព័រ http://www.pppc.mw/articles/models-of-ppps
- គេហទំព័រ http://m.freshnewsasia.com/index.php/en/localnews/111680-2019-01-28-09-49-58.html

# ឧបសម្ព័ន្ធ១

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# ឯកសារគោលនយោបាយ

# ស្តីពី

# ការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ

# ២០១៦-២០២០

**រៀបចំដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# អារម្ភកថា

រាជរដ្ឋាភិបាល បានអនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១ និងទី២ របស់ខ្លួន ហើយក្នុងនីតិកាលទី៥ នៃរដ្ឋសភា បានឈានដល់ការដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ ដើម្បីកំណើន, ការងារ, សមធម៌, និងប្រសិទ្ធភាព នៅកម្ពុជា ។ ឯកសារយុទ្ធសាស្ត្រទាំងនេះ បានប្រកាសអំពីបេសកកម្ម, ការប្តេជ្ញា, និងកិច្ចប្រឹងប្រែងឥតរាថយរបស់រាជរដ្ឋាភិបាលកម្ពុជា តាំងតាំងពីនីតិកាលទី១ នៃរដ្ឋសភារហូតមក ក្នុងការធានាចីរភាពនៃការអភិវឌ្ឍ និងការកាត់បន្ថយភាពក្រីក្រ ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ដោយក្នុងនោះ បានប្រកាន់ខ្ជាប់នូវការកំណត់យក÷ (១) ការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាវិស័យអាទិភាព សម្រាប់ទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង, បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច, ព្រមទាំងពង្រឹងភាពប្រកួតប្រជែង និងជំរុញពិពិធកម្មសេដ្ឋកិច្ចកម្ពុជា និង (២) ការចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច ដោយទទួលស្គាល់ថាវិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើននិងការអភិវឌ្ឍសង្គម និងការបញ្ចូលបច្ចេកវិទ្យាទំនើបនិងនវានុវត្តភាព សំដៅបង្កើនប្រសិទ្ធភាពនិងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានខិតខំវិនិយោគយ៉ាងគំហុក និងប្រកបដោយវិចារណញាណខ្ពស់លើការស្តារ កសាង, និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយប្រើប្រាស់ប្រភពទុនហិរញ្ញប្បទានជាប្រពៃណី ផ្អែកលើលទ្ធភាពថវិកាជាតិដែលខ្លួនមាន ក៏ដូចជាប្រភពធនាគារហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានា។ ទន្ទឹមនេះ ស្របគ្នានឹងកិច្ចខិតខំប្រឹងប្រែងកៀរគរការវិនិយោគនានា ទាំងការវិនិយោគផ្ទាល់ពីបរទេស និងទាំងការវិនិយោគផ្ទាល់ពីឯកជនក្នុងស្រុក កម្ពុជាក៏បានបន្តខិតខំជំរុញវិស័យឯកជនឱ្យចូលរួមជាមួយរាជរដ្ឋាភិបាល ក្នុងការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈផងដែរ ដែលនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែម, ចំណេះដឹង-ចំណេះធ្វើ, ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំ និងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុន ឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណ និងប្រសិទ្ធភាពចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន ស្របតាមចក្ខុវិស័យនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ក្នុងគោលដៅនេះ ច្បាប់ស្តីពីសម្បទាន ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ដែលមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្នែកឯកជន។ តែទោះជាយ៉ាងនេះក្តី ការរៀបចំ និងការគ្រប់គ្រងគម្រោងនៅមានភាពយឺតយ៉ាវ, ប្រើប្រាស់យន្តការចំពោះកិច្ច, និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលមិនអនុលោមតាមឧត្តមានុវត្តជាអន្តរជាតិ។

ក្នុងបរិការណ៍នៃដំណាក់កាលអភិវឌ្ឍន៍ថ្មី ដែលកម្ពុជាទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងឈានទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងបន្តទៅជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ រាជរដ្ឋាភិបាល បានពិនិត្យឃើញថា គោលនយោបាយនៃការជំរុញការវិនិយោគសាធារណៈ កំពុងស្ថិតក្នុងស្ថានភាពទ្វេទិស គឺមានទាំងបញ្ហាប្រឈម និងទាំងកាលានុវត្តភាព។

បញ្ហាប្រឈមធំៗ ដែលកម្ពុជាជួបប្រទះ រួមមាន៖ (១) ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការថយចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ និង (២) ការធ្លាក់ចុះ និងបាត់បង់នូវឥណទានសប្បទានកម្រិតខ្ពស់ នាពេលខាងមុខ។

ស្របពេលជាមួយគ្នានេះ កាលានុវត្តភាពថ្មីៗរបស់កម្ពុជា រួមមាន៖ (១) ការកើនឡើងក្នុងសន្ទុះលឿនគួរឱ្យកត់សម្គាល់របស់វិស័យឯកជននៅកម្ពុជាជាងមួយទសវត្សរ៍ចុងក្រោយ និងការកើនឡើងនូវសំណើសុំវិនិយោគរបស់វិស័យឯកជន តាមទម្រង់ **"សាងសង់-អាជីវកម្ម-ផ្ទេរ"** ដែលជាទម្រង់មួយនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយផ្តោតជាពិសេស ក្នុងវិស័យផ្លូវថ្នល់, ស្ពាន, និងថាមពល ជាដើម; និង (២) ការដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មីរបស់ដៃគូអភិវឌ្ឍន៍ធំៗក្នុងការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងការរៀបចំយន្តការនេះ ទាំងគ្របដណ្តប់បច្ចេកទេស និងទាំងគ្របដណ្តប់ហិរញ្ញវត្ថុ។

លើមូលដ្ឋាននេះ កម្ពុជាមិនអាចនៅតែប្រើប្រាស់ **"យន្តការចំពោះកិច្ច"** ក្នុងការរៀបចំ និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន បន្តទៀតបានទេ ដូច្នេះ រាជរដ្ឋាភិបាល ត្រូវរៀបចំ **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥"** ដើម្បីរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តជំរុញ និងលើកទឹកចិត្តការចូលរួមរបស់វិស័យឯកជននិងស្ថាប័នហិរញ្ញវត្ថុ ក្នុងការវិនិយោគលើវិស័យហេដ្ឋារចនា-សម្ព័ន្ធសាធារណៈ, វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច, និងវិស័យអាទិភាពផ្សេងទៀត ប្រកបដោយភាពគ្រប់ជ្រុងជ្រោយ និងស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ក្នុងតំបន់ និងសកលលោក។

ដើម្បីសម្រេចគោលបំណង, គោលដៅ, និងចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ឯកសារគោលនយោបាយនេះ សម្រេចដាក់ចេញនូវវិធានការគោលនយោបាយ និងការកំណត់យន្តការស្ថាប័ន ព្រមទាំងរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុចាំបាច់នានា សំដៅរៀបចំឡើងនូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡាគ្នា ឱ្យបាននៅមុនដំណាច់ឆ្នាំ២០២០។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្តរាល់វិធានការដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់។ ទន្ទឹមនេះ រាជរដ្ឋាភិបាល សង្ឃឹមយ៉ាងមុតមាំថា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ នឹងចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្ត **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០"** ឱ្យបានជោគជ័យ សំដៅចូលរួមលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម លើដំណើរនៃមាគ៌ារបស់កម្ពុជា ឆ្ពោះទៅកាន់វឌ្ឍនភាព, វិបុលភាព, និងភាពចុះថ្លើងរុងរឿង។

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

គោរពតាមការចាត់តាំងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដឹកនាំរៀបចំ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥**" ដែលមានគោលបំណងពីរគឺ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ លើការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា។

ឯកសារគោលនយោបាយនេះ ត្រូវបានម្ចាស់ការរៀបចំដោយក្រុមមន្ត្រីបច្ចេកទេសជាន់ខ្ពស់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបានសិក្សាយកពិសោធន៍ពីប្រទេសមួយចំនួនលើពិភពលោកដែលទទួលបានជោគជ័យក្នុងការរៀបចំនិងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេស ប្រទេសក្នុងទ្វីបអាស៊ី ព្រមទាំងធាតុចូលដែលទទួលបានពីការចូលរួមក្នុងវេទិកាពិគ្រោះយោបល់ថ្នាក់តំបន់ និងពីដៃគូអភិវឌ្ឍន៍មួយចំនួន។ ទន្ទឹមនេះ ការរៀបចំ "**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥**" ត្រូវបានធ្វើឡើងដោយផ្អែកលើបរិការណ៍បច្ចុប្បន្ននៃកម្ពុជាផង និងក៏អនុលោមតាមការអនុវត្តនិងនិន្នាការជាសកលផងដែរ។

"**ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥**" គឺជាផែនទីបង្ហាញផ្លូវដ៏មានសារៈសំខាន់សម្រាប់ឈានទៅសម្រេចបានតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដែលបានកំណត់យកមុនដំណាច់ឆ្នាំ២០២០ ជាពេលវេលាគោលដែលរាជរដ្ឋាភិបាលត្រូវបង្កើត និងអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡានិងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃភាពព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។ ដើម្បីសម្រេចបានតាមចក្ខុវិស័យនេះ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាល គឺការដាក់ចេញនូវវិធានការគោលនយោបាយរយៈពេលខ្លីដែលផ្តល់ផលភ្លាមៗ និងវិធានការរយៈពេលមធ្យមនិងវែង ដើម្បីរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការវិនិយោគសាធារណៈ ដោយចាប់ផ្តើមពីការពិនិត្យ និងកែសម្រួលក្របខ័ណ្ឌគតិយុត្ត, កំណត់យន្តការស្ថាប័ន, ដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, និងបង្កើត

យន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់ ព្រមទាំងកំណត់ឲ្យបានច្បាស់លាស់នូវវិស័យអាទិភាពនៃវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្របតាមបរិការណ៍នៃវិវឌ្ឍនាការរបស់កម្ពុជា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ប្ដេជ្ញាខិតខំសម្រេចឱ្យបាននូវប្រសិទ្ធភាព, វិវឌ្ឍនភាព, និងសង្គតិភាពនៃការអនុវត្តវិធានការជាយុទ្ធសាស្ត្រដែលបានដាក់ចេញក្នុងឯកសារគោលនយោបាយនេះ និងស្នើសុំការចូលរួមផ្ដល់កិច្ចសហប្រតិបត្តិការពេញលេញពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅសម្រេចឱ្យបានជោគជ័យនូវការបង្កើតប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្របតាមចក្ខុវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាល។

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា

ទំព័រ

១- សេចក្តីផ្តើម ..... ១

២- ចក្ខុវិស័យ ..... ៣

៣- គោលបំណង និងគោលដៅ ..... ៣

៤- និយមន័យ និងទម្រង់ទូទាត់នៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៤

៥- បរិការណ៍បច្ចុប្បន្ននៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ៥

៥-១- បរិការណ៍សកល ..... ៥

៥-១-១- និន្នាការសកល ..... ៥

៥-១-២- ការអនុវត្តជាសកល ..... ៥

៥-២- បរិការណ៍កម្ពុជា ..... ៧

៥-២-១- ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការស្ថាប័ន ..... ៧

៥-២-២- បញ្ហាប្រឈម និងកាលានុវត្តភាព ..... ៩

៦- យុទ្ធសាស្ត្រ ..... ១២

៦-១- វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ..... ១២

៦-២- វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង ..... ១៤

៧- ផែនការសកម្មភាពស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ..... ១៥

៨- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ ..... ១៩

៩- សេចក្តីសន្និដ្ឋាន ..... ២០

ឧបសម្ព័ន្ធ÷ ផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

## ១-សេចក្តីផ្តើម

ក្នុងរយៈកាលជាងពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាសម្រេចបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ ជាមធ្យមក្នុងកម្រិត ៧,៧ ភាគរយ ក្នុងមួយឆ្នាំ ហើយផលិតផលសរុបក្នុងស្រុក សម្រាប់ប្រជាជនម្នាក់ៗ បានកើនឡើងប្រមាណប្រាំមួយដង គឺពីប្រមាណជាង ២០០ ដុល្លារអាមេរិក នៅឆ្នាំ១៩៩២ ដល់ ១ ២២៨ ដុល្លារអាមេរិក នៅឆ្នាំ២០១៥។ ទន្ទឹមនេះ អត្រាភាពក្រីក្របានធ្លាក់ចុះពីប្រមាណ ៥០ ភាគរយ ក្នុងឆ្នាំ១៩៩២ មកត្រឹមរង្វង់ ១៦ ភាគរយ ក្នុងឆ្នាំ២០១៥។ ការសម្រេចបាននូវសមិទ្ធផលដ៏ធំធេងទាំងនេះ ពិតជាមិនអាចកាត់ផ្តាច់បានពីការរួមចំណែកដ៏សំខាន់ពីការវិនិយោគរបស់វិស័យឯកជន, ការវិនិយោគផ្ទាល់ពីបរទេស, និងជាពិសេស ការវិនិយោគសាធារណៈរបស់រដ្ឋលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានខិតខំវិនិយោគយ៉ាងធំប្រុង និងប្រកបដោយវិការណកម្មខ្ពស់ លើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយប្រើប្រាស់ប្រភពទុនហិរញ្ញប្បទានជាប្រពៃណី ផ្អែកលើលទ្ធភាពថវិកាជាតិដែលខ្លួនមាន និងក៏ដូចជាប្រភពទុនហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានា។ បើទោះជាយ៉ាងនេះក្តី ក៏នៅតែមិនទាន់ឆ្លើយតបបានគ្រប់គ្រាន់ទាំងបរិមាណនិងប្រសិទ្ធភាពចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន ក៏ដូចជាប្រភពទុនហិរញ្ញប្បទានដែលកៀរគរបានពីដៃគូអភិវឌ្ឍន៍នានានៅឡើយ ដែលតម្រូវឱ្យកម្ពុជានៅតែត្រូវបន្តខិតខំកៀរគរការចូលរួមវិនិយោគពីវិស័យឯកជនលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈបន្ថែមទៀត។ ការចូលរួមវិនិយោគពីវិស័យឯកជន មិនត្រឹមតែនាំមកនូវប្រភពទុនហិរញ្ញប្បទានបន្ថែមប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវចំណេះដឹង-ចំណេះធ្វើ ព្រមទាំងបច្ចេកវិទ្យាទំនើបដល់វិស័យសាធារណៈ ក្នុងការរៀបចំនិងគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈប្រកបដោយនវានុវត្តភាព និងកាន់តែមានប្រសិទ្ធិភាពខ្ពស់ជាងមុនទៀតផង។

ចាប់តាំងពីនីតិកាលទី១ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានខិតខំជំរុញ និងលើកទឹកចិត្តវិស័យឯកជនក្នុងការចូលរួមវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដោយបានដាក់ចេញនូវឧបករណ៍គោលនយោបាយ, បទដ្ឋានគតិយុត្ត, និងវិធានការចាំបាច់នានាក្នុងការពង្រឹងភាពជាដៃគូជាមួយគ្រប់អង្គអភិវឌ្ឍន៍ទាំងអស់ឱ្យកាន់តែទូលំទូលាយ ជាក់ស្តែងដូចបានកំណត់ក្នុង៖ (១) យុទ្ធសាស្ត្រត្រីកោណ និងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចលើកទី១ (១៩៩៦-២០០០) និងលើកទី២ (២០០១-២០០៥), (២) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០, (៣) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣, និង (៤) យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។

ក្នុងក្របខណ្ឌនេះ ច្បាប់ស្តីពីសហប្បទាន ក៏ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧ ដែលមានគោលបំណងជំរុញ និងសម្រួលការអនុវត្តគម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហិរញ្ញប្បទានដោយផ្នែកឯកជន។ បើទោះបីជាយ៉ាងនេះក្តី អនុក្រឹត្យ, លិខិតបទដ្ឋានគតិយុត្ត, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការសម្រាប់គាំទ្រការអនុវត្តច្បាប់នេះ នៅមិនទាន់ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្តនៅឡើយ ជាហេតុធ្វើឱ្យយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមិនទាន់អាចអនុវត្តបានទាំងស្រុងនិងមានប្រសិទ្ធភាពពេញលេញ ពោលគឺ កន្លងមក ការរៀបចំ, ការចរចា, និងការគ្រប់គ្រងការអនុវត្តគម្រោង មានភាពប៉ាត់ប៉ាយ ប្រើប្រាស់យន្តការចំពោះកិច្ច, និងគ្មានការវាយតម្លៃហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលមិនទាន់អនុលោមទាំងស្រុងតាមឧត្តមានុវត្តជាអន្តរជាតិនៅឡើយ។

ក្នុងដំណាក់កាលអភិវឌ្ឍថ្មីនេះ កម្ពុជាត្រូវប្រឈមមុខចំពោះបញ្ហាធំៗ ចំនួន ០២ រួមមាន÷ (១) ភាពចាំបាច់ក្នុងការកំណត់ឡើងវិញនូវគោលដៅនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ដោយសារនិន្នាការធ្លាក់ចុះនៃហិរញ្ញប្បទានឥតសំណងលើសកលលោក និងការផ្លាស់ប្តូរគោលនយោបាយផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និមួយៗ និង (២) ការធ្លាក់ចុះនៃឥណទានសម្បទានកម្រិតខ្ពស់ នៅពេលដែលកម្ពុជានឹងទទួលបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ស្របពេលជាមួយគ្នានេះ ចំពោះមុខស្ថានភាពដែលប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើននៅលើសកលលោកកំពុងរងសម្ពាធនៃការកើនឡើងនូវបន្ទុកសេវាបំណុលសាធារណៈ ដែលបណ្តាលមកពីការប្រើប្រាស់យ៉ាងច្រើនលើសលប់នូវឥណទានជាប្រភពធានាសម្រាប់ការវិនិយោគសាធារណៈ ដៃគូអភិវឌ្ឍន៍ពហុភាគីធំៗបានប្រកាសដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មី គឺការប្រើប្រាស់ **"យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គម្រោងវិនិយោគសាធារណៈ"** និងបានត្រៀមខ្លួនជួយដល់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការរៀបចំយន្តការនេះ ទាំងក្របខណ្ឌបច្ចេកទេស និងទាំងក្របខណ្ឌហិរញ្ញវត្ថុ។

បើទោះជាស្ថានភាពបំណុលសាធារណៈរបស់កម្ពុជាមាននិរន្តរភាពក្នុងរយៈពេលវែង ខុសពីស្ថានភាពបំណុលសាធារណៈរបស់ប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍មួយចំនួនក្តី ផ្អែកតាមទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជានៅតែត្រូវការយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលសម្រេចរៀបចំ និងដាក់ឱ្យអនុវត្តនូវ **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥"** ប្រកបដោយភាពគ្រប់ជ្រុងជ្រោយនិងស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដែលនឹងជួយកែលម្អនិងលើកកម្ពស់បរិស្ថានអំណោយផលសម្រាប់បន្តជំរុញការចូលរួមរបស់វិស័យឯកជនលើការវិនិយោគសាធារណៈ, បង្កើតជាប្រភពហិរញ្ញប្បទានថ្មីសម្រាប់បំពេញបន្ថែមលើប្រភពទុនវិនិយោគសាធារណៈជាប្រពៃណីរបស់រដ្ឋ, និងរួមចំណែកដល់ការពង្រឹងការគ្រប់គ្រងកាតព្វកិច្ចបំណុលជាយថាហេតុរបស់កម្ពុជា។ ឯកសារគោលនយោបាយនេះ ដាក់ចេញនូវវិធានការគោលនយោបាយ ដែលជាផែនទីបង្ហាញផ្លូវស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងកំណត់

វិស័យអាទិភាពនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន រួមមាន៖ (១) វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ និង (២) វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង។ ទន្ទឹមនេះ ឯកសារគោលនយោបាយនេះ ក៏បានដាក់ចេញផងដែរនូវផែនការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស សម្រាប់ពង្រឹងសមត្ថភាពមន្ត្រីរាជការ ពាក់ព័ន្ធនឹងវដ្តនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

## ២-ចក្ខុវិស័យ

នៅមុនដំណាក់ឆ្នាំ២០២០ រាជរដ្ឋាភិបាលត្រូវបង្កើត និងអនុវត្តឱ្យបានពេញលេញ នូវប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយភាពប្រទាក់ក្រឡានិងគ្រប់ជ្រុងជ្រោយ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការនេះ។ ការសម្រេចបាននូវចក្ខុវិស័យនេះ នឹងមិនត្រឹមតែគៀរគបានូវហិរញ្ញប្បទានពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុពាក់ព័ន្ធ បន្ថែមលើប្រភពធនហិរញ្ញប្បទានជាប្រពៃណីប៉ុណ្ណោះទេ តែថែមទាំងនាំមកជាមួយនូវបច្ចេកវិទ្យាទំនើប និងនវានុវត្តភាព ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងសមត្ថភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ផងដែរ។

## ៣-គោលបំណង និងគោលដៅ

ឯកសារគោលនយោបាយនេះ មានគោលបំណងជំរុញ និងលើកទឹកចិត្តការវិនិយោគរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការចូលរួមសាងសង់, កសាង, ផ្គត់ផ្គង់, ប្រតិបត្តិការ, និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ព្រមទាំងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ប្រកបដោយនវានុវត្តភាព និងប្រសិទ្ធភាពខ្ពស់ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ សំដៅរួមចំណែកទ្រទ្រង់ចីរភាពនៃកំណើនសេដ្ឋកិច្ចរយៈពេលវែង និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ក្នុងបរិការណ៍នៃសមាហរណកម្មសេដ្ឋកិច្ចតំបន់ និងសកលលោក។

ដើម្បីសម្រេចគោលបំណងខាងលើ តាមរយៈឯកសារគោលនយោបាយនេះ រាជរដ្ឋាភិបាលមានគោលដៅដាក់ចេញនូវយុទ្ធសាស្ត្រ, កំណត់យន្តការស្ថាប័ន, និងបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ សម្រាប់រយៈពេលខ្លី មធ្យម និងវែង សំដៅរៀបចំប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, គណនេយ្យភាព, សង្គតិភាព, និងភាពប្រទាក់ក្រឡាគ្នា ព្រមទាំងរួមចំណែកពង្រឹងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការនេះ។

## ៤-និយមន័យ និងទម្រង់ទូទាត់នៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

ភាពជាដៃគូរវាងរដ្ឋ និងឯកជន សំដៅដល់កិច្ចព្រមព្រៀងវិនិយោគរវាងរដ្ឋ ជាមួយដៃគូឯកជនមួយឬច្រើន ក្នុងការស្ថាបនា, កសាង, ជួសជុល, ថែទាំ, និង/ឬគ្រប់គ្រងប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬ វិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត ឬ ក្នុងការផ្តល់សេវាសាធារណៈ ក្នុងរយៈពេលជាក់លាក់ ដែលភាគីឯកជនត្រូវដាក់ទុនវិនិយោគ ហើយទទួលរ៉ាប់រងហានិភ័យ និងផលប្រយោជន៍ តាមការកំណត់ក្នុងកិច្ចសន្យាសម្បទាន។

ការវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានទូទាត់សងវិញតាម បីទម្រង់ទូទាត់ដូចខាងក្រោម÷

- **ការទូទាត់ផ្អែកលើផលចំណូល** (Revenue-based Payment)÷ ជាទម្រង់ដែលអនុញ្ញាតឱ្យដៃគូឯកជន ប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ ដែលកើតចេញពីគម្រោង។ ទម្រង់នេះ អាចអនុវត្តបានចំពោះគម្រោងវិនិយោគសាធារណៈទាំងឡាយណាដែលមានផលិតភាពសេដ្ឋកិច្ចខ្ពស់ និងមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ ពីអ្នកទទួលសេវាសាធារណៈ។
- **ការទូទាត់ផ្អែកលើថវិកាជាតិ** (Availability-based Payment)÷ ជាទម្រង់ដែលរដ្ឋត្រូវទូទាត់ថ្លៃវិនិយោគ និង/ឬ កម្រៃសេវាពាក់ព័ន្ធ ជូនដៃគូឯកជនដែលវិនិយោគលើការស្ថាបនា, សាងសង់, ជួសជុល, ធ្វើប្រតិបត្តិការ, និង/ឬ ថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ឬផ្តល់សេវាសាធារណៈ។ ទម្រង់នេះ អាចអនុវត្តបានចំពោះករណី÷ (១) រដ្ឋជាអ្នកប្រើប្រាស់ ឬ ជាអ្នកទិញសេវាកម្មដោយផ្ទាល់ ឬ (២) គម្រោងវិនិយោគសាធារណៈមានលក្ខណៈសង្គមកិច្ច ដែលពុំមានលទ្ធភាពប្រមូលចំណូលពីអ្នកប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និង/ឬ អ្នកទទួលសេវាសាធារណៈ។
- **ការទូទាត់តាមវិធីចម្រុះ** (Hybrid Payment) ÷ ជាទម្រង់បានមកពីការផ្សំគ្នារវាងការទូទាត់ផ្អែកលើផលចំណូល និងការទូទាត់ផ្អែកលើថវិកាជាតិ។

## ៥-បរិការណ៍បច្ចុប្បន្ននៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

### ៥-១-បរិការណ៍សកល

#### ៥-១-១-និន្នាការសកល

បច្ចុប្បន្ន ពិភពលោកកំពុងស្ថិតក្នុងស្ថានភាពប្រឈមថ្មី គឺប្រភពទុនជាប្រពៃណីពីថវិកាជាតិ និងពីដៃគូអភិវឌ្ឍន៍មិនអាចបំពេញតម្រូវការទុនវិនិយោគដ៏ច្រើនសន្ធឹកសន្ធាប់ សម្រាប់ការស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈបានឡើយ។ ទន្ទឹមនេះ ប្រទេសកំពុងអភិវឌ្ឍន៍ភាគច្រើន ក៏បាននិងកំពុងទទួលរងនូវសម្ពាធពីការកើនឡើងនៃបន្ទុកសេវាបំរើប្រយោជន៍សាធារណៈដែលបណ្តាលមកពីការប្រើប្រាស់អតិបរមានូវធនធានសម្បទាន និងប្រភេទធនធានផ្សេងទៀតពីដៃគូអភិវឌ្ឍន៍សម្រាប់ហិរញ្ញប្បទានគម្រោងវិនិយោគសាធារណៈ។ ក្នុងបរិការណ៍នេះ ពិភពលោកទាំងមូល ជាពិសេសដៃគូអភិវឌ្ឍន៍ពហុភាគីសំខាន់ៗ បាននាំមុខផ្តួចផ្តើមដាក់ចេញនូវយុទ្ធសាស្ត្រហិរញ្ញប្បទានថ្មី គឺជំរុញការប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមិនត្រឹមតែបំពេញបន្ថែមចំពោះគម្លាតហិរញ្ញប្បទានសម្រាប់ការវិនិយោគសាធារណៈលើវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំដៅកាត់បន្ថយសម្ពាធលើថវិកាជាតិ និងសម្រាលបន្ទុកសេវាបំរើប្រយោជន៍សាធារណៈប៉ុណ្ណោះទេ តែថែមទាំងផ្តល់ឱកាសអភិវឌ្ឍនិងផ្ទេរចំណេះដឹង-ចំណេះធ្វើ, បច្ចេកវិទ្យាទំនើប, ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ, ព្រមទាំងនវានុវត្តភាពដល់វិស័យសាធារណៈទៀតផង។

គំនិតផ្តួចផ្តើមថ្មីនេះ ទាមទារឱ្យមានក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, យន្តការគាំទ្រហិរញ្ញវត្ថុ, ព្រមទាំងវិធាន, នីតិវិធីប្រតិបត្តិការ, និងគោលការណ៍ណែនាំ ប្រកបដោយភាពរឹងមាំ, ច្បាស់លាស់, ប្រសិទ្ធភាពខ្ពស់, និងគ្រប់ជ្រុងជ្រោយ ក្នុងការរៀបចំ, គ្រប់គ្រង, និងអនុវត្តគម្រោងវិនិយោគសាធារណៈ។ ឆ្នាំ២០១៤ គឺជាឆ្នាំដែលដៃគូអភិវឌ្ឍន៍ពហុភាគីសំខាន់ៗ បានចាប់ផ្តើមបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ ក្នុងការជួយអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ដល់ប្រទេសកំពុងអភិវឌ្ឍន៍ ទាំងក្នុងក្របខ័ណ្ឌបច្ចេកទេស និងទាំងក្របខ័ណ្ឌហិរញ្ញវត្ថុ។

#### ៥-១-២-ការអនុវត្តជាសកល

ជាបទពិសោធន៍ ដើម្បីទទួលបាននូវភាពជោគជ័យក្នុងការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន បណ្តាប្រទេសជាច្រើនលើសកលលោក បានរៀបចំក្របខ័ណ្ឌគតិយុត្ត, ក្របខ័ណ្ឌគោលនយោបាយ, យន្តការស្ថាប័ន, យន្តការគាំទ្រហិរញ្ញវត្ថុ, ព្រមទាំងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស ប្រកបដោយភាពរឹងមាំ, ច្បាស់លាស់, និងគ្រប់ជ្រុងជ្រោយ ដូចខាងក្រោម÷

**-ក្របខ័ណ្ឌគោលនយោបាយ និង ក្របខ័ណ្ឌគតិយុត្ត ÷**

ក្របខ័ណ្ឌគោលនយោបាយ ត្រូវដាក់ចេញនូវចក្ខុវិស័យជាយុទ្ធសាស្ត្ររយៈពេលវែងរបស់រដ្ឋាភិបាលចំពោះយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយត្រូវកំណត់ច្បាស់លាស់នូវគោលដៅ, វិស័យអាទិភាព,

ទម្រង់ទូទាត់នៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, និងយន្តការគ្រប់គ្រង ដើម្បីធានាបាននូវការឯកភាពផ្ទៃក្នុងរបស់រដ្ឋាភិបាលសំដៅផ្តល់នូវភាពអាចប៉ាន់ប្រមាណបាន និងភាពអាចជឿទុកចិត្តបានរបស់វិនិយោគិន និងស្ថាប័នហិរញ្ញវត្ថុក្នុងការចូលរួមរៀបចំ និងអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ក្របខ័ណ្ឌគតិយុត្ត ត្រូវបញ្ញត្តិនូវវិធានជាសារវ័ន្ត សម្រាប់ការគ្រប់គ្រង និងអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន, កំណត់ឲ្យច្បាស់លាស់អំពីស្ថាប័នមានសមត្ថកិច្ច, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, យន្តការដោះស្រាយវិវាទ, ព្រមទាំងប្រព័ន្ធពន្ធ និងអាករ ដែលត្រូវអនុវត្តក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ការជ្រើសរើសដៃគូឯកជន ក្នុងគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវតែធ្វើឡើងតាម **"កិច្ចលទ្ធកម្ម"** ដែលមានការប្រកួតប្រជែងដោយតម្លាភាព និងយុត្តិធម៌ ទាំងគម្រោងផ្តួចផ្តើមដោយរដ្ឋ និងទាំងគម្រោងផ្តួចផ្តើមដោយដៃគូឯកជន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តរបស់វិស័យឯកជន ក្នុងការចូលរួមវិនិយោគសាធារណៈ និងធានាបាននូវផលសេដ្ឋកិច្ច, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាពខ្ពស់ នៃគម្រោង។

**-យន្តការស្ថាប័ន÷** តួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន ពាក់ព័ន្ធនឹងវដ្តនៃគម្រោង គិតចាប់ពីដំណាក់កាលធ្វើអត្តសញ្ញាណកម្មគម្រោង រហូតដល់ដំណាក់កាលវាយតម្លៃបញ្ចប់គម្រោង ចាំបាច់ត្រូវតែកំណត់ និងបែងចែកឱ្យបានច្បាស់លាស់រវាងមុខងារធំៗចំនួន ០៣ រួមមាន÷ (១) ការធ្វើអត្តសញ្ញាណកម្ម, ការរៀបចំ, និងគ្រប់គ្រងការអនុវត្តគម្រោង ជាសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នជំនាញ; (២) ការពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព ជាសមត្ថកិច្ចរបស់គណៈកម្មការអន្តរក្រសួង ដែលភាគច្រើនត្រូវបានដឹកនាំដោយក្រសួងហិរញ្ញវត្ថុ; និង (៣) ការសម្របសម្រួល, ការតាមដានត្រួតពិនិត្យ, និងការវាយតម្លៃគម្រោង ដែលភាគច្រើនជាសមត្ថកិច្ចចំមុខរបស់ក្រសួងហិរញ្ញវត្ថុ។ ខន្ទឹមនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ចាំបាច់ត្រូវតែមានធនធានមនុស្សដែលមានសមត្ថភាពខ្ពស់ និងប្រព័ន្ធប្រតិបត្តិការរឹងមាំ ក្នុងការបំពេញមុខងារ និងភារកិច្ច ផងដែរ។

**-យន្តការគាំទ្រហិរញ្ញវត្ថុ÷** ក្នុងការជំរុញការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ប្រទេសភាគច្រើនបានបង្កើតមូលនិធិពិសេសចំនួន ០២ ដែលគ្រប់គ្រងដោយក្រសួងហិរញ្ញវត្ថុ រួមមាន÷

- **មូលនិធិអភិវឌ្ឍន៍គម្រោង** (Project Development Facility - PDF) មានគោលដៅគាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការរៀបចំគម្រោង ចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពបឋមរហូតដល់ការប្រគល់កិច្ចសន្យាសម្បទាន។
- **មូលនិធិបំពេញផលហិរញ្ញវត្ថុ** (Viability Gap Fund - VGF) មានគោលដៅជួយឧបត្ថម្ភដល់គម្រោងវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈមួយចំនួន ឬគម្រោងក្នុងវិស័យបង្កើនផលិតភាព

សេដ្ឋកិច្ច ឬគម្រោងក្នុងវិស័យសង្គមកិច្ច ឱ្យមានភាពទាក់ទាញពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ព្រមទាំងកេនពលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ដាក់ឱ្យអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

### ៥-២-បរិការណ៍កម្ពុជា

### ៥-២-១-ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត និងយន្តការស្ថាប័ន

ក្នុងបរិការណ៍នៃនិន្នាការជាសកលខាងលើ រាជរដ្ឋាភិបាលពិនិត្យឃើញថា យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ពិតជាមានសារៈសំខាន់ក្នុងការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ក្នុងដំណាក់កាលថ្មីរបស់កម្ពុជា ជាពិសេស នៅពេលដែលសេដ្ឋកិច្ចកម្ពុជាកាន់តែមានការរីកចម្រើនធំធាត់ ក្នុងដំណើរឆ្ពោះទៅមកយ៉ាងស្វាហាប់ ចាកចេញពីប្រទេសមានចំណូលទាប នៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដែលនឹងធ្វើឱ្យកម្ពុជាលែងស្ថិតក្នុងក្រុមប្រទេសដែលអាចទទួលបាននូវហិរញ្ញប្បទានឥតសំណង និងឥណទានដែលមានកម្រិតសម្បទានខ្ពស់ពីដៃគូអភិវឌ្ឍន៍ទៀត។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលត្រូវមានអប្បមាទខ្ពស់លើប្រសិទ្ធភាពនៃការវិនិយោគ និងការគ្រប់គ្រងហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុ ដែលអាចនឹងកើតចេញពីការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

ថ្មីៗនេះ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល បានបន្តកំណត់យកវិស័យឯកជនជាក្បាលម៉ាស៊ីនសម្រាប់ជំរុញកំណើន, បង្កើតការងារ, និងកាត់បន្ថយភាពក្រីក្រ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានអំណោយផលអនុគ្រោះដល់ការវិនិយោគនិងធុរកិច្ច និងការពង្រឹងភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធសាធារណៈ។

ក្នុងបរិការណ៍បច្ចុប្បន្នរបស់កម្ពុជា ក្របខ័ណ្ឌគតិយុត្ត, យុទ្ធសាស្ត្រ, និងគោលនយោបាយដែលមានស្រាប់សម្រាប់ជំរុញ និងលើកទឹកចិត្តវិស័យឯកជននិងស្ថាប័នហិរញ្ញវត្ថុ ឱ្យចូលរួមវិនិយោគសាធារណៈ រួមមាន÷

- ច្បាប់ស្តីពីសម្បទាន;
- ច្បាប់ស្តីពីវិនិយោគ;
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ;
- ច្បាប់ស្តីពីភូមិបាល;
- ច្បាប់ស្តីពីផ្លូវថ្នល់;
- ច្បាប់ស្តីពីប្រតិបត្តិការដែលមានការធានា;
- ច្បាប់ស្តីពីសារពើពន្ធ;
- ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ;
- ច្បាប់ស្តីពីមូលបត្ររដ្ឋ;

- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន;
- ច្បាប់ស្តីពីអស្សាមិករណ៍;
- ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម;
- ច្បាប់ស្តីពីគយ;
- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០;
- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥។ល។

បើទោះបីជាមានលិខិតបទដ្ឋានគតិយុត្ត, យុទ្ធសាស្ត្រ, និងគោលនយោបាយអភិវឌ្ឍន៍តាមវិស័យទាំងនេះក្តី ក៏ការរៀបចំ និងការគ្រប់គ្រងលើការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមានភាពខ្វះចន្លោះ មិនប្រមូលផ្តុំ ដោយសារមិនទាន់មានក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌគោលនយោបាយរួម ដែលមានភាពគ្រប់ជ្រុងជ្រោយ នៅឡើយ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលត្រូវពិនិត្យឡើងវិញលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ដោយត្រូវធ្វើវិសោធនកម្ម និងរៀបចំលិខិតបទដ្ឋានគតិយុត្តបន្ថែម តាមការចាំបាច់ ដើម្បីបំពេញលក្ខខណ្ឌតម្រូវជាសារវន្ត ស្របតាមឧត្តមានុវត្តជាអន្តរជាតិ។

លើសពីនេះ កន្លងមក គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន ភាគច្រើនជាគម្រោងវិនិយោគក្នុងវិស័យអគ្គិសនី និងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ដូចជា ផ្លូវថ្នល់, ស្ពាន, និងព្រលានយន្តហោះ ត្រូវបានផ្តួចផ្តើមស្នើនិងសិក្សាដោយវិស័យឯកជន ដោយប្រើប្រាស់ទម្រង់ **"សាងសង់-អាជីវកម្ម-ផ្ទេរ"**, **"សាងសង់-ធ្វើម្ចាស់-អាជីវកម្ម"**, និង **"ថែទាំ-ប្រតិបត្តិ-ផ្ទេរ"**។ ផ្អែកតាមសំណើរបស់វិស័យឯកជន ក្រសួង ស្ថាប័នពាក់ព័ន្ធ ពិនិត្យលើសំណើគម្រោង ដោយបានសិក្សាវិភាគ និងវាយតម្លៃលើ÷ អត្ថប្រយោជន៍, តម្លៃគម្រោង, អត្រាតម្លៃត្រូវបង់ពីអ្នកប្រើប្រាស់និងអត្រាចំណូលផ្ទៃក្នុង, ផលប៉ះពាល់និងហានិភ័យពាក់ព័ន្ធ, ព្រមទាំងលក្ខខណ្ឌផ្សេងទៀតនៃគម្រោង មុននឹងឈានដល់ការចរចា និងចុះកិច្ចសន្យាសម្បទាន។

ទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញថា កម្ពុជានៅប្រើប្រាស់យន្តការចំពោះកិច្ច សម្រាប់គម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមិនស្របតាមឧត្តមានុវត្តជាអន្តរជាតិ ដែលបាននិងកំពុងអនុវត្តដោយជោគជ័យ និងមានប្រសិទ្ធភាពខ្ពស់នៅក្នុងបណ្តាប្រទេសជាច្រើនក្នុងពិភពលោក ជាពិសេស ការផ្តួចផ្តើម និងការដឹកមុខដោយក្រសួង ស្ថាប័នរដ្ឋ ក្នុងដំណើរការធ្វើអត្តសញ្ញាណកម្ម, សិក្សា, រៀបចំ, និងវាយតម្លៃគម្រោង ព្រមទាំងការជ្រើសរើសក្រុមហ៊ុនសម្បទានិកតាមរយៈការដេញថ្លៃដោយតម្លាភាព និងយុត្តិធម៌។ ក្នុងន័យនេះ រាជរដ្ឋាភិបាលជំរុញ និងលើកទឹកចិត្តឱ្យក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើរតួនាទីជាយុទ្ធសាស្ត្រវិទូ, អ្នកសម្របសម្រួល, គាំទ្រ, និងជាអ្នកផ្តួចផ្តើម ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្នុងការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមរយៈការកំណត់យន្តការស្ថាប័នដោយត្រូវមានការបែងចែកមុខងារច្បាស់លាស់។ ទន្ទឹមនេះ ក្រសួង ស្ថាប័នសាមី ត្រូវរៀបចំបញ្ជីគម្រោងវិនិយោគ

សាធារណៈរួមតាមវិស័យ ដោយត្រូវរួមបញ្ចូលនូវគម្រោងវិនិយោគផ្ទាល់ដោយរដ្ឋ, គម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍, និងគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

### ៥-២-២-បញ្ហាប្រឈម និងកាលានុវត្តភាព

#### ៥-២-២-១-បញ្ហាប្រឈម

- *ក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ*

ច្បាប់ស្តីពីសម្បទាន ដែលកំណត់អំពីការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ តាមកិច្ចសន្យាសម្បទាន ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ២០០៧។ បើទោះបីជាយ៉ាងនេះក្តី បទប្បញ្ញត្តិស្តីពីតួនាទីមួយចំនួនរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ នៅមិនទាន់ចែងឱ្យបានច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ព្រមទាំងមិនទាន់ស្របតាមនិន្នាការជាសកល និងឧត្តមានុវត្តជាអន្តរជាតិនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នាពេលបច្ចុប្បន្ននៅឡើយ។ ទន្ទឹមនេះ កន្លងមក គម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវបានគ្រប់គ្រង និងអនុវត្តតាមនីតិវិធីគម្រោងវិនិយោគសាធារណៈធម្មតា ដោយពុំទាន់ឆ្លើយតបតាមលក្ខខណ្ឌតម្រូវជាសារវន្ត ដែលតម្រូវឱ្យមាននីតិវិធីដោយឡែក ជាពិសេសនីតិវិធីលទ្ធកម្ម, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, និងយន្តការគាំទ្រហិរញ្ញវត្ថុ (ដូចបានបង្ហាញជូនក្នុងផ្នែក ៥.១.២ ស្តីពីការអនុវត្តជាសកល) នៅឡើយ។

- *យន្តការស្ថាប័ន*

ជារួម កម្ពុជាមិនទាន់មានយន្តការស្ថាប័នច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ សម្រាប់គ្រប់គ្រងវដ្តនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននៅឡើយ ដោយបានអនុវត្តដោយឡែកពីគ្នាតាមក្រសួង ស្ថាប័នជំនាញនីមួយៗ ឬ គម្រោងនីមួយៗ ពោលគឺបានប្រើប្រាស់យន្តការចំពោះកិច្ច និងគ្មានការពិនិត្យនិងវាយតម្លៃលើហានិភ័យហិរញ្ញវត្ថុនៃគម្រោង ដែលអាចបង្កើតឱ្យមានបន្ទុកហិរញ្ញវត្ថុជាយថាហេតុដ៏ធំបំផុតចំពោះថវិកាជាតិ។ ការអនុវត្តតាមយន្តការនេះ បណ្តាលឱ្យ÷ បាត់បង់ភាពទាក់ទាញនៃការចូលរួមពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ, ធ្លាក់ចុះនូវប្រសិទ្ធភាពនៃគម្រោង, និងប្រឈមនូវហានិភ័យខ្ពស់នៃកាតព្វកិច្ចបំណុលជាយថាហេតុចំពោះថវិកាជាតិ។ បរិការណ៍នេះ បានបង្កើតឡើងនូវស្ថានភាពមិនច្បាស់លាស់អំពីតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័នដែលត្រូវមានសមត្ថកិច្ចចូលរួមក្នុងវដ្តនៃគម្រោង រួមមាន÷ (១) ការធ្វើអត្តសញ្ញាណកម្ម, ការរៀបចំ, និងការគ្រប់គ្រងការអនុវត្តគម្រោង; (២) ការពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព; និង (៣) ការសម្របសម្រួល, ការតាមដានត្រួតពិនិត្យ, និងការវាយតម្លៃគម្រោង។

- *សមត្ថភាពជំនាញ និងបច្ចេកទេស*

ការចូលរួមរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មិនត្រឹមតែត្រូវបានចាត់ទុកជាប្រភពហិរញ្ញប្បទានថ្មីសម្រាប់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច បន្ថែមលើប្រភពហិរញ្ញប្បទាន

ជាប្រពៃណី ប៉ុណ្ណោះទេ តែថែមទាំងនាំមកនូវឱកាសអភិវឌ្ឍ, ការផ្ទេរចំណេះដឹង-ចំណេះធ្វើ, ការបញ្ចូលបច្ចេកវិទ្យាទំនើប, ការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ, និងនវានុវត្តភាពដល់ស្ថាប័នរដ្ឋនាពេលអនាគតទៀតផង។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏មើលឃើញថា យន្តការនេះមានភាពស្មុគស្មាញជាងគម្រោងវិនិយោគសាធារណៈធម្មតា ដូចជា÷ (១) ត្រូវតែជាគម្រោងដែលមានភាពទាក់ទាញពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ, (២) ប្រើប្រាស់នីតិវិធីកិច្ចលទ្ធកម្មដោយឡែក ផ្សេងពីនីតិវិធីកិច្ចលទ្ធកម្មសាធារណៈ; និង (៣) ការបែងចែកហានិភ័យ និងផលប្រយោជន៍សមស្រប រវាងភាគីពាក់ព័ន្ធជាច្រើន ដូចជា÷ ក្រសួង ស្ថាប័នរដ្ឋ, ក្រុមហ៊ុនសម្បទានិក, ស្ថាប័នហិរញ្ញវត្ថុ, អ្នកទទួលផល និងអ្នកទទួលរងផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ ជាដើម ដែលតម្រូវឱ្យមន្ត្រីពាក់ព័ន្ធមានសមត្ថភាពជំនាញខ្ពស់។ ដូច្នេះ ការលើកកម្ពស់សមត្ថភាពជំនាញនិងបច្ចេកទេសរបស់មន្ត្រី និងសមត្ថភាពស្ថាប័ន នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ជាកត្តាកំណត់ភាពជោគជ័យនៃការរៀបចំនិងអនុវត្តគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

### ៥-២-២-២-កាលានុវត្តភាព

បើទោះបីជាមានបញ្ហាប្រឈមខាងលើក្តី យន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតែមានសារៈសំខាន់ចំពោះបរិការណ៍ថ្មីនៃសេដ្ឋកិច្ចកម្ពុជា ដែលរាជរដ្ឋាភិបាលចាំបាច់ត្រូវជំរុញឱ្យបាន ដោយឈរលើមូលដ្ឋាននៃកាលានុវត្តភាពដូចខាងក្រោម÷

- ការជំរុញ និងលើកកម្ពស់វិស័យឯកជន ក្នុងការចូលរួមវិនិយោគសាធារណៈ ត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាកិច្ចការអាទិភាព និងកំណត់យកជាគោលដៅយុទ្ធសាស្ត្រ ដែលត្រូវសម្រេចឱ្យបានក្រោមយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣ និងផែនការអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។
- ការកើនឡើងក្នុងសន្ទុះលឿនគួរឱ្យកត់សម្គាល់របស់វិស័យឯកជននៅកម្ពុជាជាងមួយទសវត្សរ៍ចុងក្រោយ ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើននៃការវិនិយោគផ្ទាល់ពីបរទេស ពី ៣៨៥ លានដុល្លារអាមេរិក នៅឆ្នាំ ២០០៥ ដល់ ១,៣ ពាន់លានដុល្លារអាមេរិក នៅឆ្នាំ ២០១៥ និងកំណើននៃប្រាក់បញ្ញើរបស់វិស័យឯកជន ពី ១,៦ ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០០៨ ដល់ជាង ៤ ពាន់លានដុល្លារអាមេរិក នៅឆ្នាំ២០១៤ ជាសូចនាកររឹងមាំបង្ហាញថាវិស័យឯកជន កំពុង ហើយនឹងកាន់តែមានលទ្ធភាពខ្ពស់ក្នុងការចូលរួមវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ការកើនឡើងនៃសំណើសុំវិនិយោគរបស់វិស័យឯកជន តាមទម្រង់ **"សាងសង់-អាជីវកម្ម-ផ្ទេរ"** ដែលជាទម្រង់មួយនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេស ក្នុងវិស័យផ្លូវថ្នល់, ស្ពាន, និងថាមពល ជាដើម ជាសញ្ញាបង្ហាញថា ទីផ្សារនៃការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជនរបស់កម្ពុជា មានសក្តានុពល និងភាពទាក់ទាញខ្លាំង បើទោះបីជាកំពុងស្ថិតក្នុងដំណាក់កាលអន្តរកាល ដែលនៅពុំទាន់មានក្របខ័ណ្ឌ

គោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត, យន្តការស្ថាប័ន, យន្តការគាំទ្រហិរញ្ញវត្ថុ, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន គ្រប់គ្រាន់ក៏ដោយ។

- បទពិសោធន៍ទទួលបានពីបណ្ដាប្រទេសក្នុងតំបន់ និងបណ្ដាប្រទេសជាច្រើនទៀត ព្រមទាំងបទពិសោធន៍របស់កម្ពុជាក្នុងការកំណត់អត្តសញ្ញាណគម្រោង, ការរៀបចំ, និងការគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈមួយចំនួនក្នុងវិស័យថាមពលអគ្គិសនី និងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ដូចជាផ្លូវថ្នល់, ស្ពាន, និងព្រលានយន្តហោះ តាមទម្រង់ **"សាងសង់-អាជីវកម្ម-ផ្ទេរ"** និង **"សាងសង់-អាជីវកម្ម-ធ្វើម្ចាស់"** និងគម្រោងផ្លូវជាតិលេខ៤ តាមទម្រង់ **"ថែទាំ-ប្រតិបត្តិការ-ផ្ទេរ"** គឺជាមូលដ្ឋានដ៏រឹងមាំសម្រាប់ការចាប់ផ្តើមអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅកម្ពុជា ប្រកបដោយភាពប្រយ័ត្នប្រយែង និងគ្រប់ជ្រុងជ្រោយ។

- ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិធំៗនៅលើពិភពលោក បាននិងកំពុងផ្ដល់អាទិភាពខ្ពស់លើការចូលរួមរបស់វិស័យឯកជន ក្នុងការវិនិយោគលើគម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ហើយបានត្រៀមខ្លួនជាស្រេចក្នុងការផ្ដល់ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ គាំទ្រដល់ការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍។

## ៦-យុទ្ធសាស្ត្រ

ដើម្បីសម្រេចនូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាលគឺការរៀបចំ និងដាក់ចេញនូវវិធានការគោលនយោបាយ សំដៅរួមចំណែកបង្កើតឡើងនូវបរិស្ថានអំណោយផលសម្រាប់បន្តលើកកម្ពស់ការចូលរួមរបស់វិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដោយនឹងត្រូវអនុវត្តតាមអភិក្រមប្រយ័ត្នប្រយែង ជាជំហានៗដែលរួមមាន÷ (១) ការចាប់ផ្តើមពីការពិនិត្យនិងកែសម្រួលនូវក្របខ័ណ្ឌគតិយុត្ត, ការរៀបចំនិងដាក់ឱ្យអនុវត្តនីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ការបង្កើតយន្តការគាំទ្រហិរញ្ញវត្ថុតាមការចាំបាច់, និងការកំណត់យន្តការស្ថាប័នឱ្យបានច្បាស់លាស់ ព្រមទាំងការបង្កើតគណៈកម្មការអន្តរក្រសួង ជាស្ថាប័ន សម្រាប់គ្រប់គ្រង និងសម្របសម្រួលអនុវត្តយុទ្ធសាស្ត្រនេះ; (២) អភិក្រម **"រៀនផង-ធ្វើផង"** ដោយរៀនសូត្រពីបទពិសោធន៍ជាក់ស្តែងនៅគ្រប់ដំណាក់កាលអនុវត្តនៃវដ្តរបស់គម្រោង ជាពិសេស ការធ្វើអត្តសញ្ញាណកម្មគម្រោង, រៀបចំបញ្ជីគម្រោងអាទិភាព, សិក្សាសមិទ្ធិលទ្ធភាព, ធ្វើកិច្ចលទ្ធកម្ម, និងគ្រប់គ្រងការអនុវត្តគម្រោង ដើម្បីឈានទៅធ្វើការកែលម្អប្រព័ន្ធគ្រប់គ្រងយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ឱ្យមានសុក្រឹតភាព, ប្រសិទ្ធភាព, និងស័ក្តិសិទ្ធិភាព។ ក្នុងដំណាក់កាលរៀនផង-ធ្វើផងនេះ ដោយឈរលើគោលការណ៍ប្រុងប្រយ័ត្នខ្ពស់ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តតែគម្រោងដែលផ្តួចផ្តើមដោយរដ្ឋ (Solicited Proposals) ប៉ុណ្ណោះ។ បើទោះបីជាយ៉ាងដូចនេះក្តី រាជរដ្ឋាភិបាលនៅតែរក្សាភាពទន់ភ្លន់ ក្នុងការទទួលយកគម្រោងផ្តួចផ្តើមដោយផ្នែកឯកជន (Unsolicited Proposals) មួយចំនួន ដែលមាននវានុវត្តភាពកម្រិតខ្ពស់ មកពិនិត្យលទ្ធភាពក្នុងការដាក់ឱ្យអនុវត្តផងដែរ; និង (៣) ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស តាមក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្នុងដំណាក់កាលអន្តរកាលនៃការរៀបចំប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈថ្មី តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជននេះ កម្ពុជានៅតែបន្តអនុវត្តប្រព័ន្ធគ្រប់គ្រងដែលមានស្រាប់ រហូតដល់ប្រព័ន្ធថ្មីត្រូវបានដាក់ឱ្យអនុវត្តពេញលេញ ដើម្បីធានាការបន្តស្ថិរភាពនៃចលនការអភិវឌ្ឍរបស់កម្ពុជា។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ដែលផ្តល់ផលភ្លាមៗ និងវិធានការគោលនយោបាយរយៈពេលមធ្យម និងវែង ដូចខាងក្រោម÷

### ៦-១-វិធានការគោលនយោបាយបន្ទាន់ចំពោះមុខ

ផ្អែកតាមនិន្នាការ និងការអនុវត្តជាសកល ព្រមទាំងបញ្ហាប្រឈម និងកាលានុវត្តភាពដូចបានវិភាគខាងលើ រាជរដ្ឋាភិបាលសម្រេចដាក់ចេញនូវវិធានការគោលនយោបាយបន្ទាន់ចំពោះមុខមួយចំនួន ដូចខាងក្រោម÷

១. ក្នុងដំណាក់កាលអន្តរកាល បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានភារកិច្ច៖

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងធ្វើវិសោធនកម្មតាមការចាំបាច់;
- រៀបចំអនុក្រឹត្យ, ប្រកាស, លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ, នីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ជាពិសេសនីតិវិធីគ្រប់គ្រងកិច្ចលទ្ធកម្ម តាមយន្តការនេះ និងនីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុ;
- ពិនិត្យ និងអនុម័ត៖ បញ្ជីគម្រោងអាទិភាពតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពទាំងនោះ។ ទន្ទឹមនេះ ក្នុងដំណាក់កាលអន្តរកាល គណៈកម្មការអន្តរក្រសួងនេះ មានភារកិច្ចពិនិត្យ និងអនុម័ត បញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាសមិទ្ធិលទ្ធភាពគម្រោងអាទិភាពដែលនឹងដាក់ឱ្យអនុវត្តសាកល្បង តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលនឹងត្រូវធ្វើឡើងតាមគោលការណ៍ប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព, តម្លាភាព, យុត្តិធម៌ និងដោយមានការផ្សព្វផ្សាយជាសាធារណៈ។

មុខងារ និងភារកិច្ចទាំងនេះ នឹងត្រូវផ្ទេរជូនយន្តការអចិន្ត្រៃយ៍ដែលនឹងត្រូវពិនិត្យ និងសម្រេច ដោយរាជរដ្ឋាភិបាល នាពេលសមស្របខាងមុខ។

២. បង្កើត និងដាក់ឱ្យអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោង **(Project Development Facility - PDF)** សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការរៀបចំគម្រោង ដោយគិតចាប់ពីដំណាក់កាលសិក្សាសមិទ្ធិលទ្ធភាពបឋម ឬលម្អិត រហូតដល់ដំណាក់កាលប្រគល់កិច្ចសន្យាសម្បទាន។

៣. រៀបចំ និងកំណត់យន្តការស្ថាប័ន ដោយ៖

- ធ្វើសមាហរណកម្មមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងអង្គភាពគ្រប់គ្រងហានិភ័យ នៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាគាំទ្របច្ចេកទេសពាក់ព័ន្ធ ដល់គណៈកម្មការអន្តរក្រសួង និងក្រសួង ស្ថាប័នតាមវិស័យ ព្រមទាំងជាលេខាធិការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបំពេញមុខងារគ្រប់គ្រងប្រតិបត្តិការ, សម្របសម្រួល, តាមដានត្រួតពិនិត្យ, និងវាយតម្លៃគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;
- បង្កើត ឬធ្វើសមាហរណកម្មមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យ ក្នុងការសម្របសម្រួលធ្វើអត្តសញ្ញាណកម្មគម្រោង, រៀបចំសំណើបញ្ជី

គម្រោងអាទិភាព, សិក្សាលទ្ធភាព, ធ្វើកិច្ចលទ្ធកម្ម, និងគ្រប់គ្រងការអនុវត្តគម្រោងវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

៤ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន ដើម្បីបញ្ចៀសសម្ពាធលើថវិកាជាតិ ក្នុងជំហានដំបូងនៃការចាប់ផ្ដើមការវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ត្រូវផ្ដោតលើគម្រោងអាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចខ្ពស់មួយចំនួនសិន ដោយត្រូវអនុវត្តតាមទម្រង់ **"ការទូទាត់ផ្អែកលើផលចំណូល"** (Revenue-based Payment)។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសម្រេចកំណត់វិស័យអាទិភាពដែលត្រូវជ្រើសរើសគម្រោងវិនិយោគសាធារណៈសម្រាប់ដាក់ឱ្យអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដូចខាងក្រោម÷

- ប្រព័ន្ធបណ្តាញដឹកជញ្ជូន ដូចជា÷ ផ្លូវថ្នល់, ស្ពាន, ផ្លូវដែក, ផែ, និងអាកាសយានដ្ឋាន;
- ការផលិត, ការបញ្ជូន, និងការចែកចាយថាមពលអគ្គិសនី;
- ការផលិត, ការផ្គត់ផ្គង់, និងការចែកចាយទឹកស្អាត;
- ការអភិវឌ្ឍ, ការធ្វើទំនើបកម្មទីផ្សារ និងចំណតយានយន្តសាធារណៈ, ឬមជ្ឈមណ្ឌលពាណិជ្ជកម្មសាធារណៈ;
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈតំបន់ឧស្សាហកម្ម;
- សេវាគ្រប់គ្រង និងសម្អាតកាកសំណល់;
- ប្រព័ន្ធតម្រោះ និងប្រព័ន្ធបង្ហូរទឹកស្អុយ;
- ការអភិវឌ្ឍសមត្ថភាពជំនាញវិជ្ជាជីវៈ;
- ហេដ្ឋារចនាសម្ព័ន្ធលំនៅដ្ឋានសង្គមកិច្ច;
- ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ ដូចជាមណ្ឌលទេសចរណ៍, សារមន្ទីរ ជាដើម;
- វិស័យបង្កើនផលិតភាពសេដ្ឋកិច្ច និងវិស័យអាទិភាពផ្សេងទៀត ដែលរាជរដ្ឋាភិបាលនឹងកំណត់ក្នុងអំឡុងពេលនៃការអនុវត្តឯកសារគោលនយោបាយនេះ។

៥ រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស(ដូចមានលម្អិតក្នុងឧបសម្ព័ន្ធ)។

### ៦-២-វិធានការគោលនយោបាយរយៈពេលមធ្យម និងវែង

ដើម្បីបន្តវេននៃការអនុវត្តវិធានការគោលនយោបាយបន្ទាន់ចំពោះមុខ ក្នុងរយៈពេលមធ្យម រាជរដ្ឋាភិបាលនឹង÷

១. បន្តពិនិត្យ និងកែសម្រួលឡើងវិញ តាមការចាំបាច់ នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ, យន្តការស្ថាប័ន, នីតិវិធីគ្រប់គ្រងយន្តការគាំទ្រហិរញ្ញវត្ថុ, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន;

២. ពិនិត្យលទ្ធភាពលើការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តមូលនិធិបំពេញគម្លាតហិរញ្ញវត្ថុ (Viability Gap Fund - VGF) ដែលមានគោលដៅផ្តល់ឧបត្ថម្ភធនដល់គម្រោងវិនិយោគសាធារណៈមួយចំនួន ឱ្យមានភាពទាក់ទាញពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ;

៣. ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស;

៤. លើមូលដ្ឋាននៃភាពជោគជ័យនៃការអនុវត្តគម្រោងសាកល្បងក្នុងដំណាក់កាលបឋម ក្នុងរយៈពេលមធ្យម រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពបង្កើនចំនួនគម្រោងក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ចផ្សេងទៀត សំដៅរួមចំណែកជំរុញចីរភាពនៃកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន និងបង្កើនសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងតំបន់ និងសកលលោក ហើយក៏នឹងអាចពិចារណាឈានទៅអនុវត្តតាមទម្រង់ទូទាត់ផ្សេងទៀត ដូចជា **"ការទូទាត់ផ្អែកលើថវិកាជាតិ"** (Availability-based Payment) និង **"ការទូទាត់តាមវិធីចម្រុះ"** (Hybrid Payment) ផងដែរ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងធ្វើបច្ចុប្បន្នកម្មបញ្ជីគម្រោងអាទិភាពផ្អែកលើបរិការណ៍សេដ្ឋកិច្ចជាក់ស្តែង ដោយនឹងពិនិត្យលទ្ធភាពឈានទៅបន្ថែមវិស័យអាទិភាពមួយចំនួនទៀត ដូចខាងក្រោម÷

- ហេដ្ឋារចនាសម្ព័ន្ធវិស័យឧស្ម័ន និងប្រេងកាត ដូចជាប្រព័ន្ធបណ្តាញចែកចាយប្រេង និងឧស្ម័ន;
- វិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន;
- ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធធារាសាស្ត្រ និងកសិកម្ម; និង
- វិស័យអាទិភាពផ្សេងទៀត។

ទន្ទឹមនេះ ក្នុងរយៈពេលវែង រាជរដ្ឋាភិបាលអាចនឹងពិនិត្យលទ្ធភាពលើការវិនិយោគសាធារណៈ តាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងវិស័យសង្គមកិច្ចបន្ថែមទៀត ដូចជា÷

- ហេដ្ឋារចនាសម្ព័ន្ធសេវាសុខភាពសាធារណៈ;
- ហេដ្ឋារចនាសម្ព័ន្ធអប់រំ និងកីឡា ជាដើម។

## ៧-ផែនការសកម្មភាពស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

ដើម្បីគាំទ្រការអនុវត្តវិធានការគោលនយោបាយជាយុទ្ធសាស្ត្រខាងលើ ប្រកបដោយប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, តម្លាភាព, និងគណនេយ្យភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងឋានៈជាសេនាធិការរបស់រាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកជាស្ថាប័ននាំមុខ ក្នុងការសម្របសម្រួលលើការអនុវត្តផែនការសកម្មភាព ដូចបានកំណត់លម្អិតក្នុងតារាងខាងក្រោម÷

# ផែនការសកម្មភាពស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

## សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០

| ទិសដៅគោលនយោបាយ | សកម្មភាព | | ក្រសួង/ស្ថាប័នទទួលបន្ទុក | ប្រភពហិរញ្ញប្បទាន |
|---|---|---|---|---|
| | ឆ្នាំ២០១៦-២០១៨ | ឆ្នាំ២០១៩-២០២០ | | |
| ១.ការពិនិត្យ និងរៀបចំក្របខ័ណ្ឌគតិយុត្ត, និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ | – ក្នុងដំណាក់កាលអន្តរកាល បង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានការចូលរួមពីក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមានភារកិច្ច ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃជំពូក ៦-១;<br>– ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងធ្វើវិសោធនកម្មតាមការចាំបាច់;<br>– រៀបចំអនុក្រឹត្យ ប្រកាស, ណែនាំបទដ្ឋានគតិយុត្តពាក់ព័ន្ធ, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, ព្រមទាំងនីតិវិធីគ្រប់គ្រងកិច្ចលទ្ធកម្ម; | – ពិនិត្យ និងកែសម្រួលឡើងវិញតាមការចាំបាច់ ដើម្បីបង្កើតយន្តការស្ថាប័នអចិន្ត្រៃយ៍;<br>– ពិនិត្យ និងកែសម្រួលឡើងវិញតាមការចាំបាច់នូវក្របខ័ណ្ឌគតិយុត្តពាក់ព័ន្ធ, យន្តការស្ថាប័ន និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការ។ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | -រាជរដ្ឋាភិបាល ADB, និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត |

| វិធានការគោលនយោបាយ | សកម្មភាព | | ក្រសួង/ស្ថាប័នទទួលបន្ទុក | ប្រភពហិរញ្ញប្បទាន |
|---|---|---|---|---|
| | ឆ្នាំ២០១៦-២០១៨ | ឆ្នាំ២០១៩-២០២០ | | |
| | - ដាក់ឱ្យអនុវត្តគម្រោងសាកល្បងចំនួន២-៣គម្រោង។ | | | |
| ២. ការរៀបចំយន្តការគាំទ្រហិរញ្ញវត្ថុ | - បង្កើត និងដាក់ឱ្យអនុវត្តមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility - PDF) សម្រាប់គាំទ្រដល់ក្រសួង ស្ថាប័នជំនាញ ក្នុងការសិក្សារៀបចំគម្រោង។<br>- រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃមូលនិធិអភិវឌ្ឍន៍គម្រោង (Project Development Facility - PDF)។ | - ពិនិត្យលទ្ធភាពលើការរៀបចំបង្កើត និងដាក់ឱ្យអនុវត្តមូលនិធិបំពេញផលហិរញ្ញវត្ថុ (Viability Gap Fund - VGF) ដែលមានគោលដៅផ្តល់ឧបត្ថម្ភធនដល់គម្រោងវិនិយោគសាធារណៈមួយចំនួន ឱ្យមានភាពទាក់ទាញពីវិស័យឯកជន និងស្ថាប័នហិរញ្ញវត្ថុ។<br>- រៀបចំ និងដាក់ឱ្យអនុវត្តនីតិវិធីប្រតិបត្តិការនៃមូលនិធិបំពេញផលហិរញ្ញវត្ថុ (Viability Gap Fund - VGF)។ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | -រាជរដ្ឋាភិបាល, ADB, និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត |

| ទិសដៅការគោលនយោបាយ | សកម្មភាព | | ក្រសួង/ស្ថាប័នទទួលបន្ទុក | ប្រភពហិរញ្ញប្បទាន |
|---|---|---|---|---|
| | ឆ្នាំ២០១៦-២០១៨ | ឆ្នាំ២០១៩-២០២០ | | |
| ៣. ការរៀបចំ និងកំណត់យន្តការស្ថាប័ន | – ធ្វើសមាហរណកម្មមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងអង្គភាពគ្រប់គ្រងហានិភ័យនៅក្នុងរចនាសម្ព័ន្ធដែលមានស្រាប់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; | – ពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន និងអង្គភាពគ្រប់គ្រងហានិភ័យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ; | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | -រាជរដ្ឋាភិបាល, ADB, និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត |
| | – បង្កើតឬធ្វើសមាហរណកម្មមុខងារនៃអង្គភាពភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យ។ | – ពិនិត្យ និងកែសម្រួលឡើងវិញនូវមុខងារនៃអង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅតាមបណ្តាក្រសួង ស្ថាប័នតាមវិស័យ។ | -ក្រសួង ស្ថាប័នពាក់ព័ន្ធ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | |
| ៤. ការអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្ស | – រៀបចំ និងដាក់ឱ្យអនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាព ស្ថាប័ន និងធនធានមនុស្ស។ | – ធ្វើបច្ចុប្បន្នកម្មផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងធនធានមនុស្ស។ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ | -រាជរដ្ឋាភិបាល, ADB, និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត |

## ៨-ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តវិធានការគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបន្តទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការធានាឱ្យបាននូវប្រសិទ្ធភាព, វឌ្ឍនភាព, និងសង្គតិភាពនៃការអនុវត្តវិធានការគោលនយោបាយនេះ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តប្រគល់ភារកិច្ចជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការសម្របសម្រួលលើការអនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តវិធានការគោលនយោបាយដូចខាងក្រោម÷

- **ប្រព័ន្ធរបាយការណ៍**÷ ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវផ្តល់របាយការណ៍ប្រចាំត្រីមាស, ឆមាស, និងឆ្នាំ ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តវិធានការគោលនយោបាយពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន ជូនគណៈកម្មការអន្តរក្រសួង តាមរយៈ អង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ គណៈកម្មការអន្តរក្រសួង ដែលមានអង្គភាព ភាពជាដៃគូរវាងរដ្ឋ និង ឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការ ត្រូវចងក្រងរបាយការណ៍ប្រចាំឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **យន្តការដោះស្រាយបញ្ហាប្រឈម**÷ គណៈកម្មការអន្តរក្រសួង មានភារកិច្ចពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានាដើម្បីដោះស្រាយបញ្ហាប្រឈមៗ។ ក្នុងករណីហួសវិសាលភាព ត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- **យន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីវឌ្ឍនភាពជាប្រចាំ**÷ អង្គភាព ភាពជាដៃគូរវាងរដ្ឋ និងឯកជន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានភារកិច្ចតាមដាន, ត្រួតពិនិត្យ, និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈមដែលបានដាក់ចេញ ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តនេះ ជូនគណៈកម្មការអន្តរក្រសួង។

## ៩-សេចក្តីសន្និដ្ឋាន

ជារួម ក្នុងបរិការណ៍ថ្មីនៃការអភិវឌ្ឍរបស់កម្ពុជា រាជរដ្ឋាភិបាលពិនិត្យឃើញថា ការដាក់ឱ្យអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាពនូវយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈ ពិតជាមានសារៈសំខាន់ក្នុងចលនការនៃការបន្តជំរុញគាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច-សង្គមក្នុងល្បឿនលឿន ជាពិសេស ការឆ្លើយតបបានគ្រប់គ្រាន់ ទាំងបរិមាណ និងទាំងប្រសិទ្ធភាពនៃសេវាសាធារណៈ ចំពោះតម្រូវការប្រើប្រាស់របស់ប្រជាជន។

ពិតណាស់ថា ឯកសារគោលនយោបាយនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងជាសេចក្តីសម្រេចជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការកំណត់វិស័យអាទិភាពសម្រាប់គម្រោងវិនិយោគសាធារណៈដែលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។ ដូច្នេះ ដើម្បីឈានដល់ការអនុវត្តពេញលេញនូវយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន នៅមុនដំណាច់ឆ្នាំ២០២០ រាជរដ្ឋាភិបាលត្រូវបន្តខិតខំរៀបចំក្របខ័ណ្ឌគតិយុត្ត, នីតិវិធីគ្រប់គ្រងប្រតិបត្តិការ, កំណត់យន្តការស្ថាប័ន, បង្កើតយន្តការគាំទ្រហិរញ្ញវត្ថុ, និងអភិវឌ្ឍសមត្ថភាពស្ថាប័ន និងធនធានមនុស្សចាំបាច់ ដូចដែលបានណែនាំនិងដាក់ចេញក្នុងវិធានការជាយុទ្ធសាស្ត្រនៃឯកសារគោលនយោបាយនេះ។

រាជរដ្ឋាភិបាល ចាត់ទុកឯកសារគោលនយោបាយនេះ ជាឯកសាររស់ ដែលអាចនឹងត្រូវបានកែសម្រួលជាយថាហេតុ ដើម្បីធានាសង្គតិភាពចំពោះវិវឌ្ឍនការនៃបរិការណ៍ជាក់ស្តែងនៅកម្ពុជា នាពេលខាងមុខ។ ទន្ទឹមនេះ រាជរដ្ឋាភិបាល សង្ឃឹមយ៉ាងមុតមាំថា ការអនុវត្តដោយជោគជ័យនូវ **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥"** នឹងរួមចំណែក៖ (១) លើកកម្ពស់ការចូលរួមរបស់វិស័យឯកជន, ស្ថាប័នហិរញ្ញវត្ថុ, និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធក្នុងការបង្កើនប្រសិទ្ធភាព និងនវានុវត្តភាពនៃការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធសាធារណៈ, វិស័យអាទិភាពបង្កើនផលិតភាពសេដ្ឋកិច្ច, និងវិស័យសេវាសាធារណៈផ្សេងទៀត; និង (២) ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមរយៈនៃការពង្រឹងសមត្ថភាពក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ លើភាពអាចប៉ាន់ប្រមាណបាននៃកាតព្វកិច្ចបំណុលជាយថាហេតុរបស់រដ្ឋ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលប្រគល់ភារកិច្ចជូន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកជាស្ថាប័ននាំមុខក្នុងការសម្របសម្រួលលើការអនុវត្ត **"ឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២៥"** ដោយត្រូវមានការចូលរួមផ្តល់កិច្ចសហប្រតិបត្តិការពេញលេញ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ពីសំណាក់ក្រសួងស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល។

# ឧបសម្ព័ន្ធ២

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៩០ សហវ.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍឧស្សាហកម្មភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **វង្សី វិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២- | ឯកឧត្តម | **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម | **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- | ឯកឧត្តម | **ធេង បញ្ញាធុន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការនៃក្រសួងផែនការ | អនុប្រធាន |
| ៥- | ឯកឧត្តម | **ហ៊ុន ចុំពិកស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- | លោកជំទាវ | **ម៉ែន នជា** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៧- | ឯកឧត្តម | **ទូ សុចក្តិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨- | លោកជំទាវ | **តឹករ៉េក តំរេច** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- | ឯកឧត្តម | **គីម ឌុច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០- | ឯកឧត្តម | **ម៉ម អ៊ិណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- | ឯកឧត្តម | **នេត ធន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២- | ឯកឧត្តម | **សៅ សុភាព** | ទីប្រឹក្សាអមក្រសួង និងជានាយកខុទ្ទកាល័យក្រសួងបរិស្ថាន | សមាជិក |
| ១៣- | ឯកឧត្តម | **សុខ តុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤- | ឯកឧត្តម | **ជិន ម៉ាលីន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៥- | ឯកឧត្តម | **ចាម ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦- | ឯកឧត្តម | **គង់ ចិមុល** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ១៧- | ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨- | ឯកឧត្តម | **គុណ ញឹម** | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា កសហវ | សមាជិក |
| ១៩- | ឯកឧត្តម | **ហាច រតនៈ** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ២០- | ឯកឧត្តម | **អ៊ុំ សិទ្ធីរ៉ា** | អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ កសហវ | សមាជិក |
| ២១- | ឯកឧត្តម | **ម៉ែន ឌីរុទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល កសហវ | សមាជិក |
| ២២- | លោក | **គីមនី កោមសី** | អគ្គនាយករងបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៣- | លោក | **ស៊ុន ចាន់សេរីវុឌ្ឍ** | អគ្គនាយករងនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

២៤- លោក **ចន ណារិទ្ធ** អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយ សេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ កសហវ សមាជិក

២៥- លោក **ស៊ុន ផល្លា** ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម កសហវ សមាជិក

**ប្រការ២.-**

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងរៀបចំ និងផ្តល់អនុសាសន៍ក្នុងការធ្វើវិសោធនកម្ម ឬ ធ្វើសំណើរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមការចាំបាច់។
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាលមិទ្ធិលទ្ធភាពគម្រោងអាទិភាព រួមទាំងគម្រោងដែលនឹងដាក់ឱ្យអនុវត្តសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ឬកសរុបរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាពត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣.-**

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានក្រុមការងារបច្ចេកទេស សម្រាប់សម្របសម្រួលការអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ដែលមានសមាសភាពដូចខាងក្រោម÷

១- ឯកឧត្តម **វ៉េង ធីរុត្ថ** អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អសប) ប្រធាន

២- លោក **រស់ មរម** អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា (អថ) អនុប្រធាន

៣- លោក **ម៉ាច សុភារ៉ា** ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុលនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល អនុប្រធាន

៤- លោក **ចន្ធី ទិចិត្រា** អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា សមាជិក

៥- លោក **នួម ម៉ាត់ធារិទ្ធ** អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា សមាជិក

៦- លោក **ហ៊ុល បុណ្ណារ័ត្ន** អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល សមាជិក

៧- លោក **ចាន់ សុបញ្ញាច័ន្ទ** អនុប្រធានការិយាល័យសហប្រតិបត្តិការពហុភាគីទី១ នៃនាយកដ្ឋានសហប្រតិបត្តិការពហុភាគី (អសប) សមាជិក

៨- ការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជននៃនាយកដ្ឋានវិនិយោគ (អថ) សមាជិក

៩- ការិយាល័យវិភាគបំណុលនៃនាយកដ្ឋានគ្រប់គ្រងបំណុល (អសប) សមាជិក

**ប្រការ៤._**

ក្រុមការងារបច្ចេកទេស សម្រាប់សម្របសម្រួលការអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន មានភារកិច្ច ដូចខាងក្រោម៖

- សម្របសម្រួលនិងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ផ្តល់ការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចចុះកិច្ចសន្យាជាមួយដៃគូឯកជន ក្នុងការកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងការអនុវត្តគម្រោង។
- ពិនិត្យ និងតាមដានលើកិច្ចប្រតិបត្តិនៅគ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ផ្តល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងលើការអនុវត្ត និងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់គាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារសិក្សា និងការរៀបចំគម្រោង ព្រមទាំងប្រតិបត្តិការនានាដើម្បីឈានដល់ការប្រគល់កិច្ចសន្យាអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួង។
- បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ និងអគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច,ឯកឧត្តម, លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ

# សមាសភាពក្រុមការងារបច្ចេកទេស
# រៀបចំឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការគាំពារដៃគូរវាងរដ្ឋនិងឯកជន
# សម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ២០១៦-២០២០

| | | |
|---|---|---|
| ១- ឯកឧត្តម | **វ៉ែន ឋិរុទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អសប) |
| ២- លោក | **រស់ បរម** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា (អថ) |
| ៣- លោក | **ឈុន សិរីឌ្ឋិ** | អគ្គនាយករង នៃ អសប |
| ៤- លោក | **ម៉ាង សុតារ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុល (នគប) នៃ អសប |
| ៥- លោក | **ហ៊ូ គុណាឌុឌ្ឍន៍** | ប្រធាននាយកដ្ឋានកិច្ចការទូទៅ នៃ អសប |
| ៦- លោក | **ហ៊ុល មុណ្ណារ័ត្ន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគី (នសព) នៃ អសប |
| ៧- លោក | **ឱម ម៉ាត់ឆារិទ្ធ** | អនុប្រធាននាយកដ្ឋានវិនិយោគ (នវ) នៃ អថ |
| ៨- លោក | **ស ម៉ិនអ៊ិង** | ប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នៃ នវ-អថ |
| ៩- លោក | **ខៀម ណារ៉ា** | ប្រធានការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១០- លោក | **ឈឹម សុចរស្មី** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នៃ នវ-អថ |
| ១១- លោក | **លុយ សុក្រឹត** | អនុប្រធានការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជន នៃ នវ-អថ |
| ១២- លោក | **ចាន់ សុបញ្ញាច័ន** | អនុប្រធានការិយាល័យសហប្រតិបត្តិការពហុភាគីទី១ នៃ នសព-អសប |
| ១៣- លោកស្រី | **ឌុន មុនីកា** | មន្ត្រីការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១៤- លោកស្រី | **ឈុន ធីរៈមង្គលា** | ជំនាញការផ្នែកវិភាគបំណុល នៃការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១៥- លោក | **អ៊ុន សាភាន** | ជំនាញការផ្នែកវិភាគបំណុល នៃការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១៦- កញ្ញា | **អ៊ុង ច័ន្ទពិសី** | ជំនាញការផ្នែកវិភាគបំណុល នៃការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១៧- លោក | **ជាង សុធុទ្ធី** | ជំនាញការផ្នែកគ្រប់គ្រងបំណុល នៃការិយាល័យវិភាគបំណុល នៃ នគប-អសប |
| ១៨- លោក | **ឃ៉ន ហ៊ុន** | ជំនាញការផ្នែកគ្រប់គ្រងបំណុល នៃការិយាល័យវិភាគបំណុល នៃ នគប-អសប |

# ឧបសម្ព័ន្ធ៣

# សំណួរត្រៀមចុះស្រាវជ្រាវឯកសារ

(សិក្សាទៅលើការសាងសង់ផ្លូវថ្នល់ ឬអគារដែលអនុវត្តតាមយន្តការភាពជាដៃគូ
រវាងរដ្ឋ និងឯកជន នៅក្រសួងសាធារណការ និងដឹកជញ្ជូន)

**# ពត៌មានទូទៅនៃគម្រោង៖**

១-តើគម្រោងធ្វើការសាងសង់ទៅលើអ្វី? តើមានទីតាំងនៅកន្លែងណា? តើធ្វើការសាងសង់ និងបញ្ចប់នៅពេលណា? តើក្រុមហ៊ុនមានឈ្មោះអ្វី ដែលរដ្ឋបានសម្រេចចិត្តចុះកិច្ចសន្យាដើម្បីឲ្យទទួលការសាងសង់?

**# នីតិវិធីនៃការរៀបចំគម្រោង៖**

១-តើមានក្រសួងពាក់ព័ន្ធណាខ្លះដែលបានចូលរួមក្នុងគម្រោងដែលអនុវត្តតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន? ចូរបញ្ជាក់ពីកាតព្វកិច្ច និងដែនសមត្ថកិច្ចនៃក្រសួងនីមួយៗ។

- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងពាក់ព័ន្ធផ្សេងទៀត។

២-តើមានចំណុចសំខាន់ៗអ្វីខ្លះ ដែលភាគីរដ្ឋផ្ទាល់បានសម្រេចចិត្តយកគម្រោងខាងលើទៅអនុវត្តតាម Public-Private Partnership នៅពេលរៀបចំនីតិវិធីគម្រោង?

- គម្រោងមានលក្ខណៈធំល្មមដែលរដ្ឋពុំមានលទ្ធភាពក្នុងការសាងសង់ដូចជា ការប្រើរយះពេលយូរ និងការចំណាយទុនច្រើនដែលរដ្ឋពុំមានលទ្ធភាពដូចជា ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសនៃការសាងសង់។
- តម្រូវការនិរន្តភាពរបស់សមិទ្ធផលនៃគម្រោង និងបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទៅលើសេវាសាធារណៈដែលមានប្រសិទ្ធិភាព និងសមភាព។
- មានគោលការណ៍ច្បាប់គ្រប់គ្រាន់ ដើម្បីអោយរដ្ឋាភិបាលចូលរួមក្នុងរចនាសម្ព័ន្ធនៃគម្រោងដែលអនុវត្តតាម Public-Private Partnership។ តើគោលការណ៍នៃច្បាប់នោះមានអ្វីខ្លះ? ចូររៀបរាប់ និងពន្យល់។
- ផ្សេងៗទៀត។

៣-តើភាគីរដ្ឋបានរៀបចំផែនការអ្វីខ្លះនៃគម្រោងដែលនឹងត្រូវដាក់អោយធ្វើកិច្ចលទ្ធកម្ម និង អនុវត្ត?

- តើត្រូវប្រើរយៈពេលប៉ុន្មានចំពោះការសាងសង់ និងការគ្រប់គ្រងដោយភាគីឯកជន ដែលបានកំណត់នៅក្នុងកិច្ចសន្យា?
- តើមានធ្វើការបាន់ស្មាន និងវាយតម្លៃទៅលើអ្នកប្រើប្រាស់សេវា និងចំណូលដែល បានមកពីអ្នកប្រើប្រាស់សេវាបានកម្រិតណា ស្របពេលដែលអនុវត្ត និងក្រោយពេល អនុវត្តកិច្ចសន្យា?
- តើនៅក្នុងផែនការគម្រោងដែលមានសេចក្តីព្រាងនៃកិច្ចសន្យាដែលអនុវត្តតាម Public-Private Partnership រដ្ឋមានបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីឯក ជនដែរឬទេ ក្រោយពេលដែលកិច្ចសន្យានៃគម្រោងត្រូវបានអនុវត្ត? ចូរបញ្ជាក់ពីតួ នាទី និងការទទួលខុសត្រូវទាំងអស់នោះ។
- តើមានភាគជោគជ័យសំខាន់ៗអ្វីខ្លះដែលរដ្ឋនឹងរំពឹងទុកក្រោយពេលដែលគម្រោង សាងសង់ និងកិច្ចសន្យាត្រូវបានបញ្ចប់?
  - គម្រោងដែលត្រូវបង្កើតឡើងមានឥទ្ធិពលទៅលើការផលប្រយោជន៍សង្គម និង សេដ្ឋកិច្ច។ ចូររៀបរាប់ និងបញ្ជាក់។
  - ជួយសម្រួលបន្ទុកផ្នែកហិរញ្ញវត្ថុរបស់រដ្ឋ។ ចូរបញ្ជាក់ និងបកស្រាយ។
  - ផ្សេងៗទៀត។
- ផ្សេងៗទៀត។

**# នីតិវិធីលទ្ធកម្មៈ**

១-តើមានក្រុមហ៊ុនឯកជនចំនួនប៉ុន្មានដែលចូលធ្វើការដេញថ្លៃ? ចូររៀបរាប់។

២-តើមានដំណាក់កាលអ្វីខ្លះដែលរដ្ឋបានអនុវត្តក្នុងការធ្វើកិច្ចលទ្ធកម្មគម្រោង? ចូរបក ស្រាយ និងពន្យល់នូវដំណាក់កាលនីមួយៗ។

- ការដេញថ្លៃ
- ការពិគ្រោះថ្លៃ
- ការស្នង់មតិ។

៣-តើមាននីតិវិធីផ្សេងៗទៀតអ្វីខ្លះ ដែលរដ្ឋបានប្រើប្រាស់ក្នុងកិច្ចលទ្ធកម្មនៃគម្រោង?

- បង្កើតសិក្ខាសាលាដើម្បីណែនាំបន្ថែមឲ្យច្បាស់រវាងភាគីទាំងសងខាងទៅលើសេចក្តីព្រាងនៃកិច្ចសន្យា ឬចំណុចសំខាន់ដទៃទៀត។
- តាមវិធីផ្សេងៗទៀត។

**# ការអនុវត្តគម្រោង៖**

១-តើភាគីទាំងសងខាងបានអនុវត្តអ្វីខ្លះនៅក្នុងដំណាក់កាលនៃការអនុវត្តគម្រោង?

- ធានាការជួលជុលទៅលើសំណង់នៃគម្រោងដោយភាគីឯកជន។ ចូររៀបរាប់។
- ភាគីឯកជនអាចរកប្រភពប្រាក់ចំណូលដទៃទៀតពីគម្រោង។ ចូររៀបរាប់។
- ភាគីរដ្ឋដើរតួជាអ្នកសម្របសម្រួលទៅលើបញ្ហាដែលកើតឡើងផ្សេងៗ។ ចូររៀបរាប់។
- តើមានហានិភ័យអ្វីខ្លះដែលកើតមានក្នុងពេលដែលគម្រោងត្រូវបានគ្រប់គ្រងដោយភាគីឯកជន? តើហានិភ័យនោះមានការទទួលខុសត្រូវដោយមានការបែកចែកបានត្រឹមត្រូវ ឬអត់? ចូរបញ្ជាក់ និងពន្យល់។
- ផ្សេងៗទៀត។

**# ទំនាក់ទំនងរវាងរដ្ឋ និងដៃគូឯកជន៖**

១-តើភាគីទាំងសងខាងមានទំនាក់ទំនងយ៉ាងដូចម្តេចខ្លះ នៅពេលដែលអនុវត្តគម្រោង?

- តើនៅក្នុងអំឡុងពេលនៃការសាងសង់ រដ្ឋបានធ្វើការត្រួតពិនិត្យ និងគ្រប់គ្រងទៅលើចំណុចណាខ្លះរបស់ភាគីឯកជន? ចូរធ្វើការបកស្រាយ និងពន្យល់។
- តើភាគីឯកជនបានធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពនៃគម្រោងទៅឲ្យរដ្ឋ ឬអត់? តើរបាយការណ៍ស្តីពីវឌ្ឍភាននៃគម្រោងនោះមានអ្វីខ្លះ?
- តើភាគីឯកជនទទួលបានប្រាក់គ្រប់គ្រាន់ដែរ ឬទេពីអ្នកដែលប្រើប្រាស់សេវា ដើម្បីជួយទ្រទ្រង់ការគ្រប់គ្រងនៃគម្រោង ជាមួយនឹងការចំណាយផ្សេងៗទៀត? ចូររៀបរាប់។
- តើរដ្ឋបានរៀបចំការទូទាត់ថវិកា ទៅឲ្យភាគីឯកជនបានទៀងទាត់ឬទេ? ចូរធ្វើការបញ្ជាក់ និង បកស្រាយ។
- ផ្សេងៗទៀត។

**# ការត្រួតពិនិត្យរបស់រដ្ឋនៅពេលបញ្ចប់គម្រោង៖**

១-ក្រោយពីគម្រោងត្រូវបានបញ្ចប់ តើរដ្ឋបានត្រួតពិនិត្យទៅលើចំណុចសំខាន់ៗអ្វីខ្លះ?

-  តើស្ថានភាពនៃទ្រព្យរបស់គម្រោងមានលក្ខណៈដូចម្តេចនៅពេលដែលកិច្ចសន្យាត្រូវបានបញ្ចប់ និងត្រូវផ្ទេរទៅឲ្យរដ្ឋ?
-  តើស្ថាប័នណាទទួលបន្ទុកក្នុងការគ្រប់គ្រងនូវទ្រព្យសម្បត្តិទាំងនេះ?
-  តើមានការផ្លាស់ប្តូរអ្វីខ្លះ ក្រោយពេលកិច្ចសន្យាត្រូវបានបញ្ចប់ និងមានការផ្ទេរទ្រព្យទៅឲ្យរដ្ឋគ្រប់គ្រងបន្ទាប់?
    - o តម្លៃនៃសេវាសាធារណៈ
    - o ការទទួលខុសត្រូវ ដូចជាការជួសជុល និងការរៀបចំ
    - o ផ្សេងៗទៀត។
-  ផ្សេងៗទៀត។

**# ទំនាក់ទំនងរវាងប្រជាពលរដ្ឋ និងដៃគូឯកជនះ**

១-តើគម្រោងខាងលើមានជាប់ពាក់ព័ន្ធនឹងប្រជាពលរដ្ឋ ឬអ្នកទទួលសេវាសាធារណៈដែរឬទេ? ចូររៀបរាប់ និងពន្យល់។

-  អ្នកទទួលសេវាត្រូវធ្វើការបង់ថ្លៃទៅលើការប្រើប្រាស់សំណង់នៃគម្រោង។ ចូររៀបរាប់ និងបញ្ជាក់។
-  សមិទ្ធផលនៃគម្រោងមានឥទ្ធិពលទៅលើផលប្រយោជន៍សង្គម និងសេដ្ឋកិច្ច។ ចូររៀបរាប់ និងបញ្ជាក់។
-  ផ្សេងៗទៀត។

# ឧបសម្ព័ន្ធ៤

# ផែនទីនៃគម្រោង


项目起点 K0+000
K 线
项目终点 K190+633
PHNOM PENH
KAMPONG SPEU
KANDAL
TAKEO
KAMPOT
KRONG PREAH SIHANOUK
KRONG KEP
Southern Cardamoms
Kirirom
Ta Moa
Dong Peng
Botum Sakor
Phnom Bokor
Kbal Chay
Ream
TONLE BASSAC
TONLE MEKONG
VIETNAM


Starting Point K0+000
Total length = 190.365 km
Ending Point K190+365

## គំរូផ្លូវប្រសព្វប្តូរទិសចរាចរនៃផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ



## គំរូតំបន់ផ្តល់សេវាកម្មតាមផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ



# ការត្រៀមរៀបចំសាងសង់ ផ្លូវល្បឿនលឿន ភ្នំពេញ-ខេត្តព្រះសីហនុ












